ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការយល់ដឹងពីយេនឌ័រ



## បំណិនជីវិតសម្រាប់មធ្យមសិក្សាបឋមភូមិ
## គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ១០១១ អយក.ប្រក

# ប្រកាស
# ស្តីពី
# ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
# សៀវភៅ " ការយល់ដឹងពីយេនឌ័រ "

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញអនុក្រឹត្យលេខ ៨៤អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-យោងសេចក្តីណែនាំលេខ ០៣ អយក.សណន.ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
-យោងសំណើរបស់អង្គការអប់រំពិភពលោក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២
-យោងកំណត់ហេតុប្រជុំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអនុម័តសៀវភៅ និងសម្ភារឧបទេសនាថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩
-តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

## សម្រេច

ប្រការ ១ - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ " ការយល់ដឹងពីយេនឌ័រ " ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់អង្គការអប់រំពិភពលោក សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការបង្រៀន និងរៀនកម្មវិធីបំណិនជីវិត នៅតាមសាលារៀនមធ្យមសិក្សាបឋមភូមិ ។

ប្រការ ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងអង្គការអប់រំពិភពលោក មានភារកិច្ចអនុវត្តប្រកាសនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៩

បណ្ឌិត ហង់ ជួន ណារ៉ុន

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន "
- ដូចប្រការ២
- កាលប្បវត្តិ
- ឯកសារ៖ អគស.

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ៨៦៧ ៣៥៦ / ២១៧ ២៥៣ / ៨៦៦ ៤៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

**គណៈកម្មការអភិវឌ្ឍសៀវភៅ**
**"ការយល់ដឹងពីយេនឌ័រ"**

**គណៈកម្មការនិពន្ធ និងរៀបរៀង**

១. លោក អេង សុខ
២. លោក វីលៀម វ៉ាន់ឌីវ៉ាល់

**គណៈកម្មការកែសម្រួល**

១. លោក ឈុំ វណ្ណធន
២. លោក ប៊ុត សុភាន់
៣. លោក ផុក ចាន់ថុល

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ(USAID)

សហការរៀបចំដោយ
អង្គការអប់រំពិភពលោក និង ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា


អារម្ភកថា........................................ ក

វត្ថុបំណងរួម........................................ ខ

ការត្រៀមលក្ខណៈមុនពេលបង្រៀន........................................ ខ

ខ្លឹមសារសង្ខេប........................................ គ

មេរៀនទី ១៖ អំពីវប្បធម៌ និងការផ្លាស់ប្តូរ........................................ ១

មេរៀនទី ២៖ ភេទ និង យេនឌ័រ........................................ ៩

មេរៀនទី ៣៖ ការរើសអើង........................................ ១៥

មេរៀនទី ៤៖ តួនាទីយេនឌ័រនៅក្នុងសហគមន៍........................................ ២០

មេរៀនទី ៥៖ ការវិភាគនៅក្នុងសហគមន៍........................................ ២៩

មេរៀនទី ៦៖ ផ្នត់គំនិត និង ក្តីកង្វល់........................................ ៣៤

មេរៀនទី ៧៖ ការបែងចែកផ្នត់គំនិត........................................ ៣៩

មេរៀនទី ៨៖ ការចែករំលែកចំណេះដឹង........................................ ៤៦

មេរៀនទី ៩៖ ការចែករំលែកចំណេះដឹង(ត)........................................ ៥១

មេរៀនទី ១០៖ គោលបំណងសម្រាប់អនាគត........................................ ៥៤

# អារម្ភកថា

វិស័យអប់រំជាវិស័យគន្លឹះមួយ រួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសការអភិវឌ្ឍធនធានមនុស្ស។ ដោយសង្គមជាតិយើងមានការអភិវឌ្ឍលើគ្រប់វិស័យ ការអប់រំក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីបណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយគុណភាពនិងមានជំនាញខ្ពស់ ដើម្បីបំពេញលើគ្រប់លក្ខខណ្ឌការងារ។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើននៃទីផ្សារសេរីរបស់សង្គមជាតិ ក្រសួងអប់រំ យុវជននិងកីឡា បានបង្កើតគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីចំណេះទូទៅ និងគោលនយោបាយអប់រំបំណិនជីវិត សម្រាប់អនុវត្តនៅតាមសាលារៀនចំណេះទូទៅ។

កម្មវិធីបំណិនជីវិតនៅតាមមូលដ្ឋាន គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពក្នុងវិស័យអប់រំ ដែលនឹងផ្តល់ឱ្យសិស្សនូវចំណេះដឹងមូលដ្ឋានយ៉ាងជ្រៅជ្រះ និងពង្រឹងជំនាញផ្សេងៗ ដែលមានសារៈសំខាន់សម្រាប់ការស្រូបយកបទពិសោធន៍ល្អៗក្នុងការពង្រឹងចំណេះដឹង និងបំណិន ចាំបាច់សម្រាប់បម្រើជីវភាពរស់នៅប្រចាំថ្ងៃ។

យេនឌ័រគឺជាប្រធានបទដ៏ស្មុគស្មាញមួយដែលគួរតែត្រូវបានដាក់បញ្ចូលទៅគ្រប់មាតិកា និងដំណើរការទាំងអស់នៃកម្មវិធីបំណិនជីវិតក្នុងតំបន់។ ក្នុងពេលជាមួយគ្នានេះ ការលើកទឹកចិត្តសិស្សឱ្យផ្តោតការយកចិត្ត ទុកដាក់ទៅលើក្តីបារម្ភអំពីយេនឌ័រជាក់លាក់មួយ នៅក្នុងកម្រិតមូលដ្ឋានគួរតែជាផ្នែកមួយដ៏សំខាន់នៅក្នុងបទពិសោធន៍នៃការសិក្សា។

សៀវភៅនេះផ្តល់ឱ្យគ្រូនូវធនធានសម្ភារៈសម្រាប់ជួយសម្រួលក្នុងការបង្រៀន និងការរៀនពីប្រធានបទតូចៗដែលស្ថិតនៅក្រោមយេនឌ័រ និងជាផ្នែកមួយនៃកម្មវិធីបំណិនជីវិតដែលជាប្រធានបទទាក់ទងនឹងសង្គមក្នុងតំបន់។ សេចក្តីបញ្ជាក់ របស់សៀវភៅនេះគឺនៅលើការអភិវឌ្ឍចំណេះដឹងរបស់គ្រូ និងសិស្ស ដោយប្រើប្រាស់ការបង្រៀនបែប សិស្សមជ្ឈមណ្ឌល ដូចដែលបានបង្ហាញនៅក្នុងសៀវភៅគ្រូបង្រៀន អប់រំ/អ្នកបណ្តុះបណ្តាលបំណិនជីវិតក្នុងតំបន់។ ស្របជាមួយនឹងវិធីសាស្ត្រនៃការបង្រៀន និងការរៀនរបស់គម្រោងសាកល្បងនៃបំណិនជីវិតរបស់គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា ដែលមានបំណង អភិវឌ្ឍជំនាញសិក្សា និងការបង្កើតថ្មីក្នុងចំណោមលោកគ្រូអ្នកគ្រូ និង សិស្សានុសិស្សទាំងឡាយ។

## ១. វត្ថុបំណងរួម

*បំណិនជីវិត គឺជាបំណិនបញ្ញា បុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការធ្វើការ សម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន ហើយបំណិនទាំងនេះរួមចំណែកក្នុងការលើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាព ដើម្បីដោះស្រាយបញ្ហាក្នុងជីវិតប្រចាំថ្ងៃបានយ៉ាងជោគជ័យ។(គោលនយោបាយបំណិនជីវិត ២០០៦)*

វត្ថុបំណងដ៏សំខាន់នៃសៀវភៅនេះគឺដើម្បីកសាងសមត្ថភាពរបស់លោកគ្រូ/អ្នកគ្រូ ឱ្យចេះប្រើ ប្រាស់សម្ភារៈពាក់ព័ន្ធ បង្កើតសម្ភារៈ និងគំនិតបង្រៀនផ្ទាល់ខ្លួនព្រមទាំងអាចផ្សព្វផ្សាយ និងចែករំលែកជាមួយសាលាដទៃទៀតដែលកំពុងអនុវត្តកម្មវិធីបំណិនជីវិតក្នុងតំបន់។

នៅក្នុងម៉ូឌុលនេះ សិស្សនឹងទទួលបានចំណេះដឹង និងបំណិន អំពីយេនឌ័រ ដោយៈ

- យល់ដឹងអំពីវប្បធម៌ និងឥទ្ធិពលរបស់វាចំពោះអាកប្បកិរិយា និងទំនាក់ទំនង។
- ផ្តល់ដល់សិស្សឱ្យយល់អំពីភាពខុសប្លែកគ្នារវាង ភេទ និងយេនឌ័រ។
- យល់ដឹងអំពីរបៀបដែលវប្បធម៌អាចកំណត់គុណតម្លៃដែលសង្គមបានដាក់លើ តួនាទីយេនឌ័ររបស់មនុស្សស្រី និងតួនាទីយេនឌ័ររបស់មនុស្សប្រុស។
- យល់ដឹងអំពីផ្នត់គំនិត និងការរើសអើង ព្រមទាំងផលប៉ះពាល់ ជាក់ស្តែងនៅក្នុងកន្លែងធ្វើការងារ។
- យល់ដឹងអំពីយេនឌ័រនៅក្នុងសមាជិកសហគមន៍ ពីតួនាទី និងទំនួលខុសត្រូវរបស់បុរសនិងនារី។
- វិភាគការឆ្លើយតបរបស់សហគមន៍ និងកំណត់ឧទាហរណ៍នៃផ្នត់គំនិតអំពីយេនឌ័រ។
- ប្រាប់ពីផ្នត់គំនិត យេនឌ័រ មិនមែនតែជាក្តីកង្វល់របស់ប្រទេសកម្ពុជា ប៉ុន្តែវាក៏ជាក្តីកង្វល់របស់ ពិភពលោក។
- កំណត់ជំនាញធ្វើការជាក្រុម និងជំនាញសង្ខេបតាមរយៈការស្គាល់នូវប្រធានបទសំខាន់ៗដែលទាក់ទងនឹងផ្នត់គំនិតយេនឌ័រនិងការធ្វើសេចក្តីសម្រេចចិត្តក្នុងការចិញ្ចឹមជីវិត។
- បង្រួមការសិក្សាអំពីប្រធានបទសំខាន់ៗ និងគំនិតផ្សេងៗពីវគ្គសិក្សា។
- ឆ្លុះបញ្ចាំងអំពីជំនាញ និងការអភិវឌ្ឍឥរិយាបថក្នុងអំឡុងពេលវគ្គសិក្សា។
- វាយតម្លៃការអភិវឌ្ឍចំណេះដឹងរបស់សិស្សក្នុងអំឡុងពេលវគ្គសិក្សា។

## ២. ការត្រៀមលក្ខណៈមុនពេលបង្រៀន

ម៉ូឌុលនេះត្រូវបានបែងចែកជាផ្នែកខុសៗគ្នា ។ ក្នុងផ្នែកនីមួយៗមានគោលបំណងរបស់វា និងមានព័ត៌មានទាក់ទងនឹងរបៀបចាប់ផ្តើមបង្រៀនសិស្ស ឬផ្នែកដែលទាក់ទងនឹងសកម្មភាពក្នុងការបង្រៀន។ វាក៏ផ្តល់នូវការណែនាំអំពីរបៀបរៀបចំសម្ភារៈដែលត្រូវការសម្រាប់ធ្វើសកម្មភាព។

- **សម្ភារឧបទេស**

ផ្នែកនេះផ្តល់នូវសេចក្តីសង្ខេបពីសម្ភារឧបទេស។ ភាគច្រើនជាសម្ភារៈមូលដ្ឋាន ដូចជា ប៊ិច ឬក្រដាស។ សម្ភារៈផ្សេងទៀតនៅក្នុងមេរៀននេះនឹងត្រូវផ្តល់ឱ្យសិស្សសម្រាប់អនុវត្ត តាមរយៈឯកសារសម្រាប់សិស្ស ដែលបានភ្ជាប់នៅក្នុងម៉ូឌុលនេះ។

● **លទ្ធផលរំពឹងទុក**

សិស្សនឹងទទួលបានចំណេះដឹង បំណិន និងឥរិយាបថពីការសិក្សាមេរៀនការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គម ដែលឆ្លុះបញ្ចាំងទៅនឹងគោលបំណងរួមរបស់បំណិនជីវិត ដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំបំណិនជីវិតនៅមធ្យមសិក្សាបឋមភូមិ ព្រមទាំងកំណត់នៅក្នុង*បំណិនមូលដ្ឋាន ការសិក្សាជំនួញ បំណិនសេដ្ឋកិច្ច និងបំណិនអាជីពងាយៗ។*

● **សញ្ញាសម្គាល់សម្រាប់សកម្មភាពនីមួយៗ**

ខាងក្រោមនេះជាសញ្ញាសម្គាល់សកម្មភាពងាយ ដើម្បីគ្រូអនុវត្តបានជោគជ័យក្នុងការបង្រៀននិងរៀន។

- ធ្វើសកម្មភាព ៖ គ្រូចាំបាច់ត្រូវធ្វើសកម្មភាពផ្ទាល់ខ្លួន
- សរសេរ ៖ ពេលខ្លះត្រូវការឱ្យគ្រូសរសេរនៅលើក្តារខៀន
- សួរ ៖ មានសំណួរ ដែលគ្រូសួរទៅកាន់សិស្ស
- ពន្យល់ ៖ ពន្យល់ចំណុចសំខាន់ៗ ឬ ប្រាប់សិស្សនៅក្នុងថ្នាក់

● **លំនាំបង្រៀន**

មេរៀននីមួយៗចែកជា ៣ផ្នែក។ ផ្នែកទី១ គឺជាសេចក្តីផ្តើមដែលយើងព្យាយាមផ្សារភ្ជាប់ទៅនឹងចំណេះដឹងដែលសិស្សមានស្រាប់ ឬរំលឹកមេរៀនចាស់។ ផ្នែកទី២ យើងនឹងបង្រៀនសកម្មភាពសំខាន់ៗដោយផ្អែកលើវិធីសាស្ត្របង្រៀនបែបការងារគម្រោង(ចុះស្រាវជ្រាវ ប្រមូលព័ត៌មានសម្ភាស ចងក្រងឯកសារ និងបទបង្ហាញ...។) និងយុទ្ធវិធីបង្រៀនផ្សេងៗទៀត។ នៅផ្នែកទី៣ ដែលជាផ្នែកបញ្ចប់ យើងអាចធានាបានថា រាល់លទ្ធផលនៃការសិក្សារបស់យើង គឺបានឆ្លងកាត់នូវយុទ្ធវិធីខុសៗគ្នាជាច្រើន។

## ៣. ខ្លឹមសារសង្ខេប

មេរៀនសង្ខេបត្រូវបានផ្តល់ជូនឱ្យគ្រូក្នុងផ្នែកនេះ ដើម្បីជាទុនខ្លះក្នុងការបង្រៀន ហើយក៏ជាសញ្ញាណមួយជាក់លាក់បញ្ជាក់ពីទំនាក់ទំនង និងសារៈសំខាន់រវាងមេរៀននីមួយៗ ។

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបនៃមេរៀនទាំង១០ដែលមាននៅក្នុងម៉ូឌុលបំណិនជីវិតនេះ៖

| ចំណងជើងមេរៀន | រយៈពេល | វត្ថុបំណង | ទំព័រ |
|---|---|---|---|
| ១. អំពីវប្បធម៌ និង ការផ្លាស់ប្តូរ | ១ ម៉ោង ៣០នាទី | ● ពន្យល់ពីអត្ថន័យរបស់វប្បធម៌ និងរបៀបដែលយើងទទួលបាន<br>● ពន្យល់ពីឥទ្ធិពលរបស់វប្បធម៌លើអាកប្បកិរិយា និងទំនាក់ទំនងផ្ទាល់ខ្លួន<br>● ពិភាក្សាពីរបៀបដែលវប្បធម៌អាចផ្លាស់ប្តូរពីមួយជំនាន់ទៅមួយជំនាន់ | ១ |
| ២. ភេទ និង យេនឌ័រ | ១ ម៉ោង ៣០នាទី | ● ពន្យល់ពីភាពខុសប្លែកគ្នារវាង ភេទ និងយេនឌ័រ<br>● ពន្យល់ពីវប្បធម៌លើការយល់ដឹងអំពីយេនឌ័រក្នុងសង្គម<br>● ពិភាក្សាពីរបៀបដែលវប្បធម៌អាចផ្លាស់ប្តូរពីមួយជំនាន់ទៅមួយជំនាន់ | ៩ |

| | | | |
|---|---|---|---|
| ៣. ការរើសអើង | ១ ម៉ោង ៣០នាទី | ● ស្គាល់ពីទម្រង់មួយចំនួននៃផ្នត់គំនិតយេនឌ័រ<br>● កំណត់ពីទម្រង់មួយចំនួននៃការរើសអើងក្នុងការងារ | ១៥ |
| ៤. តួនាទីយេនឌ័រនៅក្នុងសហគមន៍ | ១ ម៉ោង ៣០នាទី | ● បែងចែងតួនាទី និងទំនួលខុសត្រូវរបស់បុរស និងនារីជាការងារផលិតភាព ការងារបន្តពូជ និងការងារសហគមន៍។ | ២០ |
| ៥. ការវិភាគនៅក្នុងសហគមន៍ | ១ ម៉ោង ៣០នាទី | ● ពន្យល់ពីការឆ្លើយតបរបស់សហគមន៍អំពីការរំពឹងទុករបស់តួនាទី និងទំនួលខុសត្រូវដែលទាក់ទងនឹងផ្នត់គំនិតយេនឌ័រ។ | ២៩ |
| ៦. ផ្នត់គំនិត និងក្ដីកង្វល់ | ១ ម៉ោង ៣០នាទី | ● ពន្យល់ពីរបៀបនៃគំលាតយេនឌ័រក្នុងការងារប៉ះពាល់ប្រទេសឧស្សាហកម្មនៅលោកខាងលិចដូចជាអង់គ្លេស ព្រមទាំងប្រទេសក្រីក្រនៅលោកខាងកើតដូចជាកម្ពុជា។ | ៣៤ |
| ៧. ការបែងចែកផ្នត់គំនិត | ១ ម៉ោង ៣០នាទី | ● ផ្ដល់ឧទាហរណ៍ដែលសំអាងលើបទពិសោធន៍អំពីបុរសនិងស្ត្រីដែលទទួលយកតួនាទីមិនមែនជាប្រពៃណី។<br>● ផ្ដល់មូលហេតុសមរម្យសម្រាប់ស្ត្រីដើម្បីធ្វើការចិញ្ចឹមជីវិត ក្នុងផ្នែកដែលជាវប្បធម៌ត្រូវបានចាត់ទុកជាភាពជាមនុស្សស្រី និងផ្ទុយមកវិញ។ | ៣៩ |
| ៨. ការចែករំលែកចំណេះដឹង | ១ ម៉ោង ៣០នាទី | ● កំណត់និងស្គាល់គំនិតសំខាន់ៗដែលទាក់ទងនឹងផ្នត់គំនិតយេនឌ័រ និងការធ្វើការសម្រេចចិត្តក្នុងការចិញ្ចឹមជីវិត។ | ៤៦ |
| ៩. ការចែករំលែកចំណេះដឹង (ត) | ១ ម៉ោង ៣០នាទី | ● ប្រើប្រាស់ជំនាញនិងចំណេះដឹងរបស់ពួកគេដើម្បីបង្កើតជាផ្ទាំងរូបភាពមួយអំពីផ្នត់គំនិតយេនឌ័រ និងផលប៉ះ ពាល់របស់វាមកលើការធ្វើការសម្រេចចិត្តក្នុងការចិញ្ចឹមជីវិត។ | ៥១ |
| ១០. គោលបំណងសម្រាប់អនាគត | ១ ម៉ោង ៣០នាទី | ● ផ្ដល់ហេតុផលសមស្របអំពីអ្វីដែលពួកគេចង់ធ្វើ ឬក្លាយទៅជាពេលពួកគេបញ្ចប់ការសិក្សា<br>● មានអារម្មណ៍ល្អអំពីអ្វីដែលពួកគេបានរៀន និងបន្សល់ទុកនៅកំណត់ត្រាវិជ្ជមាន | ៥៤ |

## ៤. ការវាយតម្លៃ

ការវាយតម្លៃមាន២ផ្នែកសំខាន់ៗ។ មួយផ្នែកជាការវាយតម្លៃនៅចុងបញ្ចប់នៃម៉ូឌុលនីមួយៗ និងជាវិញ្ញាសាសរសេរដែលយើងត្រូវបញ្ចូលនៅផ្នែកខាងចុងម៉ូឌុល ។ ផ្នែកមួយទៀត ជាការវាយតម្លៃទៅលើឥរិយាបថសិស្ស ដោយគ្រូជាអ្នកសង្កេតផ្ទាល់រៀងរាល់ថ្ងៃ ហើយដាក់ពិន្ទុ។ វិធីវាយតម្លៃទាំងពីរចំណុចនេះមានសារៈសំខាន់ក្នុងការវាស់ចំណេះដឹង និងឥរិយាបថរបស់សិស្សម្នាក់ៗ ។ ចំពោះការវាយតម្លៃសិស្សនេះ យើងគិតពិន្ទុ ៥០ ស្មើទៅនឹងមុខវិជ្ជាមួយចំនួនផងដែរ គឺយើងឱ្យពិន្ទុ ៣៥ ទៅលើឥរិយាបថ និងពិន្ទុ ១៥ ទៅលើវិញ្ញាសាសរសេរ។

នៅតាមមេរៀននីមួយៗ គ្រូទុកពេលឱ្យសិស្សពិភាក្សាក្រុមតូចឱ្យបានច្រើន នៃចំណុចសំខាន់ៗនៅពាក់កណ្ដាលមេរៀននីមួយៗ។ កំឡុងពេលសិស្សពិភាក្សាក្រុមតូច ជាពេលវេលាដែលគ្រូអាចសង្កេតឥរិយាបថសិស្សក្នុងការដាក់ពិន្ទុ។ ជាការល្អគ្រូគួរដាក់ពិន្ទុឥរិយាបងសិស្សចាប់ពីមេរៀនទី ៦ តទៅ។

## ៥. ឯកសារបន្ថែម

ផ្នែកនេះផ្ដល់នូវព័ត៌មានរួមសម្រាប់គ្រូប្រើប្រាស់ រួមទាំងផ្ទាំងរូបភាពសម្រាប់គ្រូប្រើប្រាស់នៅក្នុងមេរៀននេះ។

# មេរៀនទី ១: អំពីវប្បធម៌ និងការផ្លាស់ប្ដូរ

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវនឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ក្ដារខៀន ដីស
- ផ្ទាំងក្រដាសធំ
- ហ្វឺតចំរុះពណ៌ ឬគូល័រទៀន
- ស្កុត
- ឯកសារសម្រាប់សិស្ស (ដូចបាននិយាយខាងលើ)

☼ លទ្ធផលរំពឹងទុក

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាចៈ

- ពន្យល់ពីអត្ថន័យរបស់វប្បធម៌ និងរបៀបដែលយើងទទួលយក
- ពន្យល់ពីឥទ្ធិពលរបស់វប្បធម៌លើអាកប្បកិរិយា និងទំនាក់ទំនងផ្ទាល់ខ្លួន
- រៀបរាប់ពីរបៀបដែលវប្បធម៌អាចផ្លាស់ប្ដូរពីមួយជំនាន់ទៅមួយជំនាន់

## សេចក្ដីផ្ដើមៈ ការណែនាំពីម៉ូឌុល និងតេស្តសាកល្បងមុនវគ្គ

🕑 ៣៥ នាទី

*(មេរៀននេះ យកលំនាំតាមកម្រងឧបករណ៍បណ្ដុះបណ្ដាលគាំទ្រដោយក្រសួងកិច្ចការនារី និង GIZ " កម្រងឧបករណ៍បណ្ដុះបណ្ដាលសម្រាប់មនុស្សវ័យក្មេងស្ដីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ" ភ្នំពេញ ខែមីនា ២០១០។)*

👄 គ្រូពន្យល់ថា ប្រធានបទរបស់ម៉ូឌុលដែលសិស្សនឹងត្រូវសិក្សាក្នុងរយៈពេល១០សប្ដាហ៍ ខាងមុខនេះគឺនិយាយអំពីឥទ្ធិពលរបស់យេនឌ័រចំពោះការសម្រេចចិត្តក្នុងការចិញ្ចឹមជីវិត។ ពន្យល់ក្នុងរយៈពេល១០សប្ដាហ៍នេះ ពួកគេនឹងរៀនពីប្រធានបទមួយចំនួនដូចជា វប្បធម៌និងការផ្លាស់ប្ដូរ យេនឌ័រនិងភេទ របៀបដែលគំនិតទាំងអស់នេះមានឥទ្ធិពលលើការសម្រេចចិត្តចំពោះជម្រើសមុខរបរ និងការងាររបស់យើង ឬក្នុងន័យម្យ៉ាងទៀតជម្រើសក្នុងជីវិតរស់នៅរបស់យើង។

✎ គ្រូសរសេរពាក្យ "យេនឌ័រ និងរបៀបដែលវាមានឥទ្ធិពលលើការសម្រេចចិត្តរបស់យើង" នៅលើក្ដារខៀន។

ការណែនាំពីតេស្តសាកល្បងមុនវគ្គ

ប្រាប់សិស្សថា ការសាកល្បងមុនវគ្គវាមានសារៈសំខាន់ណាស់ ដើម្បីស្វែងយល់ពីការគិត និងការយល់ដឹងរបស់អ្នកទាំងអស់អំពីប្រធានបទនេះ។ ម្យ៉ាងទៀតការសាកល្បងនេះ អាចជួយលោកគ្រូ/អ្នកគ្រូឱ្យត្រៀម មេរៀនបានល្អ ហើយក៏មានប្រយោជន៍ ដើម្បីឱ្យដឹងថា យើងរៀនបានកម្រិតណានៅពេលបញ្ចប់កម្មវិធីក្នុងរយៈពេល១០សប្តាហ៍នេះ។

ប្រាប់សិស្សទាំងអស់ថា គ្រូនឹងចែកក្រដាសសំណួរអំពីប្រធានបទដែលយើងនឹងត្រូវសិក្សាក្នុងរយៈពេល ១០ សប្តាហ៍នេះ។ នៅចុងបញ្ចប់នៃវគ្គសិក្សានេះ លោកគ្រូ/អ្នកគ្រូនឹងឱ្យតេស្តដូចគ្នានេះម្តងទៀត។ (បញ្ជាក់ប្រាប់សិស្សថា នេះមិនមែនជាតេស្តផ្លូវការនោះទេ ប៉ុន្តែជាដំណើរការសិក្សា។ ប្រសិនបើអ្នកទាំងអស់មិនយល់ច្បាស់អំពីចម្លើយ គ្រាន់តែសរសេរអ្វីដែលពួកគេគិត និងដឹងនៅលើក្រដាស។)

គ្រូចែកក្រដាសសំណួរទៅសិស្សគ្រប់គ្នា ហើយទុកពេលឱ្យ២៥នាទីក្នុងការធ្វើតេស្តនេះ។ (តេស្តសាកល្បងមុនវគ្គអាចរកឃើញនៅក្នុងឯកសារសម្រាប់សិស្ស)។

**សកម្មភាពសំខាន់។** ៤០ នាទី

គ្រូណែនាំអំពីប្រធានបទនិងវត្ថុបំណងរបស់មេរៀន។ ហើយឱ្យសិស្សពិភាក្សាអំពីវប្បធម៌ និងរបៀបដែលមានឥទ្ធិពលលើអាកប្បកិរិយា ការគិត និងទំនាក់ទំនងរបស់យើង។

មុននឹងយើងដឹងថាវប្បធម៌មានឥទ្ធិពលយ៉ាងណា យើងចាំបាច់ត្រូវយល់ពីវប្បធម៌ជាមុនសិន។ គ្រូសរសេរសំណួរខាងក្រោមនេះដាក់លើក្តារខៀនដើម្បីឱ្យសិស្សពិភាក្សា៖ តើវប្បធម៌ជាអ្វី?

គ្រូឱ្យសិស្សគិតរៀងៗខ្លួនអំពីចម្លើយរបស់សំណួរនេះដោយគ្មានការសរសេរ។ ប្រាប់ពួកគេថា៖ ពួកគេអាចប្រើសំណួរខាងក្រោម ដើម្បីជាជំនួយក្នុងការឆ្លើយសំណួរ។ ទុកពេល ៥ នាទី ។

*(គ្រូសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ខណៈដែលសិស្សកំពុងធ្វើតេស្ត)*

ក) ចូរឱ្យឧទាហរណ៍អំពីអ្វីដែលវប្បធម៌ផ្តល់សម្រាប់អ្នក។
ខ) តើយើងទទួលបានវប្បធម៌របស់យើងពីណា?
គ) តើនរណាផ្ទេរវប្បធម៌នេះមកឱ្យយើង?
ឃ) តើវប្បធម៌ជះឥទ្ធិពលចំពោះជីវិតយើងដោយរបៀបណា?

ក្រោយពេល៥នាទីផុតទៅ គ្រូឱ្យសិស្សចែករំលែកចម្លើយរបស់ពួកគេជាមួយដៃគូក្នុងរយៈពេល៥នាទី។ ហើយបន្ទាប់មក ឱ្យពួកគេចែករំលែកទៅថ្នាក់ទាំងមូល។ ខណៈពេលដែលពួកគេ កំពុងចែករំលែក ត្រូវកត់ត្រាពាក្យ/ឃ្លាគន្លឹះនៅលើក្តារខៀន ឬសួរសំណួរបញ្ជាក់បន្ថែម ព្រមទាំងព្យាយាមភ្ជាប់គំនិតរបស់ពួកគេនៅពេលណាដែលអាចធ្វើបាន *(មើល សេចក្តីណែនាំសម្រាប់គ្រូ)*។

ក្រោយពេលការពិភាក្សាត្រូវបានបញ្ចប់ គ្រូប្រាប់សិស្សថា យើងត្រូវប្រមូលផ្តុំគំនិតទាំងអស់នោះទៅជាប្រយោគពីរ ឬបីដែលឆ្លើយនឹងសំណួរថា តើវប្បធម៌ជាអ្វី? ឱ្យសិស្សម្នាក់មកខាងមុខក្តារខៀន ហើយសិស្សដទៃទៀតប្រាប់សិស្សនោះនូវអ្វីដែលត្រូវសរសេរ។ ពួកគេត្រូវប្រើ ពាក្យ និង ឃ្លានៅលើក្តារខៀន ដើម្បីបង្កើតជាប្រយោគមួយចំនួន ឬកថាខណ្ឌខ្លីមួយ ដែលឆ្លុះបញ្ចាំងពីចម្លើយរបស់សំណួរ *(ពិនិត្យមើលគំនិតសំខាន់ៗ ដែលបានផ្តល់ជូនក្នុងនិយមន័យក្នុងសេចក្តីណែនាំសម្រាប់គ្រូ)*។

នៅពេលពួកគេបានបញ្ចប់ ឱ្យពួកគេកត់ត្រាទុកក្នុងសៀវភៅរបស់ពួកគេនូវប្រយោគ ឬកថាខ័ណ្ឌដែលឆ្លើយនឹងសំណួរ។ *(គ្រូដើរពិនិត្យមើលខណៈពេលដែលសិស្សកំពុងកត់ត្រាពីក្តារខៀន ដើម្បីឱ្យដឹងថាសិស្សទាំងអស់យល់ពីអត្ថន័យរបស់ វប្បធម៌)*។

## ការពិភាក្សាអំពីវប្បធម៌ និងការផ្លាស់ប្តូរ

👄 គ្រូប្រាប់សិស្សថា អ្នកទាំងអស់នឹងពិភាក្សាអំពីរបៀបដែលវប្បធម៌អាចជះឥទ្ធិពលលើអាកប្បកិរិយារបស់យើង៖

- សួរសិស្សថាអ្វីជាសុភាសិត។ ឱ្យពួកគេ ផ្តល់ឧទាហរណ៍អំពីសុភាសិត។ *(ប្រសិនបើមានសុភាសិតមួយចំនួនដែលបង្ហាញពីរបៀបដែលបុរស នារី កុមារា និងកុមារីគួរតែប្រព្រឹត្ត និង/មានទំនាក់ទំនងរវាងឪពុកម្តាយនិងកូនៗ សរសេរពាក្យទាំងនោះលើក្តារខៀន)*។
- តើពួកគេអាចនឹកឃើញសុភាសិតផ្សេងទៀតដែលនិយាយអំពីរបៀបដែលបុរស នារី កុមារា និងកុមារីគួរតែប្រព្រឹត្ត ឬសុភាសិតដែលនិយាយអំពីទំនាក់ទំនងរវាងឪពុកម្តាយនិងកូនៗ។ *(សរសេរពាក្យទាំងនោះលើក្តារខៀន។ លោកគ្រូ/អ្នកគ្រូក៏អាចប្រើសុភាសិតក្នុងសេចក្តីណែនាំសម្រាប់គ្រូជាជំនួយ)*។

❓ ពន្យល់សិស្សថា សុភាសិតទាំងនោះឆ្លុះបញ្ចាំងពីវប្បធម៌របស់យើង។ សួរសិស្សថា

- តើពួកគេគិតថាសុភាសិតទាំងនោះថ្មី ឬចាស់ ហើយវាមានប្រភពពីណា (ពួកវាដកស្រង់ពីក្រម និងច្បាប់ប្រុស/ស្រី - មើលសេចក្តីណែនាំសម្រាប់គ្រូ)។
- តើសុភាសិតទាំងនោះនៅមានឥទ្ធិពលក្នុងជីវិតប្រចាំថ្ងៃរបស់យើងទៀតដែរឬទេ ?

👄 ប្រាប់សិស្សថា ថ្ងៃនេះយើងនឹងពិនិត្យមើលពីរបៀបដែលវប្បធម៌ និងសុភាសិតទាំងនេះ មានឥទ្ធិពលលើអាកប្បកិរិយារបស់យើង ហើយយើងក៏នឹងពិភាក្សាផងដែរ តើខ្លឹមសារ/អត្ថន័យរបស់សុភាសិតទាំងនេះ មានទំនាក់ទំនងនឹងការគិត ការសម្រេចចិត្ត និងការប្រើប្រាស់ជីវិតរបស់យើងក្នុងសតវត្សរ៍ទី២១នេះ ដែរឬទេ ?

✋ ឱ្យសិស្សធ្វើការជាដៃគូ ហើយចែកសុភាសិតមួយទៅគ្រប់គូទាំងអស់។ គូមួយចំនួននឹងទទួលបានសុភាសិតដូចគ្នាដែលនិយាយអំពីអាកប្បកិរិយា ហើយគូខ្លះទៀតនិយាយអំពីទំនាក់ទំនងក្នុងគ្រួសារ។ ប្រសិនបើអាច សុភាសិតទាំងអស់ គួរត្រូវបានចែកទៅឱ្យសិស្សគ្រប់ៗគ្នា។

👄 ប្រាប់សិស្សថា លោក/អ្នកគ្រូចង់ឱ្យអ្នកទាំងអស់គ្នាគូររូបភាពមួយដែលឆ្លុះបង្ហាញពីអត្ថន័យរបស់សុភាសិតនោះក្នុងរយៈពេល១០នាទី។ ក្នុងន័យម្យ៉ាងទៀត គឺអាកប្បកិរិយាដែលសុភាសិតរំពឹងទុកពីបុរស នារី និង/ឬ ទំនាក់ទំនងរវាងឪពុកម្តាយជាមួយនឹងកូន។ សិស្សអាចគូររូបតែមួយផ្ទាំងជាមួយគ្នា ឬគូររូបពីរផ្ទាំងរៀងៗខ្លួន។ *(ទុកឱ្យពួកគេជាអ្នកជ្រើសរើស)*

❓ ខណៈដែលសិស្សកំពុងគូររូប គ្រូសរសេរសំណួរខាងក្រោមនេះ នៅលើក្តារខៀន៖

ក. តើសុភាសិតនេះមានឥទ្ធិពលលើជីវិតរបស់យើងដូចម្តេចខ្លះ ក្នុងរូបភាព ?

ខ. តើសុភាសិតនេះដាក់ការរំពឹងទុកអ្វីខ្លះមកលើជីវិតរបស់យើង ក្នុងរូបភាពនោះ ?

គ. តើនរណាដែលបានដាក់ការរំពឹងទុកនេះមកលើយើង ក្នុងរូបភាពនោះ ?

ឃ. តើការរំពឹងទុកនេះមានប្រភពមកពីណា?
ង. តើសុភាសិតមានឥទ្ធិពលលើជីវិតរបស់យើងដែរឬទេ? ដោយរបៀបណា?
ច. តើសុភាសិតនេះមានចំណុចវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះ?
ឆ. តើអ្នកចង់ផ្លាស់ប្តូរសុភាសិតដែរឬទេ? ដោយរបៀបណា?

ប្រាប់សិស្សថា ពួកគេនឹងបន្តទៅពិភាក្សាពីរបៀបដែលវប្បធម៌អាចប្រែប្រួល។ ឱ្យសិស្សពិនិត្យមើលគំនូររបស់ពួកគេ ហើយពិភាក្សាជាមួយដៃគូ ដោយប្រើសំណួរនៅលើក្តារខៀន។ *(គ្រូអាចដើរពិនិត្យមើល និងជួយជំរុញទឹកចិត្តសិស្ស ដែលពុំសូវពិភាក្សា)។ ទុកពេល ១០ នាទី សម្រាប់ការពិភាក្សា។*

បន្ទាប់ពីសិស្សពិភាក្សាចប់ ឱ្យដៃគូដែលពិភាក្សាវប្បធម៌មានឥទ្ធិពលលើអាកប្បកិរិយា ឡើងបង្ហាញពីលទ្ធផលនៃការពិភាក្សា ដល់សិស្សក្នុងថ្នាក់ទាំងមូលឯសិស្សដទៃទៀត អាចចូលរួមក្នុងការពិភាក្សា នៅពេលដែលសិស្សទាំងអស់បានផ្តល់ចម្លើយរបស់ពួកគេរួច។

- សួរសិស្សថា តើពួកគេឯកភាពជាមួយអ្វីដែលគ្នាយើងបានផ្លាស់ប្តូរសុភាសិតនោះដែរឬទេ។
- ប្រសិនបើគ្មានគូណាមួយធ្វើការកែប្រែសុភាសិតនោះទេ សួរពួកគេពីមូលហេតុ ដែលមិនផ្លាស់ប្តូរនេះ ហើយសួរសិស្សដទៃថា តើពួកគេឯកភាពឬទេ។ *(មើលសេចក្តីណែនាំសម្រាប់គ្រូ សម្រាប់ចំណុចសំខាន់ៗដែលអ្នកគួរបញ្ចូលក្នុងការពិភាក្សានេះ)*

បន្ទាប់មកឱ្យដៃគូដែលធ្វើការពិភាក្សាសុភាសិតដែលមានទំនាក់ទំនងនឹងចំណងទំនាក់ទំនង ដើម្បីធ្វើការបង្ហាញ។ ធ្វើដូចដំណើរការខាងលើ។ បន្តធ្វើរបៀបនេះអាស្រ័យលើពេលវេលា ដែលអ្នកមាន។ *(សិស្សដែលមិនបានបង្ហាញក្នុងថ្នាក់នឹងអាចផ្តល់គំនិតរបស់ពួកគេក្នុងផ្នែកនៃកិច្ចការផ្ទះ - មើលសកម្មភាពបន្ទាប់)*

## បញ្ចប់មេរៀន

១៥ នាទី

គ្រូប្រាប់សិស្សថា វាមានសារៈសំខាន់ក្នុងការចែករំលែកនូវអ្វីដែលអ្នកទាំងអស់គ្នាបានរៀនពីក្នុងមេរៀនថ្ងៃនេះ ដល់អ្នកដែលជុំវិញយើង។

កិច្ចការផ្ទះ៖ ពេលត្រឡប់ទៅផ្ទះវិញ

- ចូរចែករំលែកនូវអ្វី ដែលប្អូនៗបានរៀនអំពីសុភាសិត និងគំនិតដែលទទួលបានពីការពិភាក្សាអំពីរបៀបដែលវប្បធម៌អាចជះឥទ្ធិពលលើជីវិតរស់នៅរបស់យើង និងរបៀបដែលវាអាចប្រែប្រួលជាមួយនឹងការផ្លាស់ប្តូរក្នុងសង្គមដល់អ្នកនៅជុំវិញ។
- សួរឪពុកម្តាយឬអាណាព្យាបាលរបស់ប្អូនៗ ថាវប្បធម៌ដែលបានផ្លាស់ប្តូរក្នុង រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ តើពួកគាត់គិតថា ការផ្លាស់ប្តូរទាំងនោះល្អ ឬអាក្រក់? ហេតុអ្វី?

ប្រាប់សិស្ស ឱ្យកត់ត្រាចូលក្នុងសៀវភៅរបស់ពួកគេ នូវអ្វីដែលពួកគេបានរៀនពីមេរៀនថ្ងៃនេះ និងអ្វីដែលពួកគេត្រូវធ្វើពេលត្រឡប់ទៅផ្ទះវិញ។ ជួបគ្នាពេលក្រោយ យើងនឹងជជែកគ្នាពីបញ្ហានេះ។

# សេចក្តីណែនាំសម្រាប់គ្រូ

ចំណុចសំខាន់សម្រាប់គ្រូ គួរអានមុនពេលបង្រៀន៖

- វប្បធម៌ដុសខាត់ជំនឿ គុណតម្លៃ និងអាកប្បកិរិយា។
- វប្បធម៌របស់យើងត្រូវបានផ្ទេរពីមួយជំនាន់ទៅមួយជំនាន់ តាមរយៈគ្រួសាររបស់យើង សហគមន៍របស់យើង ស្ថាប័នអប់រំក្នុងសង្គមរបស់យើង ដូចជាសាលារៀន វត្តអារាម។
- មនុស្សវ័យក្មេងទទួលរងឥទ្ធិពលនៃវប្បធម៌ភ្លាមៗ បន្ទាប់ពីពួកគេបានកើត និងអំឡុងពេល ដែលពួកគេធំដឹងក្តី។
- សង្គមផ្លាស់ប្តូរ វប្បធម៌ប្រែប្រួល។ ឧទាហរណ៍ កាលពី២០ឆ្នាំមុន សង្គមភាគច្រើនត្រូវផ្លាស់ប្តូរ ដើម្បីសម្របតាមពិភពលោកសម័យថ្មី ដែលជាសម័យទំនាក់ទំនងបច្ចេកវិទ្យាជុំវិញពិភពលោក និងប្រើវិធីថ្មីៗក្នុងការរកចំណូល។
- មានភាពចាំបាច់ដែលត្រូវចងចាំថា វប្បធម៌របស់យើងឆ្លុះបញ្ចាំងពីគុណតម្លៃ និងជំនឿរបស់យើង។ មនុស្សក្នុងសង្គមខុសៗគ្នា អាចមានគុណតម្លៃ និងជំនឿដូចគ្នា ប៉ុន្តែក៏មានភាពខុសគ្នាផងដែរ អាស្រ័យលើការជះឥទ្ធិពលពីគ្រួសារ និងស្ថាប័នអប់រំក្នុងសង្គម ដែលពួកគេធំដឹងក្តីមកជាមួយ។

តេស្តសាកល្បងមុនវគ្គសិក្សា៖

- គោលបំណងរបស់តេស្តនេះគឺដើម្បីវាស់ស្ទង់ពីគំនិត និងចំណេះដឹងដែលសិស្សទទួលបានពី វគ្គសិក្សា។ ដូច្នេះ គ្រូគួរតែរក្សាទុកនូវចម្លើយរបស់សិស្សក្នុងតេស្តសាកល្បងមុខវគ្គនេះឱ្យបានល្អ ដើម្បីធ្វើការប្រៀបធៀបចម្លើយជាមួយនឹងតេស្តបញ្ចប់វគ្គ។
- តេស្តសាកល្បងក្នុងមេរៀនទីមួយនេះមិនមានចម្លើយទេ ប៉ុន្តែតេស្តក្នុងមេរៀនទី១០ មានដាក់បញ្ចូលនូវចំណុចសំខាន់ៗដែលសិស្សគួរសរសេរចូល។ ចំណុចទាំងអស់នោះគួរត្រូវបានបង្រៀនក្នុងមេរៀនបំណិនជីវិត។
- អ្នកអាចថតចម្លងក្រដាសសំណួរនេះហើយចែកទៅឱ្យសិស្ស ឬក៏ឱ្យសិស្សសរសេរវានៅលើក្រដាសដែលអ្នកអាចប្រមូលបាន។ វាមានសារៈសំខាន់ដែលអ្នកត្រូវរំលឹកពួកគេថា ពួកគេ នឹងធ្វើតេស្តដូចគ្នានេះនៅចុងបញ្ចប់វគ្គ។ ដូច្នេះ ពួកគេនិងអ្នកអាចមើលឃើញពីកម្រិតអភិវឌ្ឍន៍ចំណេះដឹងរបស់ពួកគេចំពោះប្រធានបទ។ ចូរបញ្ជាក់ពួកគេថា នេះគ្រាន់តែជាដំណើរការសិក្សា ដូច្នេះពួកគេមិនគួរមានអារម្មណ៍ភ័យព្រួយក្នុងការធ្វើតេស្តនេះឡើយ។

ការពិភាក្សាអំពីវប្បធម៌៖

- អំឡុងពេលសិក្សាត្រូវដឹកនាំសិស្សដោយសួរសំណួរ និងផ្តល់ព័ត៌មានបន្ថែមរួមទាំង៖
  - ឱ្យពួកគេធ្វើការពិចារណាចំពោះផ្នែកផ្សេងៗក្នុងជីវិតរបស់យើងដែលរងឥទ្ធិពលដោយវប្បធម៌ ភាសា សម្លៀកបំពាក់ អាហារ ពិធីបុណ្យ ជំនឿសាសនា ជីវភាពរស់នៅ និងការងាររបស់យើង។
  - ឱ្យពួកគេក្រឡេកមើលការផ្លាស់ប្តូរដែលកើតមានចំពោះអ្វីទាំងអស់នោះ ក្នុងរយៈពេល២០ឆ្នាំ កន្លងមកនេះ។ ឧទាហរណ៍៖ សម្លៀកបំពាក់ អាហារ និងជីវភាពរស់នៅ។ តើវាមានការផ្លាស់ប្តូរអ្វីខ្លះ?
  - អាហារ៖ រងឥទ្ធិពលពីប្រទេសដទៃ និងជនបរទេសដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ជាពិសេសគឺនៅទីក្រុង។
  - សម្លៀកបំពាក់៖ ទទួលរងដោយឥទ្ធិពលពិភពលោកតាមរយៈអ៊ីនធើណេតតាមរយៈនាំអារ្យធម៌មកពីបរទេស និងតាមរយៈរោងចក្រអន្តរជាតិដែលដំណើរការនៅទីនេះ។
  - ជីវភាពរស់នៅ និងការងារ៖ រងឥទ្ធិពលដោយការប្រែប្រួលក្នុងផ្នែកសេដ្ឋកិច្ចមានអ្នកធ្វើការផ្លាស់ប្តូរពី

កន្លែងមួយទៅកន្លែងមួយជាច្រើន មានឱកាសការងារកាន់តែច្រើនតាមរយៈការវិនិយោគបរទេស។ ការងាររោងចក្រ មានន័យថា មនុស្សកាន់តែច្រើនទៅទីក្រុង និងចាកចេញពីជនបទ...។ល។

- នៅពេលសិស្សចងក្រងនិយមន័យរបស់វប្បធម៌ នៅចុងបញ្ចប់នៃសកម្មភាពនេះត្រូវប្រាកដថាចំណុចខាងក្រោមត្រូវបានដាក់បញ្ចូលៈ
  - ▶ វប្បធម៌គឺជាជំនឿ គុណតម្លៃ និងទម្លាប់ប្រពៃណីដែលស្តែងចេញតាមរយៈអាកប្បកិរិយាទាំងឡាយណាដែលយើងរៀនចេះពីឪពុកម្តាយ សហគមន៍ និងស្ថាប័ន សង្គមរបស់យើងដែលមានដូចជា រដ្ឋាភិបាល សាលារៀន វត្តអារាម...។ល។ គំនិត និងការយល់ឃើញទាំងនោះត្រូវបានផ្ទេរពីមួយជំនាន់ទៅមួយ ជំនាន់ ហើយជួយយើង ឱ្យមានអារម្មណ៍ថាជាកម្មសិទ្ធិរបស់សង្គមឬសហគមន៍របស់យើង។
  - ▶ វប្បធម៌នឹងមានភាពខុសប្លែកគ្នាពីសង្គមមួយទៅសង្គមមួយទៀត អាស្រ័យលើអ្វីដែលសង្គមនោះផ្តល់តម្លៃឱ្យ។ គុណតម្លៃរបស់យើងបញ្ជាក់នូវអ្វីដែលយើងជឿថា ល្អឬអាក្រក់ សមរម្យឬមិនសមរម្យ ធម្មតាឬមិនធម្មតា។ នេះមានន័យថា វប្បធម៌ត្រូវបានបង្កើតនិងអភិវឌ្ឍឡើងដោយសង្គមមិនមែនជាផ្នែកធម្មជាតិរបស់យើងដែលកើតមកជាមួយនោះទេ។
  - ▶ ដូច្នេះហើយ វប្បធម៌មិននៅនឹងដដែលនោះទេ វាផ្លាស់ប្តូរទៅតាមបម្រែបម្រួល របស់ពិភពលោក និងរបៀបដែលវាប៉ះពាល់ដល់សង្គមរបស់យើង។ ឧទាហរណ៍ៈ បច្ចេកវិទ្យាថ្មីៗ និងស្ថានភាពសេដ្ឋកិច្ចថ្មីៗនាំឱ្យមានការផ្លាស់ប្តូរផ្សេងៗទាក់ទងនឹងអាកប្បកិរិយារបស់យើងដែលបណ្តាលឱ្យជំនឿ និងទំនៀមទំលាប់របស់មនុស្សមានការប្រែប្រួល។

ការពិភាក្សាអំពីវប្បធម៌និងការផ្លាស់ប្តូរៈ

- "ច្បាប់ក្រម "ឬ" ក្រមនៃភាពគួរសម" បង្រៀនកូនខ្មែរឱ្យមានភាពស្លូតបូត មានការគោរព និង ការទទួលយកការគ្រប់គ្រង។
- "ច្បាប់ប្រុស/ស្រី" ឬ "ក្រមនៃការប្រព្រឹត្តរបស់បុរស/នារី" លើកតម្កើនបុរស ហើយបង្រៀនមនុស្សស្រីឱ្យធ្វើខ្លួនអ្នកក្រោមបង្គាប់។
  - ▶ ស៊ូស្រក់ឈាម មិនស្រក់ទឹកភ្នែក។ (អាកប្បកិរិយាៈ បុរសមិនគួរបង្ហាញពីអារម្មណ៍ទន់ខ្សោយ - គ្រាន់តែភាពក្លាហាន)
  - ▶ មនុស្សស្រីបង្វិលចង្ក្រានមិនជុំ។ (អាកប្បកិរិយាៈ ទីកន្លែងរបស់មនុស្សស្រីគឺចង្ក្រាន បាយក្នុងផ្ទះ)
  - ▶ មនុស្សប្រុសចូលចង្ក្រាន និងធ្វើការងារផ្ទះ ជាមនុស្សអន់ខ្សោយ។ (អាកប្បកិរិយាមនុស្សប្រុសមានតួនាទីផ្សេង ហើយមនុស្សស្រីក៏មានតួនាទីផ្សេងដែរ មិនអាចចែករំលែកបានទេ)
  - ▶ មនុស្សប្រុសជាមាសទឹកដប់ មនុស្សស្រីជាក្រណាត់ស។ (អាកប្បកិរិយាៈ មនុស្សស្រី អន់ជាងមនុស្សប្រុស ហើយគួរតែប្រព្រឹត្តខ្លួនជាអ្នកក្រោមបង្គាប់)
  - ▶ ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់។ (ទំនាក់ទំនងៈ កូនៗគួរនៅជិតឪពុកម្តាយរបស់ពួកគេ)
  - ▶ ឪពុកម្តាយឃើញពន្លឺព្រះអាទិត្យមុន អញ្ចឹងកូនគួរតែគោរពតាមអ្វីដែលឪពុកម្តាយ ប្រាប់។ (ទំនាក់ទំនងៈ កូនគឺនៅក្រោមបង្គាប់ឪពុកម្តាយ)
  - ▶ នំមិនដែលធំជាងនាឡិ។ (ទំនាក់ទំនងៈ កូនស្រីត្រូវស្តាប់តាមបង្គាប់របស់ឪពុកម្តាយ)
  - ▶ កុំឱ្យកូនស្រីបោដោះយូរដូចកូនប្រុស ព្រោះពេលនាងធំឡើង នាងនឹងទៅជាមនុស្សរឹងរូស។ (ទំនាក់ទំនងៈ ការរំពឹងទុកដែលក្មេងប្រុសគួរទទួលបានការយកចិត្តទុកដាក់ និងថែរក្សាជាងក្មេងស្រី)

- អំឡុងពេលពិភាក្សា ចូរលើកឡើងពីចំណុចខាងក្រោម៖
  - រំលឹកសិស្សថា សុភាសិតខ្លះឆ្លុះបញ្ចាំងពីវប្បធម៌របស់យើង ហើយវប្បធម៌ក៏កើតឡើង ដោយសារសង្គមដែរ។
  - ពិភាក្សាពីភាពខុសប្លែកគ្នារវាងអាកប្បកិរិយាដែលត្រូវបានរំពឹងទុកសម្រាប់បុរស និងនារីប្រព្រឹត្តដោយយោងតាមសុភាសិត។ តើវាត្រឹមត្រូវឬទេ? តើអ្នកពិតជាជឿជាក់ថា បុរសមិនគួរយំ ហើយមនុស្សស្រីគួរតែនៅផ្ទះ? តើរូបភាពនេះសម្របនឹងរបៀបរស់នៅក្នុងជីវិតរបស់យើងនាពេលអនាគតដែរឬទេ? ហេតុអ្វីមិនដូច្នេះ? តើអាកប្បកិរិយារបស់បុរស និងនារីមានការផ្លាស់ប្តូរយ៉ាងដូចម្តេចខ្លះដែលយើងមានក្នុងសង្គមរបស់យើង?
  - ពិភាក្សាពីសុភាសិតដែលឆ្លុះបញ្ចាំងពីទំនាក់ទំនងជាមួយឪពុកម្តាយ។ តើការប្រែប្រួលក្នុងសង្គមបានផ្លាស់ប្តូរទំនាក់ទំនងដែលយើងមានជាមួយឪពុកម្តាយនាពេលបច្ចុប្បន្នយ៉ាងដូចម្តេចខ្លះ?
  - អ្វីដែលសំខាន់បំផុតដើម្បីរំលឹកសិស្សថា ពួកគេជាអ្នកជំនាន់ក្រោយ ហើយពួកគេជាអ្នកដុសខាត់វប្បធម៌របស់កម្ពុជានាពេលអនាគត។ ប៉ុន្តែបញ្ជាក់ថា ទោះបីជាយើងជាផ្នែកមួយរបស់សង្គមក៏ដោយ ក៏យើងនៅតែជាបុគ្គលដាច់ដោយឡែក ដែលត្រូវធ្វើការសម្រេចចិត្តលើតម្រូវការ និងចំណង់របស់យើង។ ទោះជាតម្រូវការ និងចំណង់ទាំងនោះមិនត្រូវតាមការរំពឹងទុករបស់វប្បធម៌ក្នុងសង្គមក៏ដោយ។

តេស្តសាកល្បងមុនវគ្គ

១. តើវប្បធម៌ជាអ្វី? តើមនុស្សវ័យក្មេងទទួលជំនឿ និងទម្លាប់ពីវប្បធម៌ដោយរបៀបណា?

២. តើអ្វីជាភាពខុសប្លែកគ្នារវាងភេទ និងយេនឌ័រ?

៣. តើមានចរិតលក្ខណៈអ្វីខ្លះ ដែលសង្គម គ្រួសារ និងមិត្តភក្តិបង្រៀនដល់ក្មេងស្រី/ស្ត្រី?

៤. តើមានចរិតលក្ខណៈអ្វីខ្លះ ដែលសង្គម គ្រួសារ និងមិត្តភក្តិបង្រៀនដល់ក្មេងប្រុស/បុរស?

៥. តើអ្នកគិតថាអ្នកណាដែលគួរធ្វើកិច្ចការ "សំអាតផ្ទះ"។ ចូរផ្តល់ហេតុផលចំពោះចម្លើយដែលអ្នកបានជ្រើសរើសខាងក្រោម។

ក. ភាគច្រើនបុរស ខ. ភាគច្រើនស្ត្រី គ. ទាំងពីរ

តើអ្នកគិតថាអ្នកណាដែលគួរធ្វើកិច្ចការ "រកប្រាក់ចំណូលក្នុងគ្រួសារ"។ ចូរផ្តល់ហេតុផលចំពោះចម្លើយដែលអ្នកបានជ្រើសរើសខាងក្រោម។

ក. ភាគច្រើនបុរស ខ. ភាគច្រើនស្ត្រី គ. ទាំងពីរ

៦. តើអ្នកអាចផ្តល់ឧទាហរណ៍មួយអំពីផ្នត់គំនិតយេនឌ័រ និងឧទាហរណ៍មួយទៀតអំពីការរើសអើងយេនឌ័រនៅកន្លែងធ្វើការ?

៧. អ្នកអាចផ្តល់ឧទាហរណ៍ស្តីពីផ្នត់គំនិតយេនឌ័រ និងការរើសអើងកើតឡើងនៅតែក្នុងក្នុងប្រទេសដទៃទៀតដែរ?



# មេរៀនទី ២: ភេទ និងយេនឌ័រ

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ក្ដារខៀន ដីស
- ផ្ទាំងក្រដាសធំ ហ្វឺតចំរុះពណ៌ ឬគូល័រទៀន
- ក្រដាសពណ៌កាត់ជារាងការេតូចៗ និង ស្កុត

☼ លទ្ធផលរំពឹងទុក

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច

- ពន្យល់ពីភាពខុសគ្នារវាង ភេទ និងយេនឌ័រ
- ពន្យល់ពីវប្បធម៌លើការដឹងឮអំពីយេនឌ័រក្នុងសង្គម
- រៀបរាប់អំពីរបៀបដែលវប្បធម៌អាចផ្លាស់ប្ដូរពីមួយជំនាន់ទៅមួយជំនាន់

## សេចក្ដីផ្ដើមៈ ចំណងទំនាក់ទំនងរវាងមនុស្ស

🕑 ១៥ នាទី

◈ រំលឹកមេរៀនចាស់ និងគ្រូគួតពិនិត្យកិច្ចការផ្ទះកាលពីសប្ដាហ៍មុន។ តើពួកគេបានរៀនអ្វីខ្លះកាលពីមេរៀនមុន? គ្រូឱ្យសិស្សផ្ដល់យោបល់អំពីអ្វីដែលពួកគេបានរៀនពីឪពុកម្ដាយឬអាណាព្យាបាល និងសមាជិកសហគមន៍ អំពីវប្បធម៌។

✋ ព្យួររូបភាពផ្ទាំងធំ " ដប់ដងត្រូវ? ឬដប់ដងខុស?" នៅលើក្ដារខៀន។

👄 ពន្យល់ប្រាប់សិស្សថា៖ ថ្ងៃនេះយើងនឹងជជែកគ្នាពីភាពខុសគ្នារវាងក្មេងប្រុស និងក្មេងស្រី និងការទទួលខុសត្រូវរបស់ពួកគេ។ ដូច្នេះ យើងនឹងលេងល្បែងតូចមួយជាមួយគ្នា។ នៅម្ខាងនៃថ្នាក់នេះ គឺ ផ្នែកយល់ស្រប និងម្ខាងទៀតគឺផ្នែកមិនយល់ស្រប។ ដូចនេះ នៅពេលខ្ញុំអាន ឬចង្អុលប្រយោគនៅលើផ្ទាំងរូបភាព អ្នកទាំងអស់គ្នាត្រូវសម្រេចចិត្តទៅខាងយល់ព្រម ឬមិនយល់ព្រម។

✋ លេងល្បែងនេះ រហូតដល់បញ្ចប់ទាំង១០ ប្រយោគ។ ពេលបញ្ចប់ប្រយោគនីមួយៗ គ្រូត្រូវសួរពីមូលហេតុ៖ ហេតុអ្វីគេឯកភាព ឬមិនឯកភាព។

✏ សរសេរពាក្យ "ភេទនិង យេនឌ័រ - ដូចគ្នាឬខុសគ្នា?" នៅលើក្ដារខៀន។

◈ តើសិស្សទាំងអស់ធ្លាប់ឮពាក្យថា ភេទ និងយេនឌ័រ ដែរឬទេ? ភេទសំដៅលើអ្វី? យេនឌ័រមានន័យដូចម្ដេច?

## សកម្មភាពសំខាន់។

៦៥ នាទី

**ភេទ និង យេនឌ័រ - ដូចគ្នាឬខុសគ្នា?**

គ្រូបិទផ្ទាំងរូបភាពរូបរាងរបស់មនុស្សប្រុស និងមនុស្សស្រី ហើយឱ្យសិស្សរៀបរាប់ពីចរិត លក្ខណៈរបស់នារី/ក្មេងស្រី និងបុរស/ក្មេងប្រុស។ ឧទាហរណ៍៖ ប្រភេទនៃតួនាទីដែលពួកគេមានក្នុងសង្គម ជំនាញ អាកប្បកិរិយា អារម្មណ៍ ឥរិយាបថ ការងារ រូបរាង...។ល។ អ្វីគ្រប់យ៉ាងដែល អ្នកគិតថា បុរស/ក្មេងប្រុស ខុសពីស្ត្រី/ក្មេងស្រី។ *(អ្នកគ្រូ/លោកគ្រូគ្រាន់តែចង់បានឧទាហរណ៍ពីរ ឬបីប៉ុណ្ណោះ ដើម្បីឱ្យច្បាស់ថា សិស្សយល់នូវអ្វីដែលត្រូវធ្វើ។)*

សរសេរឧទាហរណ៍មួយ ឬពីរនៅលើក្តារខៀន នៅជិតរូបភាពបុរស ឬនារី។

បន្ទាប់មកប្រាប់សិស្សថា ពួកគេនឹងមានការប្រកួតប្រជែងមួយ។ គ្រូចែកជាពីរក្រុម សិស្សស្រីមួយក្រុម ហើយសិស្សប្រុសនៅមួយក្រុម រួចផ្តល់ប័ណ្ណពណ៌ទៅក្រុមទាំងពីរ។ ប័ណ្ណគួរតែមានពណ៌ខុសគ្នាសម្រាប់ក្រុមទាំងពីរ។ នៅលើប័ណ្ណសិស្សស្រី ត្រូវសរសេរពីចរិត លក្ខណៈដែលសម្គាល់ថាបុរសឬក្មេងប្រុសឱ្យបានច្រើនបំផុតតាមតែអាចធ្វើបាន។ ចំណែកឯសិស្សប្រុសត្រូវសរសេរពីចរិតលក្ខណៈរបស់នារីឬក្មេងស្រីឱ្យបានច្រើនបំផុតតាមតែអាចធ្វើបាន។ ប័ណ្ណមួយអាចសរសេរបានមួយគំនិត។ ប្រាប់ពួកគេថា ពួកគេមានរយៈពេល១៥នាទីសម្រាប់កិច្ចការនេះ ហើយនៅពេលបញ្ចប់ អ្នកគ្រូ/លោកគ្រូ នឹងពិនិត្យមើលថា តើក្រុមណាមានប័ណ្ណច្រើនជាងគេ។ ពួកគេអាចបិទប័ណ្ណ ដែលសរសេររួចទៅតាមរូបភាពបុរស/ស្ត្រី ដែលមាននៅលើក្តារខៀន។

ខណៈដែលសិស្សកំពុងសរសេរនៅលើប័ណ្ណ គ្រូត្រូវដើរពិនិត្យមើលតាមក្រុម ដើម្បីឱ្យប្រាកដថា សិស្សនឹងមិនមើលត្រឹមតែភាពខុសគ្នានៃរាងកាយ។ លើកទឹកចិត្តពួកគេឱ្យគិតពីតួនាទីបុរស និងស្ត្រី ឬអាកប្បកិរិយា ដែលកំណត់ដោយសង្គម និងអារម្មណ៍ជាមួយគ្រួសារ ឬសង្គម.... ។

បន្ទាប់ពី១៥នាទីកន្លងផុតទៅ បញ្ឈប់សកម្មភាព ហើយឱ្យសិស្សរាប់ចំនួនប័ណ្ណរបស់ពួកគេ។ ក្រុមដែលមានចំនួនតិចជាងគេ ត្រូវឡើងមកអានចម្លើយរបស់ពួកគេ។ ក្រុមបន្ទាប់ធ្វើដូចគ្នា។ *(លើកទឹកចិត្តសិស្សឱ្យទះដៃលើកទឹកចិត្តឱ្យគ្នាទៅវិញទៅមក)*

ប្រាប់សិស្សថា យើងនឹងមើលចរិតលក្ខណៈដែលពួកគេបានសរសេរនៅលើក្តារខៀន ហើយធ្វើការសម្រេចថាមួយណាជាលក្ខណៈធម្មជាតិ និងមួយណាជាលក្ខណៈវប្បធម៌។

គ្រូសរសេរពាក្យ "ធម្មជាតិ/ជីវសាស្ត្រ" និង "វប្បធម៌/សង្គម" នៅលើក្តារខៀន។

គ្រូគពិនិត្យការយល់ដឹងពីពាក្យនេះ *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។ គ្រូសួរសិស្ស៖ តើ យើងអាចផ្លាស់ប្តូរចរិតលក្ខណៈធម្មជាតិ/ជីវសាស្ត្របានដែរឬទេ? តើយើងអាចផ្លាស់ប្តូរចរិតលក្ខណៈសង្គម/វប្បធម៌បានដែរឬទេ? *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*

សិស្សធ្វើការពិនិត្យមើលប័ណ្ណសម្រាប់ចរិតលក្ខណៈរបស់មនុស្សស្រីមុន។ ដាក់ប័ណ្ណនៅខាងក្រោមពាក្យ "ធម្មជាតិ/ជីវសាស្ត្រ" ឬ "វប្បធម៌/សង្គម" ក៏បាន។ ពិភាក្សាពីប័ណ្ណនីមួយៗដើម្បី ឱ្យប្រាកដថា សិស្សផ្តល់មូលហេតុសម្រាប់ជម្រើសរបស់ពួកគេ។ នៅពេលពួកគេបានបញ្ចប់ជាមួយចរិតលក្ខណៈរបស់មនុស្សស្រី ធ្វើដូចគ្នាដែរចំពោះចរិតលក្ខណៈរបស់មនុស្សប្រុស។

សួរសិស្សពីចំណងជើងនៃមេរៀនថ្ងៃនេះ។ *(ភេទ និងយេនឌ័រ - ដូចគ្នាឬខុសគ្នា?)*

សួរសិស្សថាតើពាក្យមួយណាដែលទាក់ទងនឹងចរិតលក្ខណៈធម្មជាតិ/ជីវសាស្ត្រ ហើយពាក្យមួយណាដែលទាក់ទងនឹងចរិតលក្ខណៈវប្បធម៌/សង្គម។ អាស្រ័យតាមការពិភាក្សារបស់សិស្ស ឱ្យពួកគេពន្យល់ពីភាពខុសគ្នារវាង ភេទ និង យេនឌ័រ *(ប្រើប្រាស់ចំណុចដូចគ្នានឹងសេចក្តីណែនាំសម្រាប់គ្រូដើម្បីជួយបង្កើនការយល់ដឹងរបស់ពួកគេ)*។

✋ បន្ទាប់មក ផ្តល់ឯកសារសម្រាប់សិស្សដែលពន្យល់អំពីនិយមន័យរបស់ពាក្យ ភេទ និងយេនឌ័រ។

ឱ្យសិស្សអានវាដោយស្ងាត់ស្ងៀម។ នៅចុងបញ្ចប់នៃការអាន ពួកគេអាចសួរសំណួរ បាន ប្រសិនបើពួកគេមិនច្បាស់ពីអ្វីមួយ។ *(ប្រសិនបើអ្នកមិនអាចថតចម្លងឯកសារសម្រាប់សិស្សបានទេ អ្នកអាចចម្លងទៅលើផ្ទាំងក្រដាសធំ ហើយឱ្យកត់ត្រាទុកក្នុងសៀវភៅរបស់ពួកគេ។ ពួកគេត្រូវការពេលវេលាបន្ថែមដើម្បីធ្វើកិច្ចការនេះ អ្នកមិនគួរបង្ខំពួកគេ។)*

**ការរំពឹងទុកតួនាទីយេនឌ័រ និងផ្នត់គំនិតយេនឌ័រ**

? សួរសិស្សថាតើពួកគេបានចាប់ផ្តើមគិតអំពីអ្វីដែលពួកគេចង់ធ្វើ ឬចង់ក្លាយទៅជានៅពេល ដែលពួកគេបញ្ចប់ការសិក្សា។

- ឱ្យសិស្សផ្តល់គំនិតមួយចំនួនអំពីអ្វីដែលពួកគេនឹងធ្វើ នៅពេលដែលពួកគេបញ្ចប់ការ សិក្សា។
- បន្ទាប់មក ឱ្យពួកគេកត់ត្រាប្រយោគខាងក្រោមដែលមានសរសេរនៅលើក្តារខៀនទុក ក្នុងសៀវភៅរបស់ពួកគេ។ ពួកគេមិនចាំបាច់កត់ត្រាពាក្យក្នុងវង្វង់ក្រចកទេ។

✎ *(អ្នកសរសេរប្រយោគទាំងនោះ ពេលសិស្សកំពុងអាននិយមន័យរបស់ភេទ និងយេនឌ័រ ក្នុងសកម្មភាពមុន)*។

ក) នៅពេលខ្ញុំបញ្ចប់ការសិក្សា ខ្ញុំនឹង... (តើអ្នកគិតថាអ្នកនឹងធ្វើអ្វីនៅពេលបញ្ចប់ការសិក្សា?)

ខ) ប្រសិនបើខ្ញុំមានភេទផ្ទុយពីនេះ ខ្ញុំគិតថាខ្ញុំនឹង... (តើអ្នកគិតថាអ្នកនឹងធ្វើអ្វីនៅពេលបញ្ចប់ការសិក្សា ប្រសិន បើមានភេទផ្ទុយពីនេះ?)

ពិនិត្យការយល់ដឹងពីប្រយោគទាំងនោះ និងអ្វីដែលពួកគេត្រូវធ្វើ (មើលសេចក្តីណែនាំសម្រាប់គ្រូ)។ ទុកពេល ៥ ទៅ ៨ នាទីសម្រាប់កិច្ចការនេះ។

✎ គ្រូគូរតារាងខាងក្រោមនៅលើក្តារខៀន *(អ្នកអាចគូរវាខណៈដែលសិស្សកំពុងបំពេញប្រយោគរបស់ពួកគេ)*។

| ចម្លើយរបស់ក្រុមក្មេងស្រី | | ចម្លើយរបស់ក្រុមក្មេងប្រុស | |
|---|---|---|---|
| ជាមនុស្សស្រី | ជាមនុស្សប្រុស | ជាមនុស្សស្រី | ជាមនុស្សប្រុស |
| សំអាងការ<br>....... | IT<br>...... | គ្រូបង្រៀន<br>..... | វិស្វករ<br>ជាងម៉ូតូ |

● នៅពេលដែលពួកគេបញ្ចប់ប្រយោគរបស់ពួកគេ ឱ្យពួកគេចូលជាក្រុមដែលមានគ្នាតែសមាជិកស្រី ឬប្រុស។ ក្នុងក្រុមនិមួយៗ ត្រូវបង្កើតជាបញ្ជីតារាងមួយដែល ពួកគេគិតថា ពួកគេនឹងធ្វើ យោងតាមភេទដែលពួកគេមាននាពេលបច្ចុប្បន្ននេះ និងអ្វីដែលពួកគេនឹងធ្វើ ប្រសិនបើពួកគេមានភេទផ្ទុយពីនេះ។ ទុកពេល១០នាទីសម្រាប់ការងារនេះ។

● ឱ្យក្រុមដែលមានសមាជិកនារី ផ្តល់មតិយោបល់អំពីប្រភេទសកម្មភាពដែលពួកគេមានក្នុងប្រអប់ "ជាមនុស្សស្រី" ហើយក្នុងប្រអប់ "ជាមនុស្សប្រុស"។ ឱ្យក្រុមមួយដែលមានសមាជិកនារីផ្សេងទៀតបន្ថែមទៅក្នុងតារាង ប្រសិនពួកគេមានអ្វីខុសប្លែកគ្នា។ ធ្វើដូចគ្នាសម្រាប់ក្មេងប្រុស។

● ឱ្យសិស្សមើលភាពខុសៗគ្នា អំពីសកម្មភាពដែលត្រូវកំណត់សម្រាប់បុរសនិងនារី។ ចាប់ផ្តើមការពិភាក្សាពីមូលហេតុដែលនៃភាពខុសប្លែកគ្នារវាងដែលពួកគេបានលើកឡើង ។

◈ ប្រើសំណួរខាងក្រោម ដើម្បីជួយលោកគ្រូ/អ្នកគ្រូ ក្នុងការដឹកនាំការពិភាក្សា៖

ក) តើមនុស្សស្រី/ប្រុសត្រូវតែក្លាយជា/ធ្វើអ្វីដែលអ្នកបានសរសេរ?

ខ) តើនរណា ឬអ្វីដែលបាននិយាយដូច្នេះ?

គ) តើមនុស្សប្រុស/ស្រីអាចធ្វើអ្វីដូចគ្នានឹងភេទមនុស្សដែលមានផ្ទុយគ្នាដែរឬទេ?

ឃ)តើការរំពឹងទុករបស់សង្គមអំពីតួនាទី និងទំនួលខុសត្រូវរបស់យើងមានផលប៉ះពាល់ដល់ជម្រើសជីវិតរបស់យើងដោយរបៀបណា?

*(មើលសេចក្តីណែនាំសម្រាប់គ្រូ សម្រាប់ជាការណែនាំនៅចំណុចសំខាន់ក្នុងការពិភាក្សា)*។ នៅពេលអ្នកបញ្ចប់ការពិភាក្សានេះ ឱ្យសិស្សកត់ត្រា និងបំពេញប្រយោគខាងក្រោមក្នុងសៀវភៅរបស់ពួកគេ៖

ក) នៅពេលដែលខ្ញុំបញ្ចប់ការសិក្សា

◈ សួរសិស្សថាតើពួកគេនៅតែមានចម្លើយដូចកាលពីលើកមុន ឬក៏មានខុសពីពេលមុន។ ប្រសិនបើពួកគេចង់ អ្នកឱ្យសិស្សមួយចំនួនចែករំលែកចម្លើយរបស់ពួកគេ។

## បញ្ចប់មេរៀន

◷ ១០ នាទី

ពន្យល់ប្រាប់សិស្សថា វាមានសារៈសំខាន់ដើម្បីធ្វើការឆ្លុះបញ្ចាំងពីអ្វីដែលពួកគេបានរៀនពីក្នុងមេរៀនថ្ងៃនេះ ដោយការប្រើប្រាស់ចំណេះដឹងរបស់ពួកគេក្នុងស្ថានភាពជីវិតជាក់ស្តែង។

✎ កិច្ចការផ្ទះ៖

◈ ពេលអ្នកទាំងអស់គ្រឡប់ទៅផ្ទះ ចូរជ្រើសរើសសកម្មភាពមួយ ឬពីរ ដែលសមាជិកគ្រួសារអាចចូលរួមបាន ដូចជា៖ ការចម្អិនអាហាររួមគ្នា ការសម្អាត ការថែរក្សាក្មេងៗ...។ល។

● សិស្សត្រូវសង្កេតពីអាកប្បកិរិយាដែលពួកគាត់(សមាជិកក្នុងគ្រួសារ ឬសហគមន៍) បានបង្ហាញឬប្រព្រឹត្តនៅពេលដែលពួកគាត់ធ្វើសកម្មភាពទាំងនោះ។

● រួចកត់ត្រាចំណុចនូវអាកប្បកិរិយា/ការគិត របស់អ្នកទាំងនោះដាក់ចូលក្នុងសៀវភៅ។

● បន្ទាប់មក ឱ្យពួកគេគិតថាតើវិធីដែលមនុស្សនោះប្រព្រឹត្តគឺជាលទ្ធផលនៃធម្មជាតិ/ភេទ ឬ វប្បធម៌/យេនឌ័រ។

● ប្រាប់សិស្សថា ពួកគេអាចនិយាយប្រាប់នៅសប្តាហ៍ក្រោយ។

# សេចក្ដីណែនាំសម្រាប់គ្រូ

● តួនាទី និងការប្រព្រឹត្តជាច្រើនរបស់យើងដែលជាមនុស្សប្រុស និងមនុស្សស្រីគឺបានមកពីផ្នែកធម្មជាតិ និងផ្នែកវប្បធម៌។ មនុស្សស្រីមានផ្ទៃពោះ កើតកូន និងបំបៅដោះ គឺជាកត្តាធម្មជាតិ។ បុរសមិនអាចមានផ្ទៃពោះ កើតកូន ឬបំបៅដោះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏តួនាទីដែលផ្ដល់ឱ្យមនុស្សស្រីគឺជា "ម្ដាយ" ដែលនៅផ្ទះ និងមើលថៃគ្រួសារ គឺជាការបង្កើតឡើង ដោយសង្គមតាមរយៈឥទ្ធិពលវប្បធម៌។ បុរសក៏អាចនៅផ្ទះ និងមើលថៃកូនបានដែរ។ មនុស្ស ស្រីក៏អាចធ្វើការនៅខាងក្រៅផ្ទះបានដែរ។

### ភេទ និងយេនឌ័រៈ ដូចគ្នា ឬខុសគ្នា?

● ធម្មជាតិ/ជីវសាស្រ្តៈ គឺជាលក្ខណៈដែលយើងកើតមកជាមួយ ហើយយើងមិនអាចកែប្រែឬផ្លាស់ប្ដូរវាបាន បើគ្មានការជំនួយពីផ្នែកវេជ្ជសាស្រ្ត។

● វប្បធម៌/សង្គមៈ គឺជាលក្ខណៈ ឬតួនាទី ឬការគិតដែលមិនបានកើតមកជាមួយយើង ប៉ុន្តែយើងរៀនចេះ ពីគ្រួសារ សហគមន៍ និងស្ថាប័នសង្គមរបស់យើងដូចជា សាលារៀន វត្តអារាម រដ្ឋាភិបាល...។ល។ យើងអាចផ្លាស់ប្ដូរលក្ខណៈទាំងនោះបានដោយមិនចាំបាច់ត្រូវការជំនួយពីផ្នែកវេជ្ជសាស្រ្តឡើយ។

● ហេតុអ្វីបានជាវាមានសារៈសំខាន់ដើម្បីដឹងពី ការគិត លក្ខណៈរបស់យើង ភ្ជាប់ទៅនឹងភេទ ឬ ទៅនឹងយេនឌ័រ?

- យើងអាចយល់ថា ការរំពឹងទុកមួយចំនួនត្រូវបានដាក់នៅលើយើងដោយសារតែវប្បធម៌ ហើយការរំពឹងទុកមួយចំនួន ធ្វើឱ្យមានអារម្មណ៍ថាពិបាកក្នុងការរស់ ដូចនេះយើងអាចកែប្រែវាបាន ទោះបីជាត្រូវចំណាយពេលច្រើនដើម្បីធ្វើវាក៏ដោយ។
- យើងអាចធ្វើការជាមួយគ្នា ក្មេងប្រុស/បុរស និងក្មេងស្រី/នារី ហើយកំណត់លក្ខណៈអ្វីដែលយើងត្រូវធ្វើ ក្នុងនាមជាបុគ្គលមួយរូបនៅក្នុងសង្គម ការកំណត់នូវលក្ខណៈទាំងនេះមានការប្រែប្រួលយ៉ាងខ្លាំង។
- ការរំពឹងទុកមួយចំនួនដែលកំណត់ការប្រព្រឹត្តឬតួនាទីរបស់បុរសនិងស្រ្តី គឺមិនមែនមកពីកត្តាធម្មជាតិ ឬក៏ជីវសាស្រ្តទេ ប៉ុន្តវាបានមកពីកត្តាវប្បធម៌ និងសង្គម។ ផ្ទុយមកវិញ យើងគួរចាប់ផ្ដើមគិត ពីអ្វីដែលយើងយល់ថាមិនមានភាពយុត្តិធម៌ ឬការគិតមួយចំនួនដែលបង្អាក់ការអភិវឌ្ឍ ឬការបង្ហាញពីសក្ដានុពលពិតប្រាកដរបស់យើង។

### ការរំពឹងទុកតួនាទីយេនឌ័រ និងផ្នត់គំនិតយេនឌ័រ

● វាមានសារៈសំខាន់ ដែលត្រូវប្រើប្រាស់សកម្មភាពនេះក្នុងបរិបទនៃផែនការចិញ្ចឹមជីវិត និង បំណងប្រាថ្នាអនាគតរបស់សិស្ស។ អ្នកអាចចាប់ផ្ដើមដោយការនិយាយពីរឿងមួយ ឧទាហរណ៍ អំពីសេចក្ដីសង្ឃឹមរបស់អ្នកផ្ទាល់សម្រាប់អនាគតនៅពេល ដែលអ្នកមានអាយុប្រហែលពួកគេ។

● ពន្យល់សិស្សថា នៅពេលដែលពួកគេបំពេញប្រយោគ នៅក្នុងប្រយោគទីមួយ ពួកគេត្រូវគិត អំពីអនាគតរបស់ពួកគក្មេងភេទដែលពួកគេមានបច្ចុប្បន្ន។ នៅក្នុងប្រយោគទីពីរ ពួកគេត្រូវ គិតអំពីអនាគតរបស់ពួកគេ ប្រសិនពួកគេមានភេទផ្ទុយពីនេះ។ ប្រសិនបើមានសិស្សចង់សរសេរអ្វីដែលដូចគ្នាសម្រាប់ប្រយោគទាំងពីរនោះ គឺមិនជាបញ្ហាទេ។ អ្នកត្រូវកត់សម្គាល់លើប្រភេទសកម្មភាព/តួនាទីដែលក្មេងបានជ្រើសរើសក្នុងករណីដែលគេមានភេទបច្ចុប្បន្ន និងផ្ទុយដើម្បីមើលថាតើវាសមស្របសម្រាប់ភេទទាំងពីរ ដែរឬទេ។

● ចំណុចខាងក្រោមគួរត្រូវបានបញ្ចូលក្នុងពេលពិភាក្សាជាមួយសិស្សៈ

- គ្មាននរណាម្នាក់ត្រូវធ្វើ ឬគួរតែធ្វើអ្វីមួយដែលពួកគេមិនចង់ធ្វើនោះទេ ប្រសិនបើកិច្ចការនេះនឹងធ្វើឱ្យពួកគេទទួលរងគ្រោះ និងមានកម្រិតនៃគុណភាពជីវិតទាប។ ស្របពេលជាមួយគ្នានេះដែរ ដើម្បីធ្វើកិច្ចការអ្វីមួយក្នុងជីវិត

របស់យើង ដែលត្រូវដឹងពីប្រភេទនៃជំនាញ ឥរិយាបថ និង ចំណេះដឹងអ្វីដែលយើងអាចត្រូវការ ដើម្បីទៅដល់គោលដៅរបស់យើង។

- ជាញឹកញាប់ បុរស និងនារីអាចធ្វើកិច្ចការដូចគ្នាបានបើទោះបីជាពេលខ្លះត្រូវបានកំណត់ ដោយវប្បធម៌ថាជាកិច្ចការមនុស្សប្រុស ឬកិច្ចការមនុស្សស្រី។ ឧទាហរណ៍៖ បុរសអាច មើលថែកូន ហើយមនុស្សស្រីអាចធ្វើការនៅខាងក្រៅ ហើយបង្កើតជាមុខរបរ ប៉ុន្តែក្នុងវប្បធម៌ខ្លះកិច្ចការនេះ គឺមិនអាចទទួលយកបានឡើយ។
- ប្រសិនបើយើងនិយាយទាក់ទងនឹងធម្មជាតិ/ភេទ ដូចជាការមានកូន នោះគឺមានតែមនុស្សស្រីតែប៉ុណ្ណោះដែលអាចទទួលធ្វើតួនាទីនេះ។ ទោះបីជាយ៉ាងណាក៏ដោយ គ្រាន់តែពួកគេអាចធ្វើតួនាទីនេះមកពីកត្តាជីវសាស្ត្រ ប៉ុន្តែមិនមែនមានន័យថា ពួកគេត្រូវតែធ្វើវានោះទេ។ មនុស្សស្រីមួយចំនួនប្រហែលជាមិនចង់មានកូន។ នេះគួរតែជាជម្រើសមួយដែលទាំងមនុស្សប្រុស និងមនុស្សស្រីគួរតែអាចសម្រេច។
- ប្រសិនបើយើងនិយាយអំពីអ្វីដែលទាក់ទងនឹងវប្បធម៌/យេនឌ័រ ដូចជាការរៀបការនោះ ទាំងបុរសនិងនារី អាចធ្វើវាបាន។ ទោះបីជាយ៉ាងណាក៏ដោយ នេះគួរតែជាជម្រើសដែលពួកគេជាអ្នកសម្រេច។
- ក្នុងវប្បធម៌ខ្លះ ជម្រើសត្រូវបានធ្វើឡើងដោយការរំពឹងទុកដែលត្រូវបានកំណត់ដោយ បទដ្ឋានវប្បធម៌។ យើងចាប់ផ្តើមជឿថា នេះគឺជាអ្វីដែលយើងត្រូវធ្វើក្នុងជីវិតរបស់យើង ពីព្រោះយើងឮវាពីសង្គមរបស់យើង។ ឧទាហរណ៍ យើងប្រហែលជាគិតថា វាអាចទទួល យកបានសម្រាប់ក្មេងស្រីបោះបង់ការសិក្សា ហើយនៅផ្ទះ និងធ្វើការ ព្រោះវាមានសារៈសំខាន់ជាងសម្រាប់ក្មេងប្រុសក្នុងការសិក្សា ដូច្នេះពួកគេអាចទទួលបានការងារដែល ទទួលបានប្រាក់កម្រៃខ្ពស់នៅពេលក្រោយ។ បញ្ហានេះមិនអាចទទួលយកបាន ដែលជាការរំពឹងទុករបស់វប្បធម៌មួយដែលធ្វើឱ្យប៉ះពាល់ដល់ជម្រើសជីវិតសម្រាប់ក្មេងស្រី និងមនុស្សស្រី។
- ការអប់រំគឺជាសិទ្ធិដែលយើងទាំងអស់គ្នាមានទាំងក្មេងប្រុស និងក្មេងស្រី ព្រោះយើង ទាំងអស់គ្នាគឺជាមនុស្ស។ យើងគួរតែគិតអំពីអ្វីដែលយើងចង់ធ្វើ និងអ្វីដែលយើងអាចធ្វើនៅពេលយើងបញ្ចប់ការសិក្សា ដោយយោងទៅតាមក្តីស្រមៃ និងការរំពឹងទុករបស់ យើងផ្ទាល់ មិនមែនក្តីស្រមៃ និងការរំពឹងទុករបស់សង្គមឡើយ។ បន្ទាប់មក យើងអាចចាប់ផ្តើមធ្វើកិច្ចការដើម្បីឆ្ពោះទៅរកគោលដៅនេះ ដោយការអភិវឌ្ឍ និងការរៀបចំខ្លួន របស់យើងសម្រាប់អនាគត។

- នៅពេលដែលអ្នកឱ្យសិស្សបំពេញប្រយោគចុងក្រោយ បញ្ជាក់ពាក្យ មនុស្សក្នុងប្រយោគ។ ប្រាប់ពួកគេថា ពួកគេគួរតែគិតអំពីអ្វី ដែលពួកគេពិតជាចង់ក្លាយទៅជា និងចង់ធ្វើក្នុងនាមជាមនុស្សម្នាក់ ដោយមិនមែនទៅតាមអ្វីដែលសង្គមរំពឹងពីពួកគេនោះទេ។
- អ្នកប្រហែលជានឹងឃើញចម្លើយខ្លះ ឬប្រហែលជាទាំងអស់ មិនមានការផ្លាស់ប្តូរពីប្រយោគ មុនទេ។ ការនេះមិនថ្មីទេ។ គ្មានចម្លើយខុស ឬត្រូវក្នុងសកម្មភាពនេះឡើយ។ គោលបំណង គឺដើម្បីជួយសិស្សឱ្យមើលឃើញពីរបៀបដែលវប្បធម៌ និងប្រពៃណីក្នុងទម្រង់នៃការរំពឹងទុក របស់ភេទ និងផ្តត់គំនិតយេនឌ័រដែលអាចជះឥទ្ធិពលលើការសម្រេចចិត្តរបស់យើង។ គោលបំណងសំខាន់ គឺមិនមែនធ្វើឱ្យសិស្សកែប្រែចិត្តរបស់ពួកគេអំពីអ្វី ដែលពួកគេចង់ធ្វើក្នុងពេលអនាគតឡើយ!



# មេរៀនទី ៣: ការរើសអើង

🕑 រយៈពេលបង្រៀន: ១ ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ:

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ក្ដារខៀន ដីស
- ផ្ទាំងក្រដាសធំ ស្កុត
- ហ្វឺតចំរុះពណ៌ ឬគូលរ័ទៀន
- ឯកសារសម្រាប់សិស្សដូចបានរៀបរាប់ខាងលើ

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច:

- ស្គាល់ពីទម្រង់មួយចំនួននៃផ្នត់គំនិតយេនឌ័រ
- កំណត់ពីទម្រង់មួយចំនួននៃការរើសអើងក្នុងការងារ។

## សេចក្ដីផ្ដើម

🕑 ១៥ នាទី

👄 លោកគ្រូ/អ្នកគ្រូនឹងរំលឹកមេរៀនចាស់ដែលយើងបានរៀនពីសប្ដាហ៍មុន។ តើនិយាយអំពីអ្វីខ្លះ? តើពួកគេបានរៀនអ្វីខ្លះ? គ្រូតពិនិត្យកិច្ចការផ្ទះ ដែលអ្នកបានដាក់ឱ្យកាលពីម៉ោងមុន។

- ទុកឱ្យសិស្សឆ្លើយតបអំពីភាពខុសប្លែកគ្នា ដែលពួកគេបានសង្កេតអំពីរបៀបដែលសមាជិកគ្រួសារ ឬសមាជិកសហគមន៍ប្រព្រឹត្តដោយយោងតាមភេទរបស់ពួកគេ។ តើមានភាពខុសប្លែកគ្នាអ្វីខ្លះ ប្រសិនបើមាន? តើសិស្សគិតថានេះ ជាលទ្ធផលនៃធម្មជាតិ/ភេទ ឬ វប្បធម៌/យេនឌ័រ? *(សរសេរពាក្យគន្លឹះនៅលើក្ដារខៀន ប្រសិនបើចាំបាច់។ លើកទឹកចិត្ត សិស្សឱ្យចែករំលែកគំនិតរបស់ពួកគេ និងចូរប្រាកដថាពួកគេដឹងថាគ្មានចម្លើយខុសឬត្រូវនោះទេ។ ទាំងនោះជាការសង្កេតផ្ទាល់របស់ពួកគេ ហើយយោបល់ទាំងអស់របស់ពួកគេគឺមានសារៈសំខាន់។ ប្រើព័ត៌មានពីម៉ោងមុនដើម្បីពង្រឹងការសិក្សា ប្រសិនបើចាំបាច់)*។

👄 គ្រូណែនាំពីប្រធានបទសម្រាប់ថ្ងៃនេះដោយពន្យល់ថា យើងនឹងបន្តសិក្សាអំពីវប្បធម៌/យេនឌ័រ ដោយយើងធ្វើការពិនិត្យមើលពីឥទ្ធិពលនៃផ្នត់គំនិតរបស់យេនឌ័រ ទៅលើជីវិតរបស់យើង។ *(សំដៅទៅលទ្ធផលរំពឹងទុករបស់ការសិក្សា)*

## សកម្មភាពសំខាន់។

🕑 ៦៥ នាទី

គ្រូប្រាប់សិស្សថា ពួកគេនឹងធ្វើតេស្តរកហេតុផលតូចមួយ *(មើលសេចក្តីណែនាំសម្រាប់គ្រូ)* ហើយអ្នកនឹងអានរឿងខ្លីមួយ ហើយពួកគេត្រូវស្តាប់ដោយយកចិត្តទុកដាក់ *(រឿងនិងសំណួរអាចរកឃើញនៅក្នុងឯកសារសម្រាប់សិស្ស)*។

- បន្ទាប់ពីលោកគ្រូ/អ្នកគ្រូបានអានរឿងចប់ម្តង គ្រូចែកតារាងសំណួរដល់សិស្សទាំងអស់គ្នា *(អ្នកអាចសរសេរវានៅលើផ្ទាំងក្រដាសធំ ហើយសិស្សអាចសរសេរលេខសំណួរ និងឆ្លើយក្នុងសៀវភៅរបស់ពួកគេ)*។ ឱ្យសិស្សឆ្លើយសំណួរមុនពេលដែលអ្នកអានរឿងម្តងទៀត។

គ្រូអានរឿងម្តងទៀត។ សិស្សអាចធ្វើការកែប្រែចម្លើយរបស់ពួកគេ ហើយពួកគេអាចផ្ទៀងផ្ទាត់ចម្លើយជាមួយដៃគូ និងបន្ទាប់មកជាមួយក្រុម។
ប្រាប់សិស្សថា ចម្លើយទៅនឹងសំណួរទាំងអស់នោះគឺ "មិនដឹង"។ សួរពួកគេពីមូលហេតុ*(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។

ពន្យល់ថា នៅពេលដែលអ្នកកំពុងស្តាប់/អានរឿង យើងនឹងគិត/សន្មតអំពីតួនាទីដែលរបស់មនុស្សនៅក្នុងរឿងនេះថាវេជ្ជបណ្ឌិត ជាមនុស្សប្រុស អ្នកកសាងជាមនុស្សប្រុស គិលានុបដ្ឋាយិកាជាមនុស្សស្រី។ នេះគឺជា ផ្នត់គំនិតសង្គមដែលយើងមាននៅក្នុងការគិតរបស់យើង*(មើលសេចក្តីណែនាំសម្រាប់គ្រូ)*

សួរអំពីអារម្មណ៍របស់ពួកគេចំពោះការធ្វើតេស្ត បញ្ជាក់ថា តើពួកគេរកនឹកឃើញវិធីផ្សេងៗដែលអាចបង្កើតជាផ្នត់គំនិតអំពីមនុស្ស? *(មើលសេចក្តីណែនាំសម្រាប់គ្រូ) ពន្យល់ថា ផ្នត់គំនិតសង្គម សំដៅទៅលើ ការគិតរបស់មនុស្សអំពីតួនាទី អាកប្បកិរិយារបស់បុរស ស្ត្រី ។ ដែលវាជាទូទៅគឺមិនពិត*
បង្កើតបញ្ជីជាឧទាហរណ៍នៃផ្នត់គំនិតនៅលើក្តារខៀន។

**ការរើសអើង**

គ្រូសរសេរសំណួរខាងក្រោមនៅក្តារខៀន ហើយឱ្យសិស្សពិភាក្សាជាក្រុមតូចៗក្នុងរយៈពេល១៥នាទី។

ក) តើការរើសអើងមានន័យយ៉ាងណា?
ខ) តើមាននរណាធ្លាប់ត្រូវបានគេ រើសអើងដែរឬទេ? ដោយរបៀបណា? ពេលណា?
គ) តើអ្នកណាម្នាក់អាចគិតឃើញពីឧទាហរណ៍ នៃការរើសអើងនៅកន្លែងធ្វើការងារដែរឬទេ?

ខណៈដែលសិស្សកំពុងពិភាក្សា គ្រូសរសេរឧទាហរណ៍នៃ "ការរើសអើងក្នុងកន្លែងធ្វើការ" នៅលើ ក្តារខៀន។
ប្រាប់សិស្សថា ពួកគេនឹងពិនិត្យមើលឧទាហរណ៍នៃករណីមួយចំនួន*(មើលឯកសារសម្រាប់សិស្ស)* ដែលកើតឡើងនៅកន្លែងធ្វើការខុសៗគ្នា ហើយពួកគេត្រូវសម្រេចចិត្តថា តើនេះជាករណីនៃការរើសអើង ឬមិនមែន។ *(ធ្វើសំណួរទីមួយជាមួយគ្នា ដូច្នេះពួកគេនឹងយល់ច្បាស់អំពីអ្វីដែលពួកគេត្រូវធ្វើ)*



- សិស្សធ្វើការជាដៃគូឬក្រុម
- ពិភាក្សាចម្លើយជាក្រុម ហើយបង្កើតជាកំណត់ត្រាអំពីការរើសអើងនៅលើក្តារខៀន *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។

## បញ្ចប់មេរៀន

១០ នាទី

កិច្ចការផ្ទះ៖ សិស្សកត់ប្រយោគខាងក្រោម ហើយបំពេញវានៅផ្ទះ៖

ក) ខ្ញុំយល់ផ្នត់គំនិតគឺជា...

ខ) ខ្ញុំយល់ការរើសអើងគឺជា...

គ) ឧទាហរណ៍នៃផ្នត់គំនិតនិងការរើសអើងដែលខ្ញុំមានបទពិសោធន៍ និង/ឬធ្លាប់បានឃើញរួមមាន...

## សេចក្តីណែនាំសម្រាប់គ្រូ

លំហាត់នេះនឹងដំណើរការកាន់តែប្រសើរ ប្រសិនបើអ្នកប្រាប់សិស្សថាអ្នកមានលំហាត់ខ្លីមួយស្តី "អំពីការរកមូលហេតុ" ដូច្នេះមិនត្រូវប្រាប់ពីគោលបំណងពិតប្រាកដរបស់វាឡើយ។ នៅក្នុងសេចក្តីដកស្រង់ "ភេទ" របស់តួអង្គមិនត្រូវបានប្រាប់ដល់សិស្សនោះទេ ប៉ុន្តែសិស្សត្រូវសន្មតដោយស្វ័យប្រវត្តិថា គិលានុបដ្ឋាយិកាគឺជាមនុស្សស្រី អ្នកស្លាបនា និងវេជ្ជបណ្ឌិតជាមនុស្សប្រុស ។ល។ តាមពិត នេះមិនធ្លាប់ត្រូវបាននិយាយថា៖ ចម្លើយរបស់សំណួរទាំងអស់នោះគួរតែ "មិនដឹង"។

- លំហាត់នេះ ត្រូវបានសរសេរឡើងដើម្បីទទួលបានព័ត៌មានអំពីផ្នត់គំនិតដែលសិស្សជាច្រើនអាចនឹងអនុវត្ត ឬក៏មានជាប់មកជាមួយក្នុងភាសា។ យើងទំនងជាបង្កើតផ្នត់គំនិតការងារមួយចំនួនជាមួយនឹងភេទ។ ផ្នត់គំនិតទាំងនោះអាចក្លាយជាអ្វីដែលត្រូវបានគេរំពឹងទុក ជាមួយបុរសប្រហែលជាមិនចង់ក្លាយជាគិលានុបដ្ឋាយិកា ហើយមនុស្សស្រីជៀសវាងការធ្វើការងារនៅក្នុងវិជ្ជាជីវៈការសាងសង់។ យើងទំនងជាបង្កើតការសន្មតជាច្រើនគ្រប់ពេលវេលា ជាញឹកញាប់ទាំងអស់នោះគឺព្រោះយើងបង្កើតផ្នត់គំនិតអំពីមនុស្ស។
- វាមានសារៈសំខាន់ក្នុងការពន្យល់សិស្សថា ផ្នត់គំនិតគឺជាទម្រង់នៃការប្រកាន់ពូជសាសន៍ និង ការរើសអើង។
- ឧទាហរណ៍មួយចំនួននិយាយអំពីផ្នត់គំនិត៖

 ១. បុរសមិនយំ (សួរសិស្សប្រុសថាតើពួកគេធ្លាប់យំដែរឬទេ!)

 ២. បុរសចូលចិត្តកីឡាថាមពលជាងក្មេងស្រី (សួរតើមានក្មេងស្រីប៉ុន្មាននាក់ចូលចិត្តលេង/មើលបាល់ទាត់ សួរតើមានក្មេងប្រុសប៉ុន្មាននាក់ដែលមិនចូលចិត្តលេង/មើលបាល់ទាត់)

 ៣. នារីមានភាពខ្មាសអៀន និងអសកម្ម *(សួរថាតើក្មេងប្រុសមានភាពខ្មាសអៀនឬទេ។ សួរតើក្មេងស្រីណាខ្លះដែលមិនមានភាពខ្មាសអៀន)*

 ៤. នារីពូកែមើលក្មេងៗជាងមនុស្សប្រុស *(តើវាពិតប្រាកដដែរឬទេ យោងតាមបទពិសោធន៍របស់ពួកគេ? ហេតុអ្វីបានជាមនុស្សគិតដូចនេះ?)*

 ៥. បុរសបើកបរបានល្អជាងមនុស្សស្រី (ហេតុអ្វីបានជាពួកគេគិតថានេះជាក្លាយជាផ្នត់គំនិត? រំលឹកពួកគេថានៅលើពិភពលោកយើងនេះ មនុស្សប្រុសចាប់ផ្តើមបើកបរមុនមនុស្សស្រី ពីព្រោះមនុស្សស្រីមិនត្រូវបានអនុញ្ញាតឱ្យបើកបរក្នុងវប្បធម៌ជាច្រើន ហើយក្នុងសង្គមខ្លះ មនុស្សស្រីនៅតែមិនត្រូវបានអនុញ្ញាតឱ្យបើកបរ។ នេះមិនដូចបុរសដែលជាអ្នកបើកបរពូកែជាងមនុស្សស្រី!)

 ៦. រំលឹកពួកគេអំពីភាពខុសប្លែកគ្នារវាងភេទ/ធម្មជាតិ និងយេនឌ័រ/វប្បធម៌ ហើយនិងឥទ្ធិពលដែលគំនិតទាំងនោះអាចមានលើជំនឿ ឥរិយាបថ និងអាកប្បកិរិយារបស់យើង។

**ការរើសអើងនៅកន្លែងធ្វើការ**

● ករណីនៅកន្លែងធ្វើការ អាចរកឃើញនៅក្នុងឯកសារចែកសិស្ស។ ប្រសិនបើអ្នកមិនអាច ថតចម្លង អ្នកអាចសរសេរនៅលើក្តារខៀន ឬផ្ទាំងក្រដាសធំ ហើយឱ្យសិស្សកត់ទុកក្នុងសៀវភៅរបស់ពួកគេ។

● វាមានសារៈសំខាន់ដែលលោកគ្រូ/អ្នកគ្រូត្រូវយល់ថា លំហាត់ដែលឱ្យសិស្សធ្វើការកំណត់ពីរូបភាពផ្សេងៗនៃការរើសអើងនៅកន្លែងធ្វើការ នេះគឺអាស្រ័យទៅលើសមត្ថភាពសិស្សដើម្បីកំណត់ចម្លើយរបស់ពួកគេ។ គ្រូគួរតែលើកទឹកចិត្តក្នុងការពិភាក្សា និងរំលេចពីទស្សនវិស័យផ្សេងៗ ដែលអាចបង្កើតជាផ្នត់គំនិត និងការរើសអើង ជាជាងការប៉ុនប៉ងដើម្បីបែងចែកករណី ថា "ត្រូវ" ឬ "ខុស"។ រំលឹកសិស្សម្តងទៀត អំពីភាពខុសប្លែកគ្នានៃភេទ/ធម្មជាតិ និងយេនឌ័រ/វប្បធម៌ ហើយ និងឥទ្ធិពលដែលផ្នត់គំនិតទាំងនោះអាចជះឥទ្ធិពលលើជំនឿ ឥរិយាបថ និងអាកប្បកិរិយារបស់យើង។

● ចំណុចសំខាន់ដែលគួរតែត្រូវបានបញ្ចូលក្នុងការពិភាក្សាជាមួយសិស្សរួមមាន៖

- មនុស្សដែលត្រូវបានប្រព្រឹត្តខុសប្លែកគ្នា ដោយសារតែភេទ ជាតិសាសន៍ ពណ៌សម្បុរ និងសញ្ជាតិ ដើមកំណើត ឬប្រភពដើមនៃជាតិ ឬស្ថានភាពគ្រួសាររបស់ពួកគេ។ ឧទាហរណ៍ និយោជិតទទួលបានប្រាក់ខែខុសគ្នា បើទោះជាធ្វើការងារដូចគ្នាដ៏ដោយ ពីព្រោះតែភេទរបស់ពួកគេ។
- នយោជិករើសអើងប្រឆាំងនឹងបុគ្គលម្នាក់ ដោយអាស្រ័យលើហេតុផលនៃពិការភាព របស់ពួកគេ។ ដើម្បីការពារការរើសអើង នយោជិកត្រូវតែរំពឹងថានឹងធ្វើការកែខែចំពោះកន្លែងធ្វើការ និងល័ក្ខខ័ណ្ឌធ្វើការមួយចំនួន ដូច្នេះមនុស្សពិការមិនត្រូវបានដាក់នៅក្នុងគុណវិបត្តិទូទៅមួយ។
- នយោជិកម្នាក់ មានការរើសអើងព្រោះតែទំនោរផ្លូវភេទរបស់ពួកគេ *(ឧទាហរណ៍៖ មនុស្សប្រុសខ្ទើយ ឬមនុស្សស្រីស្រលាញ់មនុស្សស្រី)*
- ការរើសអើងអាយុ *(ប្រសិនបើអ្នកត្រូវបានបដិសេធចំពោះការងារមួយដែលអ្នកមានសមត្ថភាពគ្រប់គ្រាន់ពីព្រោះអ្នកមានអាយុក្មេងពេក ឬចាស់ពេក)*។
- ការបៀតបៀន ក៏ត្រូវបានរាប់បញ្ចូលជាទម្រង់មួយនៃការរើសអើងផងដែរ។ ឧទាហរណ៍ ការរំលោភបំពានជាតិសាសន៍ ឬមនុស្សដែលកំណត់សម្គាល់អំពីភេទ។
- ការរើសអើងមិនចាំបាច់តម្រង់ទៅរកតែបុគ្គលទេ វាក៏អាចកើតឡើង ប្រសិនក្រុមហ៊ុន ដាក់សម្ពាធទៅលើមនុស្សមួយក្រុមឱ្យទទួលការងារមួយ ។ ឧទាហរណ៍ ក្រុមហ៊ុនអាចទាមទារកម្រិតជោគជ័យអប្បបរមា សូម្បីតែគ្មានអ្វីដែលពាក់ព័ន្ធជាមួយការងារ។ ការរើសអើងនេះ ច្រើនកើតមានចំពោះមនុស្សស្រី។
- ពេលខ្លះ នយោជិកអាចប្រកែកបានថា ការរើសអើងប្រភេទខ្លះគឺមានភាពចាំបាច់សម្រាប់ការងារ។ ឧទាហរណ៍ ភោជនីយដ្ឋានខ្មែរមួយដែលបម្រើម្ហូបខ្មែរ និងនិយាយភាសាខ្មែរ - ការនិយាយជាមួយអតិថិជនប្រហែលនឹងអាចជាលក្ខខណ្ឌក្នុងការជ្រើសរើស ដោយកំណត់អ្នកចេះនិយាយភាសាខ្មែរតែប៉ុណ្ណោះ។ នេះអាចនឹងគិតថាជាហេតុផលសមស្រប ទៅតាមកាលៈទេសៈ។



ផ្តត់គំនិត

**<u>តេស្តរកមូលហេតុ:</u>**

អ្នកស្ដាបនាម្នាក់ដែលកំពុងផ្ដេកទៅនឹងឡានដឹកទំនិញមួយបានហួចទៅកាន់គិលានុបដ្ឋាយិកាដែលកំពុងដើរឆ្លងកាត់។ គិលានុបដ្ឋាយិកាដដែលបានទៅដល់កន្លែងធ្វើការ ហើយប្រាប់បញ្ហានេះទៅកាន់វេជ្ជបណ្ឌិត។ វេជ្ជបណ្ឌិតនិយាយថា "ខ្ញុំមិនដែលនិយាយដូច្នេះទេ"។ វេជ្ជបណ្ឌិតមានកូនធំពេញវ័យពីរនាក់ដែលមានអាយុ ២៦ឆ្នាំ និង៣០ឆ្នាំ។ ពួកគេចុះសម្រុងនឹងគ្នាខ្លាំងណាស់។ ម្នាក់ជាពលបាលត្រីក្នុងជួរកងទ័ព ហើយម្នាក់ទៀតកំពុងរៀនអំពីការកែសម្ផស្ស។ វេជ្ជបណ្ឌិតបានលែងលះជាមួយភរិយាកាលពីឆ្នាំទៅ ប៉ុន្តែកាលពីពេលថ្មីៗនេះ គាត់បានជួបនឹងនារីម្នាក់ ហើយមានគម្រោងនឹងរៀបការម្ដងទៀត។

| ឆ្លើយសំណួរខាងក្រោមយោងតាមព័ត៌មានដែលបានផ្ដល់ដោយគូស(✓)ក្នុងប្រអប់ដែលសមស្រប។ | ត្រូវ | ខុស | មិនដឹង |
|---|---|---|---|
| ១. អ្នកស្ដាបនាកំពុងបើកបរឡានដឹកទំនិញ។ | | | |
| ២. ឡានដឹកទំនិញធ្វើដំណើរលឿនជាងគិលានុបដ្ឋាយិកា។ | | | |
| ៣. មានមនុស្សប្រុសយ៉ាងតិចណាស់ម្នាក់នៅក្នុងឡានដឹកទំនិញ។ | | | |
| ៤. មិនមែនបុរសទាំងអស់ដែលបានរៀបរាប់នឹងហួចទៅកាន់អ្នកដំណើរឆ្លងកាត់។ | | | |
| ៥. វេជ្ជបណ្ឌិតមិនរស់នៅជាមួយប្រពន្ធគាត់ទៀតទេ។ | | | |
| ៦. វេជ្ជបណ្ឌិតមានមិត្តស្រីថ្មី។ | | | |
| ៧. កូនរបស់វេជ្ជបណ្ឌិតគឺនៅក្នុងជួរកងទ័ព។ | | | |
| ៨. កូនដែលក្មេងជាងគេគឺកំពុងរៀនអំពីការកែសម្ផស្ស។ | | | |
| ៩. នៅក្នុងចំណុចខ្លះ មនុស្សប្រុសនិយាយជាមួយមនុស្សស្រី។ | | | |
| ១០. មនុស្សយ៉ាងតិចពីរនាក់ដែលបានរៀនរាប់ខាងលើជាមនុស្សប្រុស។ | | | |

ការរើសអើង

តើខាងក្រោមជាឧទាហរណ៍នៃការរើសអើងឬ? ពន្យល់មូលហេតុ ឬ ហេតុអ្វីមិនមែន?

១. វិបុលមានអាយុ៥៥ឆ្នាំ បានដាក់ពាក្យធ្វើការងារជាអ្នកដុតនំម្នាក់។ ក្រុមហ៊ុនមិនបានផ្ដល់ការងារនេះឱ្យគាត់ទេ ដោយសារតែពួកគេចង់បានមនុស្សដែលក្មេងជាងនេះ ដើម្បីអោយសក្ដិសមជាមួយបុគ្គលផ្សេងទៀត។

២. សូលីនដែលប្រើប្រាស់រទេះជនពិការ បានបរាជ័យក្នុងការទទួលបានការងារជាអ្នកសរសេរកម្មវិធី ដោយហេតុថាក្រុមហ៊ុនតូច(មានបុគ្គលិក១០នាក់)គិតថា ពួកគេមិនមានថវិកាគ្រប់គ្រាន់ក្នុងការរៀបចំការិយាល័យដើម្បីអោយរទេះជនពិការអាចប្រើប្រាស់បាន។

៣. បុគ្គលិកបុរសម្នាក់បានហួចដាក់ថាវីជារៀយៗនៅពេលដែលនាងដើរកាត់កន្លែងបុគ្គលិកធ្វើការ។ រឿងនេះធ្វើអោយនាងមានអារម្មណ៍មិនសុខស្រួល និងគ្មានសុវត្ថិភាព។

៤. ភាព បានបរាជ័យក្នុងការឡើងឋានៈ សូម្បីតែនាងជាបេក្ខជនដ៏ល្អបំផុតមួយរូប ពីព្រោះក្រុមប្រឹក្សាគិតថានាងនឹងចាប់ផ្ដើមជីវិតគ្រួសារក្នុងពេលឆាប់ៗ ហើយនឹងសុំច្បាប់ឈប់សម្រាកជាច្រើន។

# មេរៀនទី ៤: តួនាទីយេនឌ័រនៅក្នុងសហគមន៍

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ក្ដារខៀន ដីស
- ផ្ទាំងក្រដាសធំ ស្កុត
- ហ្វឺតចំរុះពណ៌ ឬគូល័រទៀន
- ឯកសារសិស្ស ៤.១ និង ៤.២

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាចៈ

- ស្វែងយល់ពីការរំពឹងទុករបស់សហគមន៍ចំពោះតួនាទី និងការទទួលខុសត្រូវរបស់បុរស និងស្ត្រី
- បែងចែងតួនាទី និងទំនួលខុសត្រូវរបស់បុរស និងនារី ជាការងារផលិតភាព ការងារបន្តពូជ និងការងារសហគមន៍

**សេចក្ដីផ្ដើម** 🕑 ១០ នាទី

✋ គ្រូឱ្យសិស្សយកកិច្ចការផ្ទះកាលពីម៉ោងមុន មកចែករំលែកជាមួយគ្នា។

✋ ព្យួររូបភាពផ្ទាំងធំ " ដប់ដងត្រូវ ?ឬដប់ដងខុស ?" នៅលើក្ដារខៀន។

👄 ពន្យល់ប្រាប់សិស្សថាៈ មេរៀននេះនឹងនិយាយពីការរំពឹងទុករបស់សហគមន៍ទៅលើតួនាទីយេនឌ័រ។ ជាការចាប់ផ្ដើម ឱ្យក្មេងក្រឡេកមើលផ្ទាំងរូបភាពធំនៅលើក្ដារខៀនដែលបានប្រើនៅក្នុងមេរៀនទី២ ទាំងអស់គ្នា។

◈ តើអ្នកគិតថា អ្នកនៅក្នុងភូមិ ឬសហគមន៍ យល់ឃើញ/និយាយថា ដូចម្ដេចចំពោះប្រយោគទាំងអស់នេះ ? ( ឱ្យសិស្សពន្យល់ពីមូលហេតុ ) តើការយល់ឃើញរបស់ពួកគេ មានភាពខុសគ្នាយ៉ាងម៉េចជាមួយគំនិតរបស់អ្នក ?

## សកម្មភាពសំខាន់។

⏲ ៨០ នាទី

**ថ្ងៃដែលមាន២៤ម៉ោង**

*(យកលំនាំតាមសៀវភៅការអភិវឌ្ឍ និងការលើកម្ពស់យេនឌ័រ UNDP/Kabul, ២០០៧)*

✋ ឱ្យសិស្សបង្កើតជា៤ក្រុម ហើយពន្យល់ថាពួកគេនឹងធ្វើការជាមួយគ្នាដើម្បីបំពេញកិច្ចការមួយ ដែលនឹងបង្ហាញតួនាទី ៣ យ៉ាង ខុសៗពីគ្នា ដែលបុរសនិងនារី ធ្វើ។

✎ សរសេរពាក្យ "ផលិតភាព" "បន្តពូជ" និង "សហគមន៍" នៅលើក្តារខៀន។ សួរសិស្សបញ្ជាក់ ដើម្បីប្រាកដថាសិស្សយល់ពីអត្ថន័យនៃពាក្យនីមួយៗ



✋ ដំបូង ផ្តល់ប្រភេទអ្នកធ្វើការមួយទៅឱ្យក្រុមនីមួយៗ រួចបន្ទាប់មក ចែកផ្ទាំងក្រដាសធំមួយសន្លឹកទៅឱ្យ ក្រុមនីមួយៗ។

ក្រុមទី១ គឺជាកសិករស្រី។
ក្រុមទី២ គឺជាកសិករប្រុស។
ក្រុមទី៣ គឺជាក្រុមប្រឹក្សាឃុំស្រី។
ក្រុមទី៤ គឺជាក្រុមប្រឹក្សាឃុំប្រុស។

👄 ប្រាប់ក្រុមនីមួយៗឱ្យគូររង្វង់ធំមួយនៅលើក្រដាស ហើយស្រមៃរង្វង់នោះថាជា នំមួយ។ ប្រាប់ពួកគេថា អ្នកចង់ឱ្យពួកគេគិតអំពីអ្នកធ្វើការដែលអ្នកបានផ្តល់ឱ្យ និងគិតអំពីសកម្មភាព/កិច្ចការខុសប្លែកគ្នាទាំងអស់ដែលមនុស្សនេះធ្វើក្នុងមួយថ្ងៃ ដែលមានរយៈពេល២៤ម៉ោង។ សកម្មភាពអាចទាក់ទង នឹងការងារ ឬការកំសាន្ត។

- សិស្សបែងចែករង្វង់ជាផ្នែកៗ *(ដូចជាការកាត់នំ)* ហើយក្នុងផ្នែកនីមួយៗតំណាងឱ្យចំនួនពេលវេលាដែលផ្តល់សម្រាប់សកម្មភាពជាក់លាក់ណាមួយ។ ទំហំនៃផ្នែកនីមួយៗនឹងអាស្រ័យលើចំនួនពេលវេលាដែលផ្តល់សម្រាប់ធ្វើសកម្មភាពនោះ។ ពួកគេគួរតែបង្ហាញអ្វីគ្រប់យ៉ាងដែលបុគ្គលនោះធ្វើក្នុងមួយថ្ងៃរួមបញ្ចូលទាំង ដេក ញុំា ។ល។ *(ទុកពេលឱ្យសិស្សប្រហែលជា២០នាទី។ វាមានសារៈសំខាន់ក្នុងការដើរពិនិត្យមើល ដើម្បីឱ្យប្រាកដថាពួកគេយល់ពីកិច្ចការ និងពួកគេអាចបំពេញវាជាក្រុម)*។
- បន្ទាប់មកសមាជិកទាំងអស់ក្នុងក្រុមនីមួយៗឡើងមកបង្ហាញក្រាបទៅកាន់សិស្សដទៃទៀត។
- ក្រោយពេលសិស្សបញ្ចប់ការបង្ហាញរបស់ពួកគេ ដឹកនាំការពិភាក្សាអំពីភាពខុសប្លែកគ្នាក្នុងសកម្មភាព និងពេលវេលាដែលបានចំណាយក្នុងផ្នែកនីមួយៗ។

ប្រើប្រាស់សំណួរខាងក្រោមដើម្បីសម្រួលក្នុងការដឹកនាំការពិភាក្សា៖

១. តើអ្វីជាការចាប់អារម្មណ៍ដំបូងបំផុតនៅពេលដែលអ្នកបានឃើញពីរបៀបដែលពេលវេលាត្រូវបានផ្តល់សម្រាប់អ្នកធ្វើការខុសៗគ្នា? តើវាធ្វើឱ្យអ្នកភ្ញាក់ដែរឬទេ? ហេតុអ្វី?

២. តើសកម្មភាពណាខ្លះដែលអ្នកគិតថាជាការងារ?តើអ្នកកំណត់និយមន័យការងារយ៉ាងដូចម្តេច?

៣. តើអ្វីខ្លះជាភាពខុសប្លែកគ្នាក្នុងរបៀបដែលមនុស្សប្រុស និងមនុស្សស្រីចំណាយពេលវេលាក្នុងមួយថ្ងៃៗ? ពេលកំសាន្តរបស់ពួកគេ?

៤. តើអ្វីខ្លះជាផលវិបាកនៃភាពខុសប្លែកគ្នាទាំងនោះសម្រាប់មនុស្សស្រី? តើអ្វីខ្លះជាការបង្ហាញពីផលប៉ះពាល់សុខភាពដែលអាចកើតមាន? ឬក៏ ការបង្ហាញពីផលប៉ះពាល់ដែលទាក់ទងនឹងប្រាក់ចំណូលដែលអាចកើតមាន?
៥. តើអ្វីខ្លះជាផលវិបាកសម្រាប់បុរស? តើអ្វីខ្លះជាផលវិបាកសម្រាប់សង្គមក្នុងលក្ខណៈទូទៅ?
៦. តើសកម្មភាពណាមួយដែលអ្នកនឹងដាក់នៅក្នុងតួនាទីផលិតភាព តួនាទីបន្តពូជ និងតួនាទីសហគមន៍? តើអ្នកនឹងឱ្យនិយមន័យពាក្យទាំងនោះដោយរបៀបណា? *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*

ការរៀបចំសម្រាប់សកម្មភាពស្រាវជ្រាវ

គ្រូណែនាំពីសកម្មភាពស្រាវជ្រាវដែលសិស្សនឹងត្រូវធ្វើការស្រាវជ្រាវក្នុងសហគមន៍ *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។

សួរសិស្សអំពីអ្វីដែលពួកគេចង់ដឹងពីសហគមន៍ ទាក់ទងនឹងតួនាទីយេនឌ័រ និងទំនួលខុសត្រូវរបស់បុរសនិងស្ត្រី ។

● សិស្សធ្វើការត្រិះរិះពិចារណារកគំនិតថ្មី ហើយគ្រូសរសេរគំនិតទាំងនោះនៅលើក្តារខៀន *(អ្នកអាចឱ្យសិស្សឡើងមកសរសេរគំនិតរបស់ពួកគេនៅលើក្តារខៀនដោយខ្លួនឯងក៏បាន)*។ ប្រើប្រាស់ផែនទីគំនិតជាជំនួយក្នុងការចាត់ជាផ្នែកនៃព័ត៌មានទាំងនោះ *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។

● ពិនិត្យមើលគំនិតទាំងនោះជាមួយសិស្ស ហើយដាក់គំនិតដែលប្រហាក់ប្រហែលគ្នា នៅជាមួយគ្នា *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។ គ្រូពន្យល់ទៅកាន់សិស្សថា ពួកគេនឹង ប្រើប្រាស់គំនិតទាំងនោះ ដើម្បីរៀបចំបង្កើតជាសំណួរក្នុងការសម្ភាសជាមួយសមាជិកសហគមន៍។

ឥឡូវគ្រូមានជម្រើស ៣៖

*ជម្រើសទី ១៖* សិស្សជាអ្នកជ្រើសរើសប្រធានបទសម្រាប់សកម្មភាពស្រាវជ្រាវ *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។ ប្រសិនបើគ្រូមានបទពិសោធន៍ ឬមានទំនុកចិត្តក្នុងការអនុញ្ញាតឱ្យសិស្ស ជាអ្នកដឹកនាំក្នុងដំណើរការស្រាវជ្រាវជាមួយការ ណែនាំតិចតួចសិស្សគួរជ្រើសរើសជម្រើសនេះ។ ជាធម្មតាសិស្សធ្លាប់បានបង្កើត និងធ្វើសកម្មភាពស្រាវជ្រាវជាមុនរួចមកហើយ។

*ជម្រើសទី ២៖* គ្រូជាអ្នកជ្រើសរើសការសម្ភាសដូចជាវិធីក្នុងការស្រាវជ្រាវ ប៉ុន្តែសិស្សបង្កើតសំណួរស្រាវជ្រាវដោយខ្លួនឯង *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។ នេះជាសម្រើសដ៏ល្អបំផុតសម្រាប់គ្រូ និងសិស្សដែលមានអារម្មណ៍មិនសូវមានទំនុកចិត្តក្នុងបង្កើតសំណួរស្រាវជ្រាវសមរម្យសម្រាប់មាតិកា និងប្រធានបទជាក់លាក់ ហើយធ្លាប់ធ្វើសកម្មភាពស្រាវជ្រាវរួចមកហើយ។

*ជម្រើសទី ៣៖* គ្រូផ្តល់តារាងសម្ភាសន៍ដែលបានបង្កើតរួចឱ្យសិស្ស។ នេះជាជម្រើសសម្រាប់គ្រូ និងសិស្សដែលទើបតែចាប់ផ្តើមធ្វើការជាមួយសកម្មភាពស្រាវជ្រាវ ហើយកំពុងអភិវឌ្ឍជំនាញទាំងនោះ។ សៀវភៅនេះផ្តល់តារាងសម្ភាសន៍សាមញ្ញមួយ ដែលសិស្សអាចប្រើប្រាស់បាន ប្រសិនបើជ្រើសរើសយកជម្រើសនេះ *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។

● នៅពេលដែលឧបករណ៍ស្រាវជ្រាវ និងប្រធានបទត្រូវបានបង្កើតរួចរាល់ហើយ គ្រូរៀបចំ ឱ្យសិស្សធ្វើការសម្ភាសន៍ក្នុងសហគមន៍។ គ្រូពិនិត្យមើលតារាងត្រួតពិនិត្យរបស់សិស្ស និងឆ្លើយទៅនឹងសំណួរផ្សេងៗ។ សិស្សត្រូវធ្វើការស្រាវជ្រាវនៅមុនមេរៀនបន្ទាប់ *(មើលសេចក្តីណែនាំសម្រាប់គ្រូ និងឯកសារសម្រាប់សិស្ស)*។

**បញ្ចប់មេរៀន** ១០ នាទី

គ្រូសួរសិស្សអំពីអារម្មណ៍របស់ពួកគេចំពោះការធ្វើការស្រាវជ្រាវ។ គ្រូប្រើប្រាស់រយៈពេល យ៉ាងតិច៥នាទី ដើម្បីឆ្លើយតបទៅនឹងសំណួរចុងក្រោយអំពីការស្រាវជ្រាវ ហើយជូនពរឱ្យពួកគេមានសំណាងល្អ។

## សេចក្តីណែនាំគ្រូ

### ថ្ងៃដែលមាន២៤ម៉ោង

● អ្នកអាចត្រូវការចំនួន ៨ក្រុម សម្រាប់សកម្មភាពនេះ យោងតាមចំនួនសិស្សក្នុងថ្នាក់។ ចូរប្រាកដថា យ៉ាងតិចណាស់មាន ៤ ក្រុម សម្រាប់ពិភាក្សានូវផ្នែកទាំងបួន។

● អានកំណត់ត្រាខាងក្រោមមុនពេលដែលបង្រៀន។ ប្រើប្រាស់គំនិតពីអត្ថបទ ដើម្បីជួយអ្នកក្នុងការដឹកនាំការពិភាក្សាអំពីតួនាទីយេនឌ័ររបស់បុរស និងនារី។ វាមានសារៈសំខាន់សម្រាប់លោកគ្រូ/អ្នកគ្រូ ក្នុងការបង្កើតគំនិត និងស្វែងយល់ពីអត្ថបទនេះដោយខ្លួនឯងជាមុន ព្រោះនឹងជួយអ្នកងាយចាប់បានពីគំនិតរបស់សិស្សក៏មានប្រយោជន៍ផងដែរក្នុងការពិភាក្សាគំនិតខាងក្រោមមួយចំនួនជាមួយមិត្តរួមការងារ ឬមិត្តភ័ក្តិ និងគ្រួសាររបស់អ្នក ព្រោះវាជួយអ្នកឱ្យអាចទទួលបានគំនិត និងយោបល់ជាច្រើន។

- ភាពខុសគ្នាផ្នែកជីវសាស្ត្ររវាងបុរស និងនារី ជាលក្ខណៈធម្មតាមិនផ្លាស់ប្តូរឡើយ។ ទោះបីជា យ៉ាងណាក៏ដោយលក្ខណៈដែលពួកគេទទួលបាន និងតួនាទី និងទំនួលខុសត្រូវ ដែលត្រូវបានចាត់ចែងទុកសម្រាប់ឱ្យពួកគេគឺអាស្រ័យលើសង្គម និងវប្បធម៌។
- វប្បធម៌ប្រែប្រួល! ឧទាហរណ៍៖ អ្វីដែលយើងជឿ និងអ្វីដែលបុរស និងនារីធ្វើនាពេលបច្ចុប្បន្ន គឺខុសប្លែកពីអ្វីដែលជីដូនជីតារបស់យើងជឿ ឬធ្វើ ព្រោះការផ្លាស់ប្តូរកើតឡើង ក្នុងសង្គម និងវប្បធម៌របស់យើង។
- តួនាទីរបស់បុរស និងនារី ដែលបានផ្តល់ទៅឱ្យពួកគេ អំពីមូលដ្ឋាននៃចរិតលក្ខណៈយេនឌ័រដែលទទួលបាន គឺជាញឹកញាប់សំដៅទៅរកការបែងចែកយេនឌ័រនៃការងារ។ នេះវាមានភាពខុសគ្នាឆ្ងាយពីការមើលលើអ្វីដែលមនុស្សប្រុស និងមនុស្សស្រីអាចធ្វើបាន ដោយពឹងផ្អែកលើជំនាញ និងសមត្ថភាពរបស់ពួកគេ។
- តួនាទីរបស់បុរស៖ ក្នុងសង្គមឧស្សាហកម្មជាច្រើនដូចជាប្រទេសអូស្ត្រាលី ការបែងចែងនៃការងាររវាងតួនាទីរបស់បុរសនិងនារី គឺមិនមានភាពដាច់ស្រេចក្នុងប្រទេសដែលមានឧស្សាហកម្មតិចតួច ដូចជាប្រទេសកម្ពុជា។ ក្នុងប្រទេសកម្ពុជា បុរស មានតួនាទីអាចមើលឃើញច្បាស់ និងទទួលស្គាល់ជាង។ បុរសមានទំនោរធ្វើការក្នុងផ្នែក**ការងារផលិតភាព** *(ការងារដែលបង្កើតប្រាក់ចំណូលនៅខាងក្នុងឬខាងក្រៅផ្ទះ)* និងធ្វើការងារផ្ទះ ឬការងារក្នុងគ្រួសារតិចតួច។ តួនាទីសហគមន៍របស់ពួកគេ គឺមានទំនោរទៅរកផ្នែកនយោបាយ ជាងតួនាទីរបស់មនុស្សស្រី ព្រោះពួកគេទទួលមុខដំណែងជាអ្នកដឹកនាំ និងជាអ្នកធ្វើការសម្រេចចិត្ត។ ឧទាហរណ៍ តាមរយៈរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាឃុំ។
- តួនាទីរបស់នារី ៖ នារីទំនងជាមានការងារ៣ប្រភេទ។ **ការងារផលិតភាព** ដូចបុរស។ **ការងារបន្តពូជ** ដែលរួមបញ្ចូលទាំង**ការងារផ្ទះ** ឬការងារក្នុងគ្រួសារទាក់ទងនឹងការបង្កើត និងការគ្រប់គ្រងកូន និងគ្រួសារ ហើយនិងការងារគ្រប់គ្រងសហគមន៍ដែលទាក់ទងនឹងការចាត់ចែងការងារអង្គភាពសហគមន៍ ជាជាងការដឹកនាំផ្នែកនយោបាយ ដូចបុរស។ ការងាររបស់មនុស្សស្រី តែងតែមិនទាក់ទងជាមួយនឹងប្រាក់ចំណូលឡើយ ដូច្នេះហើយជាញឹកញាប់មិនត្រូវបាន គេផ្តល់តម្លៃឱ្យ ដូចការងារចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់សហគមន៍ និងសង្គមឡើយ។
- ការបែងចែកយេនឌ័រនៃការងារអាចបង្ខូចទឹកចិត្តមនុស្សស្រីពីការស្វែងរកការងារដែលត្រូវបានគេយល់ថាជារបស់

"មនុស្សប្រុស" និងមនុស្សប្រុសពីការស្វែងរកការងារដែលត្រូវបានគេយល់ថាជារបស់ "មនុស្សស្រី"។ ឧទាហរណ៍មានមនុស្សស្រីតែពីរ ឬបីនាក់ ប៉ុណ្ណោះក្នុងតួនាទីជាក្រុមប្រឹក្សាឃុំ ហើយមានមនុស្សប្រុសតែពីរ ឬបីនាក់ប៉ុណ្ណោះដែលធ្វើការផ្ទះ។ នេះកម្រិតឱកាសនិងជម្រើសទាំងបុរស និងនារី ហើយបង្កើតសង្គមមួយដែលមិនអនុញ្ញាតឱ្យបុគ្គលមានការរីកចម្រើន និងបង្កើតសមត្ថភាពដែលមានតែមួយ របស់គាត់/នាង។

**សេចក្ដីសង្ខេបរបស់សកម្មភាពថ្ងៃដែលមាន២៤ម៉ោង អាចបញ្ចូលចំណុចខាងក្រោម៖**

- សកម្មភាពជាច្រើន ដែលបំពេញដោយមនុស្សស្រីសព្វថ្ងៃនេះគឺមិនត្រូវបានគេចាត់ទុកជាការងារឡើយ - ការមើលកូន ការចម្អិនម្ហូប មុខងារក្នុងផ្ទះ... - ព្រោះទាំងអស់នោះមិនពាក់ព័ន្ធនឹងប្រាក់ចំណូល។
- ពេលវេលារបស់មនុស្សស្រីត្រូវបានគេគិតថាមានតម្លៃតិចជាងពេលវេលារបស់បុរស ពីព្រោះពួកគេមិនបានរកប្រាក់ចំណូល នេះនាំឱ្យមានការគោរព និងផ្តល់តម្លៃតិចតួចឱ្យទៅស្ត្រីក្នុងសង្គម។
- នៅពេលស្ត្រីរកប្រាក់ចំណូល ពួកគេក៏ត្រូវបន្តធ្វើតួនាទីបន្តពូជថែមទៀត។ កត្តានេះអាចដាក់ស្ត្រីនៅកន្លែងមួយដែលនាំឱ្យស្រីមានពេលវេលាតិចតួច ដើម្បីចូលរួមក្នុងរចនាសម្ព័ន្ធ/តួនាទីសម្រេចចិត្តក្នុងគ្រួសារ និងសហាគមន៍។
- ងាយស្រួលក្នុងការមិនយកចិត្តទុកដាក់អំពីតួនាទីរបស់ស្ត្រី ដែលមានធ្វើនៅ ក្នុងការជួយគាំទ្រ និងកសាងសេដ្ឋកិច្ចក្នុងតំបន់ និងសេដ្ឋកិច្ចជាតិ ព្រោះតែកង្វះភាពទទួលស្គាល់នៃតម្លៃរបស់តួនាទីទាំងបីរបស់ពួកគេ (តួនាទីផលិតភាព តួនាទីបន្តពូជ និងតួនាទី សហាគមន៍)។

**និយមន័យរបស់តួនាទីទាំងបី៖**

- *តួនាទីបន្តពូជ៖* ទំនួលខុសត្រូវពរពោះ និងអប់រំកូន និងកិច្ចការក្នុងផ្ទះដែលធ្វើដោយស្ត្រី ទាមទារឱ្យមានការធានាការថែទាំ និងក្រុមការងារបន្តពូជ។ នេះមិនត្រឹមតែរួម បញ្ចូល ការបន្តពូជផ្នែកជីវសាស្ត្រ ប៉ុន្តែក៏ជាការថែរក្សា និងការថែទាំនៃក្រុមការងារ *(ដៃគូបុរស និងកុមារដែលកំពុងធ្វើការ)* និងអនាគតនៃក្រុមការងារ *(ទារក និងការទៅសាលារបស់កុមារ)*។
- *តួនាទីផលិតភាព៖* ការងារដែលធ្វើបានទាំងបុរស និងនារីសម្រាប់ទទួលបានជាប្រាក់កម្រៃឬសប្បុរស។ វារួមបញ្ចូលទាំងការបង្កើតទីផ្សារជាមួយការផ្លាស់ប្តូរតម្លៃ និងការបង្កើតផ្ទះ និងការចិញ្ចឹមជីវិតជាមួយតម្លៃប្រើប្រាស់ពិតប្រាកដ ហើយនិងការផ្លាស់ប្តូរតម្លៃដែល មានសក្តានុពល។ សម្រាប់មនុស្សស្រីក្នុងការបង្កើតផ្នែកកសិកម្ម អាចគិតបញ្ចូលទាំងការងារជាកសិករឯករាជ្យ និងកម្មករយកប្រាក់ឈ្នួល។
- *តួនាទីគ្រប់គ្រងសហាគមន៍៖* សកម្មភាពទាំងឡាយណាដែលធ្វើដោយមនុស្សស្រីនៅក្នុងកម្រិតសហាគមន៍ដែលជាការពង្រីកតួនាទីបន្តពូជរបស់ពួកគេ ដើម្បីធ្វើឱ្យប្រាកដពីការ ផ្គត់ផ្គង់ និងការថែទាំធនធានដ៏កម្រនៃការប្រើប្រាស់រួមដូចជាទឹក ការថែទាំសុខភាព និងការអប់រំ។ នេះជាការងារស្ម័គ្រចិត្តដែលមិនទទួលបានប្រាក់កម្រៃធ្វើនៅពេលទំនេរ។
- *តួនាទីនយោបាយសហាគមន៍៖* សកម្មភាពទាំងឡាយណាដែលធ្វើដោយមនុស្សប្រុសនៅក្នុងកម្រិតសហាគមន៍ការរៀបចំកម្រិតនយោបាយផ្លូវការ ជាញឹកញាប់ជាមួយនឹងគ្រោងការងារនៃគោលនយោបាយជាតិ។ នេះជាការងារដែលទទួលបានប្រាក់កម្រៃ ដោយ ផ្ទាល់ ឬដោយប្រយោល តាមរយៈអំណាច ឬតំណែង។

**ការរៀបចំសម្រាប់សកម្មភាពស្រាវជ្រាវ**

- គ្រូគួរតែសំដៅទៅសៀវភៅអ្នកបណ្តុះបណ្តាល LSS LLSP / សៀវភៅគ្រូ នឹងធ្វើការរំលឹកពីដំណើរការសម្រាប់ការស្រាវជ្រាវក្នុងសហាគមន៍។ ការណែនាំដែលបានដាក់បញ្ចូលក្នុងផ្នែកនេះ គឺបានដកស្រង់ចេញពីសៀវភៅនោះ។

ពន្យល់ទៅកាន់សិស្សថា គោលបំណងរបស់កម្មវិធីបំណិនជីវិត គឺដើម្បីបង្កើតចំណេះដឹង និង ជំនាញរបស់យើង ដូច្នេះ

យើងត្រៀមឱ្យបានល្អប្រសើរនិងដឹងអំពីឧបសគ្គ ដែលយើងនឹងប្រឈមក្នុងជីវិត។ ឧបសគ្គមួយក្នុងចំណោមឧបសគ្គដែលយើងប្រឈម គឺការយល់ឃើញ និងឥរិយាបថអំពីយេនឌ័រ និងឥទ្ធិពលដែលពួកវាអាចមានមកលើរបៀបដែលយើងគិត និងការប្រព្រឹត្ត។ ប្រសិនបើយើងប្រឈមជាមួយឧបសគ្គទាំងនេះ នោះវានឹងជួយយើងក្នុងការរៀនបន្ថែមទៀត អំពីប្រធានបទ។ នេះគឺជាអ្វីដែលយើងបាននឹងកំពុងតែធ្វើ។ ទោះបីជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ផងដែរសម្រាប់យើងក្នុងការរៀនបន្ថែមទៀត អំពីថាតើ មនុស្សដទៃគិតយ៉ាងដូចម្ដេចពីប្រធានបទ។ ឧទាហរណ៍ តើសមាជិក សហគមន៍គិតថា មនុស្សស្រីត្រូវបានគេរើសអើងឬទេ? តើពួកគេគិតថា ស្ត្រីមានឱកាសតិចជាងបុរស ទាក់ទងនឹងលទ្ធភាពការងារទេ? ដើម្បីឱ្យយើងសិក្សាពីសមាជិកសហគមន៍ យើងត្រូវបង្កើតវិធីដើម្បីស្វែងរកព័ត៌មានពីពួកគេ។ នេះហៅថា ការស្រាវជ្រាវ។ វាមានការចាំបាច់ក្នុងការរៀបចំកម្រងសំណួរមុនពេលដែលសិស្សទៅសហគមន៍ ដូច្នេះពួកគេនឹងដឹងច្បាស់ពីអ្វីដែលពួកគេនឹងស្វែងយល់ពីសហគមន៍។

**វិធីសាមញ្ញក្នុងការបង្កើតកម្រងសំណួរ៖**

● រំលឹកពីបញ្ហាដែលបានពិភាក្សាក្នុងម៉ោងមុន ហើយរំលេចពីខ្លឹមសារ និងគំនិតសំខាន់ៗដែលបានលេចចេញពីការត្រិះរិះពិចារណាដើម្បីរកគំនិតថ្មី។

● បង្កើតផែនទីគំនិត អំពីប្រធានបទដោយប្រើប្រាស់ខ្លឹមសារ និងគំនិតសំខាន់ៗ។ ផែនទីគំនិតត្រូវបានបង្កើតឡើងដោយការដាក់ប្រធានបទសំខាន់នៅលើក្ដារខៀន និងឱ្យសិស្សឡើងមកសរសេរជុំវិញប្រធានបទ នូវអ្វីដែលពួកគេបានដឹងអំពីប្រធានបទនោះ*(មើលឧទាហរណ៍ខាងក្រោម)*។




● ប្រើផែនទីគំនិត ដើម្បីជួយសិស្សបង្កើតវត្ថុបំណងរបស់ការស្រាវជ្រាវសម្រាប់ការស្រាវ ជ្រាវសហគមន៍។ អ្នកអាចប្រើប្រាស់ប្រយោគដែលសិស្សត្រូវបំពេញនៅខាងចុង ដើម្បីជាការណែនាំពួកគេ ឬអ្នកអាចទុកកិច្ចការឱ្យពួកគេជាអ្នកធ្វើដោយខ្លួនឯង *(មើលឧទាហរណ៍នៃប្រយោគខាងក្រោម)*។ ទោះបីជាយ៉ាងណាក៏ដោយ ចូរប្រាកដថា វត្ថុបំណងនៃការស្រាវជ្រាវអាចសម្រេចបាន ដោយការប្រមូលទិន្នន័យពីសហគមន៍។

● បន្ទាប់មកឱ្យសិស្សនឹកគិតសំណួរយ៉ាងច្រើនបំផុត ១០សំណួរ ដែលទាក់ទងនឹងវត្ថុ បំណង។

● សកម្មភាពនេះអាចធ្វើជាក្រុមតូចៗ ឬជាមួយសិស្សទាំងអស់។ ប្រសិនបើនៅក្នុងក្រុមតូចនីមួយៗត្រូវបង្ហាញពីសំណួររបស់ពួកគេទៅកាន់មិត្តរួមថ្នាក់ទាំងអស់ហើយសមាជិកដទៃទៀតសួរសំណួរ។ ក្រុមអាចធ្វើការកែសម្រួលសំណួររបស់ពួកគេស្របទៅតាមនោះ។

ប្រយោគឧទាហរណ៍៖

ក) នៅចុងបញ្ចប់នៃសកម្មភាពស្រាវជ្រាវ ខ្ញុំ/យើងនឹងដឹងបន្ថែមទៀតអំពីរបៀបដែលសហគមន៍គិតអំពី...

ខ) នៅចុងបញ្ចប់នៃសកម្មភាពស្រាវជ្រាវ ខ្ញុំ/យើងនឹងដឹងបន្ថែមទៀតអំពីរបៀបដែលបង្ហាញពីបញ្ហានៃ...

គ) យើងចង់ស្វែងរកអំពី... នៅចុងបញ្ចប់នៃសកម្មភាព យើងនឹងមានព័ត៌មានគ្រប់គ្រាន់ដើម្បីឆ្លើយនឹងសំណួររបស់យើង។

● សិស្សនឹងធ្វើការសម្ភាសជាមួយសមាជិកសហគមន៍។ ការរៀបចំសម្រាប់ការសម្ភាសនឹងជួយឱ្យសិស្សដឹងយ៉ាងជាក់លាក់អំពីអ្វីដែលពួកគេនឹងត្រូវធ្វើក្នុងសហគមន៍ មូលហេតុដែលពួកគេត្រូវធ្វើកិច្ចការនេះ នរណាដែលពួកគេត្រូវសម្ភាស ទីកន្លែងដែលនឹងត្រូវធ្វើការសម្ភាស និងរបៀប ដែលពួកគេត្រូវរៀបចំលិខិតស្នាម។

**<u>គំរូកម្រងសំណួរ (ថ្នាក់ទី៧)</u>**

ប្រធានបទ: តួនាទី និងទំនួលខុសត្រូវរបស់បុរស និងស្ត្រី

វត្ថុបំណងការស្រាវជ្រាវ: នៅចុងបញ្ចប់នៃការស្រាវជ្រាវ យើងនឹងដឹងបន្ថែមទៀតអំពីការរំពឹងទុករបស់សមាជិកសហគមន៍ចំពោះតួនាទី និងទំនួលខុសត្រូវរបស់បុរស និងស្ត្រី។

កាលបរិច្ឆេទ:.............................

ទីកន្លែងសម្ភាស:...........................................................................................

តំណែង/មុខងាររបស់អ្នកផ្តល់ព័ត៌មាន:........................................................ (គ្មានឈ្មោះ)

ប្រុស/ស្រី

ការណែនាំ: ធ្វើការគួរសមជាមួយអ្នកផ្តល់ព័ត៌មាន និងពន្យល់ពីមូលហេតុដែលអ្នកធ្វើការសម្ភាសនិងរបៀបដែលអ្នកនឹងប្រើទិន្នន័យ។ ប្រាប់ពួកគេថា ឈ្មោះរបស់ពួកគេនឹងមិនត្រូវបានប្រើប្រាស់ទេ។ សួរពួកគេថាតើពួកគេសប្បាយចិត្តក្នុងការឆ្លើយសំណួររបស់អ្នក។ ប្រសិនបើជាពួកគេយល់ព្រម បន្តធ្វើការសួរសំណួរ។ ប្រសិនបើពួកគេមិនសប្បាយចិត្តក្នុងការឆ្លើយសំណួររបស់អ្នក អរគុណ ពួកគេសម្រាប់ពេលវេលា ហើយទៅស្វែងរកមនុស្សថ្មីទៀត។

ខ្ញុំនឹងអានឱ្យបញ្ជីតួនាទីនិងទំនួលខុសត្រូវខុសៗគ្នា។ ខ្ញុំចង់អោយអ្នកប្រាប់ខ្ញុំថាតើអ្នកបញ្ចូលពួកវាក្នុងផ្នែកបុរស នារី ឬក៏ទាំងពីរ។ វាគ្មានចម្លើយខុសឬត្រូវនោះទេ។ យើងគ្រាន់តែចង់សិក្សាពីគំនិតរបស់អ្នក។

| **តួនាទី/ទំនួលខុសត្រូវ** | **ប្រុស** | **ស្រី** | **ទាំងពីរ** |
|---|---|---|---|
| ការថែរក្សាកូន | | | |
| ជាសមាជិកក្រុមប្រឹក្សាឃុំ | | | |
| ជាប្រធានក្រុមប្រឹក្សាឃុំ | | | |
| ការចូលរួមក្នុងនយោបាយរបស់សហគមន៍ | | | |
| ការចម្អិនម្ហូប និងការសម្អាត | | | |
| ការរៀបចំព្រឹត្តិការណ៍សហគមន៍ | | | |
| ការធ្វើការសម្រេចចិត្តចំពោះថវិកាក្នុងគ្រួសារ | | | |
| ជួសជុលវត្ថុនៅក្នុងនិងជុំវិញផ្ទះ | | | |
| ការដេរប៉ាក់ | | | |
| រកប្រាក់ចំណូលជាទៀងទាត់/មានការងារជាប្រចាំ | | | |

## តារាងត្រួតពិនិត្យរបស់សិស្សសម្រាប់ធ្វើការស្រាវជ្រាវបែបសហគមន៍

**ត្រៀមការណ៍:**

- ចូរប្រាកដថាអ្នកមានការរៀបចំយ៉ាងល្អរួមបញ្ចូលទាំងសំណួរ អ្នកផ្តល់ព័ត៌មាន និងកំណត់ត្រាផ្សេងៗទៀតដែលអ្នកអាចនឹងត្រូវការដើម្បីធ្វើការសម្ភាស។
- ចូរប្រាកដថាអ្នកមិនមានសំណួរច្រើនពេល - ច្រើនបំផុតត្រឹម១០សំណួរ។
- ចូរប្រាកដថាម៉ោងសម្ភាសត្រូវបានកំណត់ ហើយអ្នកផ្តល់ព័ត៌មានកំពុងរង់ចាំអ្នក។
- ចូរប្រាកដថាអ្នកបានអនុវត្តសួរសំណួរ។
- ចូរប្រាកដថាអ្នកយល់ពីសំណួរទាំងអស់។
- ចូរប្រាកដថាអ្នកបានគិតអំពីរបៀបក្នុងការដោះស្រាយជាមួយផ្តល់ព័ត៌មានដែលមិនចេះគួរសម និងមិនចង់ឆ្លើយសំណួរ។
- ចូរប្រាកដថាអ្នកបានកំណត់តួនាទីនិងទំនួលខុសត្រូវរបស់ក្រុមសម្រាប់ដំណើរការសម្ភាស ប្រសិនបើមានសមាជិកច្រើននាក់។
- ចូរប្រាកដថាសមាជិកក្នុងក្រុមរបស់អ្នកមានទំនុកចិត្ត និងគ្មាននរណាម្នាក់មានសំពាធ ឬតប់ប្រមល់។

**កំឡុងពេល:**

- គោរពអ្នកផ្តល់ព័ត៌មាន ហើយនិងពន្យល់ពីគោលបំណងនៃការសម្ភាស។
- ពន្យល់ថា គ្មានចម្លើយខុស ឬត្រូវនោះទេ។ អ្នកចង់សិក្សាពីគំនិតរបស់ពួកគេ។
- ណែនាំសមាជិកក្រុមដល់អ្នកផ្តល់ព័ត៌មាន។
- ចាប់ផ្តើមការសម្ភាស ហើយសមាជិកក្រុមនីមួយៗបំពេញតួនាទី និងទំនួលខុសត្រូវតាមអ្វីដែលបានគ្រោងទុកកាលពីសកម្មភាពមុន។
- អរគុណអ្នកផ្តល់ព័ត៌មាន និងប្រាប់ពួកគេថា អ្នកនឹងប្រើទិន្នន័យដែលប្រមូលបាននេះដើម្បីបង្ហាញអំពីបញ្ហាដែលកំពុងពិភាក្សា។

**ក្រោយ:**

- ធ្វើការឆ្លុះបញ្ចាំងអំពីរបៀបដំណើរការនៃការសម្ភាស និងបង្កើតជាមេរៀនទុកសម្រាប់រៀន និងជាជំនួយរបស់អ្នកក្នុងការធ្វើការស្រាវជ្រាវលើកក្រោយ។
- ប្រសិនបើអ្នកមិនមានទិន្នន័យគ្រប់គ្រាន់ ឬទិន្នន័យមិនអាចទុកចិត្តបានចូរព្យាយាមធ្វើម្តងទៀត។ ចងចាំថា នេះគឺជាលើកទីមួយរបស់អ្នក ហើយគ្រូរបស់អ្នកនឹងជួយអ្នកក្នុងការរៀបចំវាឲ្យកាន់តែប្រសើរ សម្រាប់លើកក្រោយ។
- កុំអានសំណួរ និងចម្លើយពីអ្នកផ្តល់ព័ត៌មានរបស់អ្នក ព្រោះការធ្វើបែបនេះនឹងមានអារម្មណ៍ធុញទ្រាន់ និងខ្ជះខ្ជាយពេលវេលា។
- វិភាគលទ្ធផលរបស់អ្នក ដោយមានគ្រូជួយណែនាំអ្នក ហើយបន្ទាប់មករៀបចំសេចក្តីសង្ខេបពីលទ្ធផលរបស់អ្នក ដើម្បីចែករំលែកជាមួយមិត្តរួមថ្នាក់។
- សម្តែងនូវសេចក្តីអបអរសាទរចំពោះគ្នាទៅវិញទៅមកអំពីការធ្វើការស្រាវជ្រាវ។



# មេរៀនទី ៥: ការវិភាគនៅក្នុងសហគមន៍

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ក្ដារខៀន ដីស
- ផ្ទាំងក្រដាសធំ
- ហ្វឺតចំរុះពណ៌ ឬគូលរទៀន
- ស្កុត

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាចៈ

- ពន្យល់ពីការឆ្លើយតបរបស់សហគមន៍អំពីការរំពឹងទុករបស់តួនាទី និងទំនួលខុសត្រូវដែលទាក់ទងនឹងផ្នត់គំនិតយេនឌ័រ

## សេចក្ដីផ្ដើមៈ មើលក្នុងកញ្ចក់

🕑 ១៥ នាទី

✎ សរសេរពាក្យគន្លឹះ "ផលិតភាព" "បន្តពូជ" និង "សហគមន៍" នៅលើក្ដារខៀន។ ឱ្យសិស្សពន្យល់ពាក្យនីមួយៗដោយផ្អែកលើអ្វីដែលបានរៀនកាលពីមេរៀនមុនហើយបន្ទាប់មកលេងល្បែងទះក្ដារខៀន *(មើលសេចក្ដីណែនាំសម្រាប់គ្រូ)*។

👄 ពន្យល់ថា ក្នុងមេរៀននេះ ពួកគេនឹងពិនិត្យលើពីលទ្ធផលដែលបានពីកម្រងសំណួររបស់ពួកគេដែលបានរៀបចំកាលពីម៉ោងមុន ដោយប្រើប្រាស់ទិន្នន័យទាំងនោះបង្កើតជាផ្ទាំងរូបភាពធំមួយ។ បន្ទាប់ពីនេះ សិស្សទាំងអស់នឹងបង្កើតជាសកម្មភាពស្រាវជ្រាវតូចមួយទៀតដែលនឹងធ្វើនៅក្នុងសហគមន៍។

✎ សរសេរវត្ថុបំណងមេរៀននៅលើក្ដារខៀន។

## សកម្មភាពសំខាន់។

🕑 ៦៥ នាទី

តើពួកគេនិយាយអ្វីខ្លះ? - វិភាគទិន្នន័យ

✋ គ្រូឱ្យធ្វើការជាក្រុមដែលមានគ្នា ៥-៦នាក់ ហើយធ្វើការវិភាគលទ្ធផលរបស់ពួកគេ។

ដំបូងក្រុមនីមួយៗជ្រើសរើសអ្នកធ្វើបទបង្ហាញម្នាក់។ អ្នកធ្វើបទបង្ហាញនេះនឹងផ្ដល់មតិ យោបល់ពីលទ្ធផលនៃការងារក្រុមនៅចុងបញ្ចប់នៃកិច្ចការ។ បន្ទាប់មកក្រុមនីមួយៗយកកម្រងសំណួរចេញ ដើម្បីធ្វើការចាត់ប្រភេទនៃទិន្នន័យដែលបានប្រមូល ដើម្បីពិនិត្យមើលថាតើសមាជិកសហគមន៍គិតថាតួនាទី និងទំនួលខុសត្រូវណាខ្លះជារបស់មនុស្សប្រុស មនុស្សស្រី ឬទាំងពីរ។ សិស្សម្នាក់កត់ត្រាទម្រង់កម្រងសំណួរទៅលើផ្ទាំងក្រដាសធំ ហើយបំពេញតួលេខ ដោយប្រើប្រាស់លទ្ធផលដែលបានរកឃើញ។

ឧទាហរណ៍៖ នៅក្នុងក្រុមរបស់ពួកគេ ពួកគេរាប់ចំនួនមនុស្សប៉ុន្មាននាក់ដែលគិតថាការមើល ថែកូនជាតួនាទីរបស់បុរស *(បំពេញចំនួននេះ ក្នុងប្រអប់មនុស្សប្រុស)* ចំនួនមនុស្សប៉ុន្មាននាក់ដែលគិតថាការមើលថែកូនជាតួនាទីរបស់មនុស្សស្រី *(បំពេញចំនួននេះក្នុងប្រអប់មនុស្ស ស្រី)* និងចំនួនមនុស្សប៉ុន្មាននាក់ ដែលគិត ថា ការមើល ថែកូនជាតួនាទីរបស់មនុស្សទាំងពីរ *(បំពេញចំនួននេះក្នុងប្រអប់ទាំងពីរ)*។

| តួនាទី/ទំនួលខុសត្រូវ | ប្រុស | ស្រី | ទាំងពីរ |
|---|---|---|---|
| ការថែរក្សាកូន | | | |
| ជាសមាជិកក្រុមប្រឹក្សាឃុំ | | | |
| ជាប្រធានក្រុមប្រឹក្សាឃុំ | | | |
| ការចូលរួមក្នុងគណកម្មាធិការរបស់សហគមន៍ | | | |
| ការធ្វើម្ហូប និងការសម្អាត | | | |
| ការរៀបចំព្រឹត្តិការណ៍សហគមន៍ | | | |
| ការធ្វើការសម្រេចចិត្តចំពោះថវិកាក្នុងគ្រួសារ | | | |
| ជួសជុលវត្ថុនៅក្នុងនិងជុំវិញផ្ទះ | | | |
| ការដេរប៉ាក់ | | | |
| រកប្រាក់ចំណូលជាទៀងទាត់/មានការងារជាប្រចាំ | | | |

គ្រូសរសេរសំណួរខាងក្រោមនេះនៅលើក្ដារខៀន ខណៈដែលសិស្សកំពុងរាប់ទិន្នន័យរបស់ពួកគេ។ នៅពេលពួកគេ បញ្ចប់ការរាប់ទិន្នន័យ ឱ្យសិស្សពិភាក្សាដើម្បីឆ្លើយនឹងសំណួរនេះ។ អ្នកធ្វើបទបង្ហាញនឹងសង្ខេបចំណុចសំខាន់ៗ នៅពេលផ្ដល់មតិយោបល់ទៅកាន់មិត្ត រួមថ្នាក់ដទៃទៀត។

**សំណួរពិភាក្សា៖**

១. តើមានតួនាទី/ទំនួលខុសត្រូវដែលសមាជិកសហគមន៍ចូលរួមច្រើនជាមួយនឹងបុរស និងច្រើនជាមួយ មនុស្សស្រី ដែរឬទេ?

២. តើមានតួនាទីមួយចំនួនអាចត្រូវបានគេចាត់ថ្នាក់ជា ការងារផលិតភាព ការងារបន្តពូជ ឬការងារសហគមន៍ដែរឬទេ?

៣. ផ្អែកលើការឆ្លើយតបរបស់អ្នក តើការងារមួយណាក្នុងផ្នែកទាំងបីនេះពាក់ព័ន្ធជាមួយការងាររបស់មនុស្សស្រី? តើមួយណាពាក់ព័ន្ធជាមួយការងាររបស់មនុស្សប្រុសជាង?

៤. តើអ្នកគិតថាទាំងបុរស និងស្ត្រី អាច/មានសមត្ថភាពក្នុងការបំពេញតួនាទី និងទំនួលខុសត្រូវទាំងនោះ ទាំងផ្លូវកាយ និងផ្លូវចិត្តដែរឬទេ?

៥. តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលដល់ការឆ្លើយតបរបស់សមាជិកសហគមន៍ចំពោះផ្នែកតួនាទី និងទំនួលខុសត្រូវដែលមានលក្ខណៈជាបុរស និងនារី?

នៅពេលដែលពួកគេបានបញ្ចប់ការពិភាក្សាឱ្យក្រុមនីមួយៗឡើងមកធ្វើបទបង្ហាញពីចំណុចសំខាន់ៗពីការពិភាក្សារបស់ពួកគេដោយប្រើទិន្នន័យដែលបានរៀបរាប់ជាភស្តុតាង។

ប្រាប់ពួកគេឱ្យប្រើប្រាស់ទិន្នន័យនិងបទបង្ហាញពីក្រុមនីមួយៗ ដើម្បីបង្កើតជាសេចក្ដីសង្ខេបខ្លីមួយអំពីលទ្ធផលសំខាន់ៗ។ គ្រូណែនាំពួកគេអំពីដំណើរការ និងអាចចាប់ផ្ដើមជួយពួកគេជាមួយនឹងប្រយោគដូចខាងក្រោម៖
ទិន្នន័យដែលបានប្រមូលពីសហគមន៍របស់យើងបង្ហាញថា ...

- គ្មានចម្លើយខុសឬត្រូវទេនៅទីនេះ។ ប្រយោគនេះនឹងអាស្រ័យលើទិន្នន័យដែលប្រមូលបានដោយសិស្ស។

- ឱ្យសិស្សកត់ត្រាទុកនូវសេចក្តីសង្ខេបពីលទ្ធផលរបស់ពួកគេនៅក្នុងសៀវភៅរបស់ពួកគេ *(មើលគំរូសង្ខេបក្នុងសេចក្តីណែនាំសម្រាប់គ្រូ)*។

**ពួកគេមិនអាច.../បាទ(ចាស) ពួកគេអាច...**

ប្រាប់សិស្សថា គ្រូនឹងជួយពួកគេក្នុងការរៀបចំសម្រាប់សកម្មភាពស្រាវជ្រាវក្នុងសហគមន៍បន្ទាប់ទៀត។

គ្រូចែកក្តារខៀនជាពីរចំណែកស្មើគ្នា ហើយសរសេរពាក្យខាងក្រោមនៅលើក្តារខៀន។ បន្ទាប់មកឱ្យកត់ទុកក្នុងសៀវភៅរបស់ពួកគេ។

"ពួកគេមិនអាច..." "ពួកគេអាច..."

- ឱ្យសិស្សគិតអំពីការងារទាំងអស់ដែលពួកគេគិតថាក្មេងស្រីមិនអាចធ្វើបាន និងការងារ ដែលពួកគេអាចធ្វើបាន។ ពួកគេធ្វើជាបញ្ជីមួយអំពីការងារទាំងនោះនៅក្នុងសៀវភៅ របស់ពួកគេក្រោមឃ្លាថា "ពួកគេមិនអាច..." ឬ "ពួកគេអាច..." ។
- ប្រាប់សិស្សឱ្យធ្វើដូចគ្នាសម្រាប់ក្មេងប្រុស។
- ប្រើបញ្ជីការងារដែលផ្តល់ឱ្យខាងក្រោមជាការណែនាំ ប្រសិនបើសិស្សពិបាកក្នុងការគិតរកដោយខ្លួនឯង។ សិស្សសម្រេចចិត្តថាតើផ្នែកណានៃក្តារខៀនដែលពួកគេគួរដាក់ សម្រាប់ទាំងក្មេងប្រុស និងក្មេងស្រី។

*គំរូការងារៈ*

*អ្នករត់ម៉ូតូ ជាងអគ្គិសនី គិលានុបដ្ឋាយិកា វេជ្ជបណ្ឌិត នាយករដ្ឋមន្ត្រី អ្នកទាត់បាល់អាជីព អ្នកបើកយន្តហោះ អ្នកអវកាស គ្រូបង្រៀន ប្រធានក្រុមប្រឹក្សាឃុំ រដ្ឋសភា សាស្ត្រាចារ្យ នៃមហាវិទ្យាល័យ អ្នកវិទ្យាសាស្ត្រ អ្នកមើលថៃក្មេង គ្រូមត្តេយ្យ ម្ចាស់រោងចក្រ ជាងម៉ាស៊ីន។*

- ពេលពួកគេបញ្ចប់ការបំពេញបញ្ជីរបស់ពួកគេ ពួកគេអាចចែករំលែកជាមួយមិត្តរួម ថ្នាក់ដទៃទៀត។
- ប្រសិនបើអំឡុងពេលពិភាក្សា សិស្សមានការមិនចុះសម្រុងនឹងគ្នា វាគឺមិនអីទេ ប៉ុន្តែត្រូវប្រាប់ពួកគេកុំឱ្យផ្លាស់ប្តូរបញ្ជីរបស់ពួកគេ។

គ្រូពន្យល់ប្រាប់សិស្ស អំពីរបៀបដែលពួកគេនឹងប្រើប្រាស់បញ្ជីការងារសម្រាប់សកម្មភាព ស្រាវជ្រាវបន្ទាប់ ដោយនិយាយថា សកម្មភាពស្រាវជ្រាវបន្ទាប់ ពួកគេត្រូវស្វែងរកឧទាហរណ៍នៃករណីពិសេស។ ឱ្យសិស្សម្នាក់ៗជ្រើសរើសការងារមួយដែលពួកគេនិយាយថា ក្មេងស្រីមិន អាចធ្វើបាន និងការងារមួយដែលពួកគេនិយាយថាក្មេងប្រុសមិនអាចធ្វើបានហើយបន្ទាប់មក ស្វែងរកករណីពិសេស។

ឧទាហរណ៍៖ ប្រសិនបើពួកគេនិយាយថាក្មេងស្រីមិនអាចក្លាយជាប្រធានក្រុមប្រឹក្សាឃុំពួកគេត្រូវតែស្វែងរកឧទាហរណ៍នៃប្រធានក្រុមប្រឹក្សាឃុំស្រី។ ឬក៏ពួកគេគិតថា ក្មេងប្រុសមិន អាចក្លាយជាគ្រូមត្តេយ្យ ពួកគេត្រូវស្វែងរកឧទារហេណ៍នៅកន្លែងណាដែលវាកើតឡើង។

ពន្យល់ទៅកាន់សិស្សថា ពួកគេអាចស្វែងរកករណីពិសេសតាមវិធីផ្សេងៗ។ ពួកគេអាចសួរ សមាជិកគ្រួសារ គ្រូ និងសមាជិកសហគមន៍ ប្រសិនបើពួកគេដឹងពីឧទាហរណ៍ក្នុងតំបន់នៃ ករណីពិសេសនោះ ពួកគេអាចស្រាវជ្រាវក្នុងបណ្ណាល័យសាលារៀន ឬពួកគេអាចប្រើ អ៊ីនធើណិត (ប្រសិនបើពួកគេអាចប្រើបាន)។

ឧទាហរណ៍នៃករណីពិសេសមិនចាំបាច់នៅ ក្នុងតំបន់របស់ពួកគេទេ។ ប្រាប់ពួកគេឱ្យចាប់ផ្តើមមើលជុំវិញក្នុងតំបន់ជាមុន បន្ទាប់មកពួកគេអាចប្រើប្រាស់ឧទាហរណ៍ថ្នាក់ជាតិ និងអន្តរជាតិបាន។

**បញ្ចប់មេរៀន** ១០ នាទី

គ្រូសួរសិស្សអំពីអារម្មណ៍របស់ពួកគេចំពោះការធ្វើការស្រាវជ្រាវ។ គ្រូប្រើប្រាស់រយៈពេល យ៉ាងតិច៥នាទី ដើម្បីឆ្លើយតបទៅនឹងសំណួរចុងក្រោយអំពីការស្រាវជ្រាវ ហើយជូនពរឱ្យ ពួកគេមានសំណាងល្អ។

កិច្ចការផ្ទះ

## សេចក្ដីណែនាំសម្រាប់គ្រូ

### សេចក្ដីផ្ដើម

- ប្រសិនបើអ្នកចង់លេងល្បែងទៈក្ដារខៀន នេះជាអ្វីដែលអ្នកត្រូវធ្វើ៖
  - ១. សរសេរពាក្យគន្លឹះចំនួន៣ពាក្យសម្រាប់តួនាទីយេនឌ័រនៅលើក្ដារខៀនជា ជួរដេកដោយទុកចន្លោះរវាងពាក្យនីមួយៗដើម្បីឱ្យសិស្សអាចរត់ និងទះពាក្យនីមួយៗ។ ឧទាហរណ៍៖ ផលិតភាព បន្តពូជ សហគមន៍
  - ២. រំកិលតុកៅអីដើម្បីឱ្យមានទីធ្លាគ្រប់គ្រាន់សម្រាប់សិស្សរត់ទៅក្ដារខៀន និងទះពាក្យនីមួយៗ។
  - ៣. ឱ្យសិស្សស្ម័គ្រចិត្តពីរនាក់មកលេង។ ឱ្យពួកគេឈរនៅឆ្ងាយបន្តិចពីក្ដារខៀន ហើយត្រៀមដើម្បីរត់ទៅក្ដារខៀន នៅពេលដែលអ្នកបានហៅតួនាទី/ទំនួលខុសត្រូវមួយ។
  - ៤. ពួកគេស្ដាប់តួនាទី/ទំនួលខុសត្រូវដែលអ្នកហៅ ហើយបន្ទាប់មកធ្វើការសម្រេចចិត្តថាវានៅក្នុងផ្នែកមួយណា។ ឧទាហរណ៍៖ ប្រសិនបើអ្នកនិយាយ "ការចម្អិនម្ហូប" ពាក្យដែលសិស្សគួររត់ទៅ ហើយទះគឺ បន្តពូជ។ សួរសិស្សពីមូលហេតុដែលពួកគេទះពាក្យនោះ ដើម្បីជួយពួកគេរំលឹកពីអត្ថន័យនៃពាក្យទាំងនោះ។

- ឧទាហរណ៍ពីតួនាទី/ទំនួលខុសត្រូវ៖

  តួនាទីបន្តពូជ៖ សកម្មភាពដូចជា មើលថែទាំក្មេង ទៅផ្សារ បោសសម្អាត ដងទឹក ឬរកអុស។

  តួនាទីផលិតភាព៖ សកម្មភាពដូចជា គ្រូបង្រៀន ម្ចាស់រោងចក្រ កម្មកររោងចក្រ ការងារ កសិដ្ឋានធ្វើស្រែចិញ្ចឹមជីវិត។

  តួនាទីគ្រប់គ្រងសហគមន៍៖ សកម្មភាពដូចជា ការចម្អិនម្ហូបសម្រាប់ព្រឹត្តិការណ៍សហគមន៍។

  តួនាទីនយោបាយសហគមន៍៖ សកម្មភាពដូចជា មេឃុំ ប្រធានភូមិ CCWC (មិនច្បាស់ថា តើនេះជាតួនាទីទទួលបានប្រាក់កម្រៃ - ប្រសិនបើមិនមែនទេ វាគួរតែនៅក្នុងសកម្មភាព មុន)។

**តើពួកគេនិយាយអ្វីខ្លះ? - វិភាគទិន្នន័យ**

ប្រើប្រាស់ការពិភាក្សាដើម្បីបង្កើតជាសេចក្ដីសង្ខេបនៃការវិភាគពីលទ្ធផល។ ការឆ្លើយតបចំពោះសំណួរនៃការពិភាក្សាគួរប្រាប់ផងដែរពីមូលដ្ឋានសម្រាប់ការរែកញែកសង្ខេប។ ខាងក្រោមនេះ គឺជាសេចក្ដីសង្ខេបគំរូ។ ការប្រើប្រាស់នេះដើម្បីណែនាំរបាយការណ៍សង្ខេបរបស់សិស្ស របស់អ្នកផ្ទាល់។

*គំរូនៃសេចក្ដីសង្ខេបក្នុងការពិភាក្សា៖*

*ទិន្នន័យដែលប្រមូលបានពីសហគមន៍របស់យើងបានបង្ហាញថា សមាជិកសហគមន៍ភាគច្រើនគិតថា តួនាទីរបស់មនុស្សស្រីគឺមើលថែរក្សាកូន ចម្អិនម្ហូប បោសសម្អាត និងការដេរប៉ាក់។ ដូច្នេះសមាជិកសហគមន៍ភាគច្រើនមានទាក់ទងការងារបន្តពូជជាមួយមនុស្សស្រី។ មនុស្សប្រុសច្រើនជាងស្ត្រី គឺទាក់ទងជាមួយការធ្វើការសម្រេចចិត្ត និងតួនាទីរកប្រាក់ចំណូល ដូច្នេះសមាជិកសហគមន៍ភាគច្រើនមានទាក់ទងការងារផលិតភាពជាមួយមនុស្សប្រុស។*

*ការឆ្លើយតបក៏បង្ហាញផងដែរថា សមាជិកសហគមន៍ទាក់ទងតួនាទីនយោបាយ សហគមន៍ និងការធ្វើការសម្រេចចិត្តជាមួយបុរស ប៉ុន្តែជាទូទៅសកម្មភាពសហគមន៍គឺទាក់ទងជាមួយមនុស្សស្រី។*

*យើងគិតថា លទ្ធផលទទួលរងឥទ្ធិពលដោយវប្បធម៌របស់យើងដែលបានដឹងនាំយើងឱ្យបង្កើតជាផ្នត់គំនិតអំពីអ្វីដែលមនុស្សស្រីអាចធ្វើបាន និងអ្វីដែលមនុសប្រុសអាចធ្វើបានក្នុងសង្គម។ យើងគិតថា បុរសនិងស្ត្រីអាចចែករំលែកតួនាទីទាំងបីនោះ - តួនាទីផលិតភាព តួនាទីបន្តពូជ និងតួនាទីសហគមន៍។*

# មេរៀនទី ៦: ផ្នត់គំនិត និង ភ្នែកទន្លាល់

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវនឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ក្ដារខៀន ដីស
- ផ្ទាំងក្រដាសធំ ស្កុត
- ហ្វឺតចំរុះពណ៌ ឬគូលរ័ទៀន
- ឯកសារដូចបានរៀបរាប់ខាងលើ

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាចៈ

- ពន្យល់ពីរបៀបនៃគំលាតយេនឌ័រ ក្នុងការងារជាផលប៉ះពាល់ដល់ប្រទេសឧស្សាហកម្មនៅលោកខាងលិច(អង់គ្លេស) ព្រមទាំងប្រទេសក្រីក្រនៅលោកខាងកើត(កម្ពុជា)។

## សេចក្ដីផ្ដើមៈ តើខ្ញុំគិតថាខ្លួនរបស់ខ្ញុំ គឺជានរណា ? 🕑 ១៥ នាទី

✋ គ្រូឱ្យសិស្សសង្ខេបអំពីអ្វីដែលពួកគេបានរៀនទាំង៥មេរៀនកន្លងមកនេះ។ ពួកគេអាចឡើង មកសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន។ នេះនឹងធ្វើឱ្យគ្រូអាចដឹងពីអ្វីខ្លះដែលពួកគេទទួលបាន។ គ្រូអាចប្រើឱកាសនេះដើម្បីរំលឹកពីចំណុចសំខាន់ៗដែលបានបង្រៀន។

👄 ប្រាប់ពួកគេថា ក្នុងមេរៀននេះពួកគេនឹងពិនិត្យមើលឧទាហរណ៍នៃការលើកលែងចំពោះច្បាប់ទម្លាប់ក្នុងលក្ខខណ្ឌការងារដែលជាផ្នត់គំនិតយេនឌ័រ។ ពួកគេនឹងពិភាក្សាលើឧទាហរណ៍ទាំងនោះទាក់ទងជាមួយភាពខុសប្លែកគ្នាក្នុងការងារនៃយេនឌ័រ ក្នុងស្រុក និងក្រៅប្រទេសដើម្បី ជួយពួកគេ ឱ្យយល់បានកាន់តែប្រសើរពីធម្មជាតិរបស់ពិភពលោកនៃភាពមិនស្មើគ្នាផ្នែកយេនឌ័រ។ ម្យ៉ាងទៀតទិន្នន័យដែលពួកគេប្រមូលបាននឹងធ្វើការវិភាគហើយប្រើប្រាស់ដើម្បីកំណត់ពីគំលាតនៃចំណេះដឹងរបស់យើងអំពីផ្នត់គំនិតយេនឌ័រ និងផលប៉ះពាល់លើការធ្វើការសម្រេចចិត្ត ក្នុងការចិញ្ចឹមជីវិតហើយចំណេះដឹងថ្មីទាំងអស់នេះនឹងជួយយើងឱ្យកំណត់ពីវិធី ក្នុងការបំបែកផ្នត់គំនិតយេនឌ័រ។

✏ សរសេរវត្ថុបំណងមេរៀននៅលើក្ដារខៀន។

## សកម្មភាពសំខាន់។ ⏲ ៦៥ នាទី

**តើអ្នកបានរកឃើញអ្វីខ្លះ? - វិភាគទិន្នន័យ**

ឱ្យសិស្សធ្វើការជាក្រុមដែលមានគ្នា ៦-៨នាក់។ ក្រុមនីមួយៗគួរតែមានទាំងក្មេងប្រុស និង ក្មេងស្រី។ បន្ទាប់មកឱ្យក្រុមនីមួយបង្កើតជាបញ្ជីនៃករណីលើកលែងដែលពួកគេគិតឃើញ ឬឧទាហរណ៍នៃបុរស និងស្ត្រីដែលបំបែកផ្នត់គំនិតនៃយេនឌ័រការងារ។

ឱ្យសិស្សពិភាក្សាពីលទ្ធផល និងសួរសំណួរអំពីឧទាហរណ៍/ករណីលើកលែងដែលពួកគេ ម្នាក់ៗគិតឃើញ។ លើកទឹកចិត្តសិស្ស ឱ្យស្តាប់គ្នាទៅវិញទៅមកដោយយកចិត្តទុកដាក់ និងប្រាប់ពួកគេថា ពួកគេនឹងមានកិច្ចការមួយនៅចុងបញ្ចប់នៃការពិភាក្សានេះ។

- ទុកពេលប្រហែល៣០នាទីឱ្យសិស្សធ្វើការជាក្រុម ហើយអ្នកត្រូវត្រួតពិនិត្យមើលយ៉ាងប្រុងប្រយ័ត្ន។
- នៅចុងបញ្ចប់នៃការពិភាក្សា ឱ្យក្រុមនីមួយៗជ្រើសរើសឧទាហរណ៍មួយ ដែលពួកគេបានឮ ហើយបង្ហាញយ៉ាងច្បាស់ពីផ្នត់គំនិត ដែលបង្កើតឡើងដោយឥទ្ធិពលនៃវប្បធម៌ និងអាចផ្លាស់ប្តូរបាន។ ពួកគេត្រូវពន្យល់ពីមូលហេតុដែលពួកគេ ជ្រើសរើសឧទាហរណ៍នេះ ហើយពួកគេក៏ត្រូវប្រាប់ផងដែរថា តើនោះជាឧទាហរណ៍ ក្នុងតំបន់ ក្នុងប្រទេស ឬអន្តរជាតិ។

ក្រោយពេលក្រុមនីមួយៗបានពន្យល់ពីករណីរបស់ពួកគេ សួរពួកគេថា តើវាមានភាពងាយស្រួលឬពិបាកដែរឬទេ ក្នុងស្វែងរកឧទាហរណ៍ ពាក់ព័ន្ធនឹងស្ត្រីដែលធ្វើការងារ ដែលត្រូវបានគេចាត់ថាជាការងារ "បុរស" ហើយនឹងឧទាហរណ៍ដែលបុរសធ្វើ ដែលគេចាត់ទុកថាជាការងាររបស់ "ស្ត្រី"។
បង្កើតការពិភាក្សាជុំវិញផលប៉ះពាល់នៃផ្នត់គំនិត ចំពោះឱកាសការងារសម្រាប់មនុស្សប្រុស និងមនុស្សស្រី *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។

**ភាពខុសប្លែកគ្នានៃយេនឌ័រក្នុងការងារ និងប្រាក់ឈ្នួល**
សួរសិស្សថា តើពួកគេគិតថាផ្នត់គំនិតយេនឌ័រ គឺកើតមាននៅតែក្នុងប្រទេសកម្ពុជា ឬក៏នៅក្នុងប្រទេសដទៃទៀតដែរ *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។

ប្រាប់សិស្សថា ពួកគេនឹងអានអត្ថបទអំពីគំលាតក្នុងការទទួលបានប្រាក់ឈ្នួលនៃយេនឌ័រ។ សួរពួកគេថានេះមានន័យយ៉ាងណា *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។

បែងចែកសិស្សជាពីរក្រុមធំ ហើយឱ្យក្រុមមួយអានអត្ថបទ "ក" អំពីប្រទេសកម្ពុជា និងក្រុមមួយទៀតអានអត្ថបទ "ខ" អំពីប្រទេសអង់គ្លេស។

ប្រាប់ពួកគេថា ពួកគេមានពេល២០នាទីក្នុងការអាន និងឆ្លើយសំណួរក្នុងនោះ។ ក្រោយពេលពួកគេបានអាន និងឆ្លើយសំណួររួច ឱ្យពួកគេធ្វើការជាដៃគូដែលម្នាក់បានអាន អត្ថបទ "ក" និងម្នាក់ទៀតបានអានអត្ថបទ "ខ"។

សិស្សម្នាក់ចាប់ផ្តើមចែករំលែកចម្លើយរបស់គេជាមួយសិស្សម្នាក់ទៀត។ នៅពេលគេបញ្ចប់ សិស្សម្នាក់ទៀតជាអ្នកចែករំលែកវិញ។ ទុកពេលឱ្យពួកគេប្រហែលជា២០នាទី ដើម្បីពិភាក្សាចម្លើយរបស់ពួកគេជាដៃគូ។ នៅចុងបញ្ចប់នៃការងារជាដៃគូ សួរសិស្សអំពីអ្វីដែលពួកគេបានរៀនពីអត្ថបទទាំងពីរនោះ *(មើលសេចក្តីណែនាំសម្រាប់គ្រូ)*។

**បញ្ចប់មេរៀន** ១០ នាទី

អនុញ្ញាតឱ្យសិស្សសួរសំណួរផ្សេងៗដែលពួកគេមាននៅក្នុងមេរៀនថ្ងៃនេះ។

## សេចក្តីណែនាំសម្រាប់គ្រូ

**តើអ្នកបានរកឃើញអ្វីខ្លះ? - វិភាគទិន្នន័យ**

- នៅចុងបញ្ចប់នៃសកម្មភាពនេះ សួរសិស្សថា តើពួកគេចងចាំពីសកម្មភាពដែលពួកគេបានធ្វើ កាលពីមេរៀនមុនដែរឬទេ នៅពេលដែលពួកគេកំណត់ការងារដែលមានតែបុរសឬស្ត្រីទើបអាចធ្វើបាន។ សួរពួកគេតើពួកគេអាចចាំបានដែរឬទេ ថាតើបុរសឬស្ត្រី មានជម្រើសការងារច្រើនជាងនៅក្នុងប្រភេទទាំងបី គឺៈ តួនាទីបន្តពូជ តួនាទីផលិតភាព និង តួនាទីសហគមន៍។
- ពន្យល់ប្រាប់ពួកគេថា ជាទូទៅ បុរសមានទំនោរនិងមានជម្រើសច្រើនជាងក្នុងលក្ខខណ្ឌនៃការ ធ្វើផ្នែកទាំងបី តួនាទីបន្តពូជ តួនាទីផលិតភាព និង តួនាទីសហគមន៍។
- យើងត្រូវបំបែកផ្នត់គំនិតនៃយេនឌ័រការងារ ដូច្នេះបុរសនិងស្ត្រីមានឱកាសស្មើភាពគ្នា និងធ្វើការសម្រេចចិត្តនៅពេលដែលត្រូវធ្វើការសម្រេចពីអ្វីដែលពួកគេចង់ធ្វើ ឬចង់ក្លាយទៅជាអ្វីមួយនៅពេលពួកគេបញ្ចប់ការសិក្សា។
- មធ្យោបាយមួយក្នុងការបំបែកឥទ្ធិពលនៃផ្នត់គំនិត គឺត្រូវសិក្សាបន្ថែមទៀតអំពីផលប៉ះពាល់នៃផ្នត់គំនិត និងយល់ពីទំហំនៃបញ្ហា។

**ភាពខុសប្លែកគ្នានៃយេនឌ័រក្នុងការងារនិងប្រាក់ឈ្នួល**

- អំឡុងពេលពិភាក្សា ត្រូវបញ្ចូលចំណុចខាងក្រោមៈ
  ១. មានកត្តាជាច្រើនដែលពន្យល់ខ្លះពីភាពខុសគ្នានៃគំលាតទទួលបានប្រាក់ឈ្នួលរវាងបុរសនិងនារីនៅក្នុងក្រុមការងារទូទាំងពិភពលោក។ សេដ្ឋកិច្ច ភូមិសាស្ត្រ ច្បាប់យុត្តិធម៌សង្គម វប្បធម៌ ប្រវត្តិសាស្ត្រ និងអារម្មណ៍ផ្ទាល់ខ្លួនគឺជាកត្តាដែលពន្យល់ពីមូលហេតុដែលមនុស្សប្រុសទំនងជាទទួលបានប្រាក់ឈ្នួលច្រើនជាងមនុស្សស្រី។
  ២. ភាពខុសប្លែកគ្នាក្នុងការអប់រំ ការហ្វឹកហ្វឺន បទពិសោធន៍ការងារ ជម្រើសមុខរបរ និងចំនួនម៉ោងធ្វើការរបស់បុគ្គលម្នាក់គឺអាចជាមូលហេតុដែលគំលាតទទួលបានប្រាក់ឈ្នួលមាននៅក្នុងយេនឌ័រ។
  ៣. គំលាតទទួលបានប្រាក់ឈ្នួលក៏ត្រូវបានរិះគន់ទៅលើការពិតដែលស្ត្រីជាមួយគ្រួសារទំនងជាបដិសេធការដំឡើងមុខដំណែង និងការទទួលបានប្រាក់ឈ្នួលខ្ពស់ ដើម្បីមានកាលវិភាគការងារដែលអាចបត់បែនបាន។
  ៤. ជាការងាយស្រួលក្នុងការរិះគន់គំលាតទទួលបានប្រាក់ឈ្នួលទាំងនោះចំពោះជម្រើសដែលមនុស្សស្រីបានជ្រើសរើសសម្រាប់គ្រួសាររបស់ពួកគេ ប៉ុន្តែសម្រាប់មនុស្សស្រីដែលមានកូនគឺធ្វើការជាងសព្វដង មុនពេលយកចិត្តទុកដាក់ជាមួយនឹងការបន្តការសិក្សា ការហ្វឹកហ្វឺន និងមុខរបររបស់ពួកគេ។ ដូច្នេះយើងក៏ត្រូវពិចារណាផងដែរថាជាបុព្វហេតុសម្រាប់គំលាតទទួលបានប្រាក់ឈ្នួល និងមើលពីរបៀបក្នុងការដោះស្រាយបញ្ហានេះ។

**អត្ថបទ "ក": ស្ថានភាពនៅក្នុងប្រទេសកម្ពុជា**

នៅក្នុងប្រទេសកម្ពុជា ស្ត្រីមានចំនួន៥៥ភាគរយនៃប្រជាជនវ័យជំទង់។ ៧១ភាគរយនៃស្ត្រី និងជិត៨០ភាគរយនៃបុរសដែលមានអាយុជាង១៥ឆ្នាំគឺការងារ និង៦០ភាគរយនៃក្មេងជំទង់គឺចូលរួមក្នុងផលិតកម្មកសិកម្ម (៦២ភាគរយនៃពួកគេគឺជាស្ត្រី)។ បុរសច្រើនជាងស្ត្រីធ្វើការនៅក្នុងការងារផ្នែកផ្លូវការ ហើយស្ត្រីមានចំនួនត្រឹមតែ២៣ភាគរយប៉ុណ្ណោះ នៃនយោជិតផ្នែកសាធារណៈទាំងអស់។ មានស្ត្រីតែមួយចំនួនតូចប៉ុណ្ណោះដែលបម្រើការក្នុងជួររដ្ឋាភិបាលទាក់ទងនឹងការរីកចម្រើននៃសេដ្ឋកិច្ច ហើយកាន់តែតិចតួចនៅក្នុងផ្នែកសេវាកម្មពង្រីកកសិកម្ម និងក្រុមចុះបញ្ជីដីធ្លី។ ជាមធ្យម ស្ត្រីទទួលបានប្រាក់ឈ្នួលតិចជាងបុរស៣០ភាគរយសម្រាប់ការងារដូចគ្នា និងធ្វើអោយកាន់តែឃើញខុសគ្នាសម្រាប់ស្ត្រីដែលមានកម្រិតការអប់រំខ្ពស់ជាង។ គម្លាតជាន់ប្រមាណរបស់ស្ត្រីចំពោះបុរសក្នុងការរកប្រាក់ចំនូលគឺ ០.៦៨។ វាកាន់តែពិបាកសម្រាប់ស្ត្រីជាជាងបុរសដើម្បីលើកឡើងនៅក្នុងមុខដំណែងភាពជាអ្នកដឹកនាំសហគ្រាស។

មានមូលហេតុជាច្រើនសម្រាប់គំលាតទទួលបានប្រាក់ឈ្នួល។ ស្ត្រីភាគច្រើនចំណាយពេលវេលាមួយចំនួនក្រៅការងារនៅពេលដែលកូនរបស់ពួកគេនៅតូចៗ នេះអាចមានន័យថា ពួកគេបាត់បង់ឱកាសដំឡើងដំណែង។ នយោជិកខ្លះមានអារម្មណ៍ថាការដំឡើងដំណែងបុរសគឺប្រសើរជាងស្ត្រី ជាពិសេសប្រសិនបើពួកគេគិតថាស្ត្រីចង់ចាប់ផ្តើមមានគ្រួសារ (ការរើសអើងដូចនេះគឺខុសច្បាប់)។ ទន្ទឹមនឹងនោះ ស្ត្រីទំនងជាធ្វើការក្នុងការងារដែលទទួលបានប្រាក់ឈ្នួលទាប។

**<u>សំណួរ:</u>**

1.តើនៅក្នុងប្រទេសកម្ពុជាមានបុរសវ័យជំទង់ច្រើនជាង ឬក៏ស្ត្រីវ័យជំទង់ច្រើនជាង? តើបុរសឬស្ត្រីដែលមានអាយុច្រើនជាង ១៥ឆ្នាំ ទំនងជាកំពុងធ្វើការឬ?

2.តើឧទាហរណ៍អ្វីដែលអត្ថបទបានផ្តល់ដើម្បីបង្ហាញការមិនស្មើភាពគ្នានៅកន្លែងធ្វើការក្នុងប្រទេសកម្ពុជា?

3.តើមូលហេតុអ្វីខ្លះដែលអត្ថបទបានផ្តល់អោយសម្រាប់គម្លាតទទួលបានប្រាក់ឈ្នួល?

4. តើអ្នកអាចគិតរកឃើញអ្វីផ្សេងទៀតទេ?

(ដកស្រង់ពីរបាយការណ៍វាយតម្លៃយេនឌ័រ USAID/កម្ពុជា ខែកញ្ញា ២០១០)





**អត្ថបទ"ខ": ស្ថានភាពនៅក្នុងប្រទេសអង់គ្លេស**

នៅដើមសតវត្សទី២០ ស្ត្រីភាគច្រើនមិនបានធ្វើការនៅខាងក្រៅផ្ទះទ្បើយ។ ក្នុងកំឡុងសង្គ្រាមលោកលើកទី១ និងទី២ ស្ត្រីធ្វើការនៅក្នុងរោងចក្រខិតខំដើម្បីបង្កើនផលិតផល។ បន្ទាប់ពីសង្គ្រាមលោកលើកទី២ ស្ត្រីជាច្រើនបានធ្វើការនៅខាងក្រៅផ្ទះ។ តាំពីពេលនោះមក ចំនួនស្ត្រីដែលធ្វើការចាប់ផ្តើមកើនទ្បើងបន្តិចម្តងៗ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ត្រីមិនទទួលបានភាពស្មើគ្នានៅកន្លែងធ្វើការនៅទ្បើយ។ បុរសកាន់កាប់មុខដំណែងសំខាន់ៗជាច្រើននៅក្នុងក្រុមហ៊ុន ហើយវាអាចមានការលំបាកដែលស្ត្រីទទួលបានការដំទ្បើងដំណែង។ ក្នុងទ្រឹស្តី វាមើលទៅដូចជាស្ត្រីអាចត្រូវបានគេដំទ្បើងដំណែងគ្រប់វិធីដើម្បីទៅដល់ដំណែងកំពូលរបស់ក្រុមហ៊ុនប៉ុន្តែការពិត ពួកគេត្រូវបានគេរាំងមិនអោយធ្វើរបៀបនេះ។ នៅក្នុងឆ្នាំ១៩៩៩ មធ្យមភាគស្ត្រីដែលធ្វើការពេញម៉ោងរកចំនួលបាន១៨% តិចជាងពេលវេលាមធ្យមភាគបុរសដែលធ្វើការពេញម៉ោង។ បុរសធ្វើការជាលក្ខណៈក្រៅម៉ោងរកចំនួលបាន៣៩% ច្រើនជាងស្ត្រីធ្វើការជាលក្ខណៈក្រៅម៉ោង។

មានមូលហេតុជាច្រើនសម្រាប់គម្លាតទទួលបានប្រាក់ឈ្នួល។ ស្ត្រីភាគច្រើនចំណាយពេលវេលាមួយចំនួនក្រៅការងារនៅពេលដែលកូនរបស់ពួកគេនៅតូច។ នេះអាចមានន័យថា ពួកគេបាត់បង់ឱកាសដំទ្បើងដំណែង។ និយោជិកខ្លះមានអារម្មណ៍ការដំទ្បើងដំណែងបុរសគឺប្រសើរជាងស្ត្រី ជាពិសេសប្រសិនបើពួកគេគិតថាស្ត្រីចង់ចាប់ផ្តើមមានគ្រួសារ (ការរើសអើងដូចនេះគឺខុសច្បាប់)។ ទន្ទឹមនឹងនោះ ស្ត្រីទំនងជាធ្វើការក្នុងការងារដែលទទួលបានប្រាក់ឈ្នួលទាប។

<u>**សំណួរ:**</u>

1.តើនៅពេលណាដែលស្ត្រីចាប់ផ្តើមធ្វើការនៅខាងក្រៅផ្ទះ នៅក្នុងប្រទេសអង់គ្លេស?

2.តើឧទាហរណ៍អ្វីដែលអត្ថបទបានផ្តល់ដើម្បីបង្ហាញការមិនស្មើភាពគ្នានៅកន្លែងធ្វើការក្នុងប្រទេសអង់គ្លេស?

3.តើមូលហេតុអ្វីខ្លះដែលអត្ថបទបានផ្តល់អោយសម្រាប់គំលាតទទួលបានប្រាក់ឈ្នួល?



4.តើអ្នកអាចគិតរកឃើញអ្វីផ្សេងទៀតទេ?

(ដកស្រង់ពីបញ្ហាការងារ - ដំណាក់កាលសំខាន់ទី៤ នៃឯកសាររបស់គ្រូអំពីការរិះរកផ្នែកនៃការងាររបស់ពលរដ្ឋ វិទ្យាស្ថានសម្រាប់ពលរដ្ឋ www.citizen.org.uk)



# មេរៀនទី ៧: ការបែងចែកផ្នត់គំនិត

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

🕮 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ក្ដារខៀន ដីស
- ផ្ទាំងក្រដាសធំ
- ហ្វឺតចំរុះពណ៌ ឬគូលរំទៀន
- កាសែតជាមួយការសម្ភាស
- ម៉ាស៊ីនថតសម្លេង និងថ្ម

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាចៈ

- បង្ហាញបទពិសោធន៍អំពីបុរសនិងស្ត្រីដែលទទួលយកតួនាទីមិនមែនជាប្រពៃណី។
- ផ្ដល់មូលហេតុសមរម្យសម្រាប់ស្ត្រីធ្វើការចិញ្ចឹមជីវិត ដែលវប្បធម៌ត្រូវបានចាត់ទុកជាមនុស្សស្រី និងផ្ទុយមកវិញ។

**សេចក្ដីផ្ដើម** 🕑 ១៥ នាទី

◈ គ្រូសួរសិស្សៈ តើអ្នកចងចាំអ្វីបានខ្លះកាលពីមេរៀនមុន?

✎ គ្រូសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន។

👄 គ្រូប្រើប្រាស់អ្វីដែលសិស្សបាននិយាយ ដើម្បីណែនាំពីមេរៀនថ្ងៃនេះដោយនិយាយថា ក្នុងមេរៀនថ្ងៃនេះ យើងនឹងពិនិត្យ លើឧទាហរណ៍ពិតៗនៃបុរសនិងស្ត្រី ដែលពិភាក្សាអំពីការងារដែលពួកគេមិនត្រូវបានរំពឹងទុកថាត្រូវធ្វើ ពីព្រោះតែឥទ្ធិពលនៃវប្បធម៌ និងផលប៉ះពាល់នៃផ្នត់គំនិតយេនឌ័រមកលើការសម្រេចចិត្តនៅក្នុងជីវិតរស់នៅ។

✋ ឱ្យសិស្សប្រាប់ពីការងារដែលជាធម្មតាស្ត្រីមិនធ្វើ ឬបុរសមិនធ្វើ។ *(នៅពេលដែលពួកគេ និយាយពីអ្នករត់ម៉ូតូឌុប កីឡាបាល់ទាត់ និងគ្រូមត្តេយ្យ សរសេរពាក្យទាំងនោះនៅលើ ក្ដារខៀន។ ប្រសិនបើពួកគេចំណាយពេលយូរពេក អ្នកអាចប្រាប់ពួកគេពីគំរូយខ្លះៗ ឬគ្រាន់តែឱ្យវិជ្ជាជីវៈដែលមេរៀននឹងផ្ដោតទៅលើការងារទាំងនោះ)*។

## សកម្មភាពសំខាន់។

៦៥ នាទី

### ការស្ដាប់អំពីការបំបែកផ្នត់គំនិត

*(មេរៀននេះ យកលំនាំតាមកម្រងឧបករណ៍បណ្ដុះបណ្ដាលគាំទ្រដោយក្រសួងកិច្ចការនារី និង GIZ " កម្រងឧបករណ៍បណ្ដុះបណ្ដាលសម្រាប់មនុស្សវ័យក្មេងស្ដីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ" ភ្នំពេញ ខែមីនា ២០១០។)*

គ្រូសួរសំណួរទៅកាន់សិស្សអំពីកីឡាបាល់ទាត់

- តើអ្នកទាំងអស់គ្នាលេងបាល់ទាត់ដែរឬទេ? *(សួរទាំងក្មេងប្រុសនិងក្មេងស្រី)*
- តើមានក្មេងស្រីប៉ុន្មាននាក់អ្នកលេងបាល់ទាត់? *(ឱ្យពួកគេលើដៃបង្ហាញ)*
- តើអ្នកគិតយ៉ាងដូចម្ដេចចំពោះក្មេងស្រីដែលលេងបាល់ទាត់? *(សួរក្មេងប្រុសនិងក្មេងស្រីហើយកត់ចំណាំគំនិតរបស់ពួកគេនៅលើក្ដារខៀន។ អ្នកអាចប្រើគំនិតទាំងនោះនៅពេលក្រោយ បន្ទាប់ពីពួកគេបានស្ដាប់កាសែតដើម្បីឱ្យឃើញថា តើពួកគេនៅតែមាន គំនិតដូចមុនឬទេ បន្ទាប់ពីបានស្ដាប់រួចមក។)*

គ្រូណែនាំពីសកម្មភាពដោយពន្យល់ថា សិស្សនឹងស្ដាប់ការសម្ភាសបីជាមួយមនុស្សដែលពាក់ព័ន្ធជាមួយក្រុមបាល់ទាត់ក្នុងខេត្តបាត់ដំបង។ ការសម្ភាសមួយគឺជាមួយ រស្មី អាយុ១៥ឆ្នាំដែលជាកីឡាករបាល់ទាត់ក្នុងក្រុម ម្នាក់ទៀតជាគ្រូបង្វឹកមានឈ្មោះថា មករា ហើយនិងចុងក្រោយជាគ្រូបង្វឹកក្រុមបាល់ទាត់ជាតិកម្ពុជា ឈ្មោះសេម។ ក្រុមមានឈ្មោះថា "ក្រុមបាល់ទាល់ខេត្តនៃ កម្មវិធីសលត៍ (SALT) ខេត្តបាត់ដំបង់។"

គ្រូសរសេរឈ្មោះទាំងនោះនៅលើក្ដារខៀន។

- គ្រូឱ្យសិស្សមើលសំណួរនៅលើក្ដារខៀន/ផ្ទាំងក្រដាសធំ *(មើលឯកសារចែកសិស្ស)*។ ពិនិត្យ ការយល់ដឹងអំពីសំណួររបស់សិស្ស។ បន្ទាប់មកចាក់ការ សម្ភាសលើកទីមួយ ចំនួនម្ដង។
- បន្ទាប់ពីការស្ដាប់លើទីមួយ ឱ្យសិស្សពិភាក្សាជាដៃគូ។ ចាក់ការសម្ភាសជាលើកទីពីរ ប្រសិនបើចាំបាច់ ហើយបន្ទាប់មកធ្វើការពិភាក្សាពីចម្លើយជាមួយគ្នា។
- អនុវត្តដូចខាងលើសម្រាប់ការសម្ភាសទីពីរ និងទីបី។

នៅចុងបញ្ចប់នៃការពិភាក្សាបន្ទាប់ពីការសម្ភាសទីបី ធ្វើសេចក្ដីសន្និដ្ឋានដោយប្រើប្រាស់ការ ឆ្លើយតបរបស់សិស្ស *(មើលសេចក្ដីណែនាំសម្រាប់គ្រូសម្រាប់ចំណុចសំខាន់ៗដែលគួរទទួលបានបន្ទាប់ពីការស្ដាប់)*។ សំដៅទៅលើគំនិតរបស់សិស្ស អំពីការលេងបាល់ទាត់របស់ក្មេងស្រីដែលនៅលើក្ដារខៀន សួរពួកគេថា តើពួកគេយល់ស្រប ឬមិនយល់ស្របជាមួយគំនិតទាំងនោះ។



### ការអានអំពីការបំបែកផ្នត់គំនិត

គ្រូប្រាប់សិស្សថា ឥឡូវពួកគេមានឧទាហរណ៍ពិតប្រាកដមួយអំពី មនុស្សដែលផ្លាស់ប្ដូរផ្នត់គំនិត យេនឌ័រ នូវអ្វីដែលក្មេងប្រុសឬក្មេងស្រីគួរ ឬ មិនគួរធ្វើសម្រាប់ការចិញ្ចឹមជីវិត ។ ពន្យល់ថាពួកគេនឹងពិនិត្យមើលឧទាហរណ៍ពីរទៀត អំពីមនុស្សពិតប្រាកដដែលបំបែក/ផ្លាស់ប្ដូរផ្នត់គំនិតក្នុងសង្គម។

✋ បែងចែកសិស្សក្នុងថ្នាក់ជាពីរក្រុម។ ផ្ដល់អត្ថបទ និងសំណួរ អំពី អ៊ុំ ចាន់ថន អ្នករត់ម៉ូតូឌុប ឱ្យទៅសិស្សក្រុមមួយ ហើយក្រុមមួយទៀត ឱ្យអត្ថបទអំពី លួង ត្រុងប៊ិញ និង ង្វយិន ថាយលួង គ្រូមត្តេយ្យ *(មើលឯកសារសម្រាប់សិស្ស សម្រាប់ថតចម្លង)*។

👄 ប្រាប់សិស្សថា ពួកគេត្រូវឆ្លើយសំណួរដោយប្រើប្រាស់ព័ត៌មាននៅក្នុងអត្ថបទ។ នៅពេលដែលសិស្សបញ្ចប់ការឆ្លើយសំណួរ ឱ្យសិស្សធ្វើការជាដៃគូដែលបានអានអត្ថបទខុសគ្នា ដើម្បីធ្វើការចែករំលែក រឿងដែលពួកគេបានអាន និងពិនិត្យមើលចម្លើយជាមួយគ្នា។

◈ នៅពេលដែលសិស្សបានចែករំលែកចម្លើយរបស់ពួកគេរួច ឱ្យសិស្សទាំងអស់គិតអំពីសំណួរចុងក្រោយៈ "តើអ្វីខ្លះដែលមនុស្សនៅក្នុងរឿងមានដូចគ្នា?" *(មើលសេចក្ដីណែនាំសម្រាប់គ្រូ)*។

## បញ្ចប់មេរៀនៈ រៀបចំគំនិតរបស់ខ្ញុំ

🕑 ១០ នាទី

👄 គ្រូប្រាប់សិស្សថា នៅមេរៀនបន្ទាប់ ពួកគេនឹងរួមបញ្ចូលគ្នានូវអ្វីគ្រប់យ៉ាងដែលពួកគេបាន រៀនតាំងពីដើមរហូតមកដល់ពេលនេះ និងប្រើប្រាស់ចំណេះដឹងថ្មីនេះ ដើម្បីបង្កើតជាផ្ទាំងក្រដាសធំអំពីការលើកកម្ពស់ការយល់ដឹង។

✏ ដើម្បីជួយពួកគេ ក្នុងការចាប់ផ្ដើមត្រៀមរៀបចំសម្រាប់មេរៀនបន្ទាប់ គ្រូសរសេរអត្ថបទខាងក្រោម នៅលើក្ដារខៀន ហើយឱ្យសិស្សកត់ត្រាទុកក្នុងសៀវភៅរបស់ពួកគេ។

*ខ្ញុំចង់ប្រាប់មនុស្សនៅក្នុងគ្រួសារ សហគមន៍ និងសាលារៀនរបស់ខ្ញុំអំពីផលប៉ះពាល់របស់ជំនឿ មួយចំនួននៅក្នុងសង្គម មកលើការសម្រេចចិត្តក្នុងជីវិតរបស់យើង។ ការសម្រេចចិត្តទាំងនោះ ទទួលឥទ្ធិពលពីជំនឿយេនឌ័ររបស់យើង អំពីអ្វីដែលក្មេងស្រីអាចធ្វើ ហើយអ្វីដែលក្មេងប្រុសអាចធ្វើ គឺមិនមែនដោយសារអ្វីដែលយើងអាចធ្វើបានពិតប្រាកដនៅក្នុងភាពជាក់ស្ដែងនោះទេ។ ខ្ញុំចង់ផ្លាស់ប្ដូរឥរិយាបថនេះ ដូច្នេះខ្ញុំអាចធ្វើការសម្រេចចិត្តអំពីការចិញ្ចឹមជីវិត នាពេលអនាគតរបស់ខ្ញុំដោយផ្អែកលើខ្ញុំជានរណាដែលជាមនុស្សពិត ដោយមិនផ្អែកលើឥទ្ធិពលរបស់អ្នកដទៃមកលើខ្ញុំ ជាអ្វីដែលជាផ្នត់គំ និតយេនឌ័រនោះទេ។ ផ្អែកលើអ្វីដែលខ្ញុំបានរកឃើញ ដើម្បីជួយមនុស្សឱ្យផ្លាស់ប្ដូរឥរិយាបថរបស់ពួកគេ ខ្ញុំគិតថាពួក គេគួររៀន/ដឹងបន្ថែមទៀត...។*

## សេចក្តីណែនាំសម្រាប់គ្រូ

### ការបំបែកផ្នត់គំនិត

● ប្រសិនបើ អ្នកគ្មានឧបករណ៍សម្រាប់ចាក់សម្លេង "ម៉ាញេ/cd" បាន។ ក្នុងករណីនោះ អ្នកអាចរំលងសកម្មភាពនេះទៅធ្វើសកម្មភាពអាន។ ប៉ុន្តែអ្នកត្រូវគិតរកសកម្មភាពអ្វីដើម្បីបំពេញរយៈ៣៥នាទី ជំនួសសកម្មភាពនេះវិញ។

● ប្រសិនបើ អ្នកអាចប្រើម៉ាញេ អ្នកត្រូវស្តាប់មុនពេលបង្រៀនដើម្បីឱ្យដឹងពីចម្លើយរបស់ សំណួរ។

● សេចក្តីសង្ខេបគំនិតសំខាន់ដែលត្រូវបញ្ចូលក្នុងការពិភាក្សាៈ មានបញ្ហាចម្បង៣យ៉ាង ដែលបានលើកលើង ក្នុងការសម្ភាសនេះ

*(មេរៀននេះយកលំនាំតាមកម្រងឧបករណ៍បណ្តុះបណ្តាលគាំទ្រដោយក្រសួងកិច្ចការនារី និង GIZ "កម្រងឧបករណ៍បណ្តុះបណ្តាលសម្រាប់មនុស្សវ័យក្មេង ស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ" ភ្នំពេញ ខែមីនា ឆ្នាំ២០១០។)*

ក. *ជំនឿអំពីតួនាទីយេនឌ័ររបស់ក្មេងស្រីៈ* មនុស្សជាច្រើនគិតថា វាមិនត្រឹមត្រូវដែលក្មេងស្រីលេងបាល់ទាត់ពីព្រោះវាជាល្បែងកំសាន្តរបស់ក្មេងប្រុស។ នៅពេលក្មេងស្រីលេងបាល់ទាត់ ពួកគេគិតថាវាមិនធម្មតាសោះ។ សូម្បីមនុស្សមួយចំនួនមានជំនឿថា ប្រសិនបើក្មេងស្រីលេង បាល់ទាត់ វាអាចបណ្តាលឱ្យពួកនាងគ្មានកូនក្នុងពេលអនាគត។ ជំនឿរបៀបនេះបានបង្កើតជាការរំពឹងទុកដែលក្មេងស្រីមិនគួរលេងបាល់ទាត់ ឬក៏ល្បែងកំសាន្តថាមពល។ ទោះបីជាយ៉ាងណាក៏ដោយ ជំនឿទាំងនោះគឺផ្អែកលើគំនិតរបស់សង្គម ហើយមិនមែនជាធម្មជាតិទេ។ ខ្លួនប្រាណ និងចិត្តរបស់ក្មេងស្រីក៏អាចទទួលបានប្រយោជន៍ ពីការលេងកីឡាច្រើនដូចក្មេងប្រុសដែរ។

ខ. *ផលប្រយោជន៍ចំពោះក្មេងស្រីៈ* ក្មេងស្រីបង្កើតភាពជិតស្និទ្ធជាមួយមិត្តក្នុងក្រុមរបស់ពួកគេជាង បង្កើតទំនុកចិត្តនិងរៀនធ្វើការជាក្រុមនិងជួយគាំទ្រគ្នាជាង។ ពួកគេទទួលបានផល ប្រយោជន៍ពីការហាត់ប្រាណ ហើយពួកគេក៏មានរបៀបបញ្ចេញអារម្មណ៍ និងមនោសញ្ចេតនា របស់ពួកគេ។ គ្រូបង្វឹកក៏មានផលប្រយោជន៍ពីបទពិសោធន៍និងបានបង្កើតទំនុកចិត្ត និង ជំនាញភាពជាអ្នកដឹកនាំ។ ក្រុមទាំងមូលទទួលបានការគោរពនិងអារម្មណ៍មោទនភាព មានតម្លៃ និងមានសិទ្ធស្មើគ្នា។

គ) *ការផ្លាស់ប្តូរវិយាបថអំពីតួនាទីយេនឌ័រៈ* ក្មេងស្រីមានអារម្មណ៍ខ្មាសអៀន និងស្ទាក់ស្ទើរ ពេលលើកដំបូង។ នៅពេលវ័យជំទង់ (មករា សំ និងគ្រូៗរបស់ពួកគេ) ចាប់ផ្តើមគាំទ្រពួកគេ ពួកគេមានអារម្មណ៍ថាមានទំនុកចិត្តជាងមុន។ ពួកគេក៏កាន់តែមានទំនុកចិត្ត ខណៈដែលពួកគេទទួលបានផលប្រយោជន៍ពីការលេងបាល់ទាត់។ បងប្អូន និងអ្នកដទៃចាប់ផ្តើមគាំទ្រពួកគេ ខណៈដែលពួកគេបានឃើញពីផលប្រយោជន៍ចំពោះក្មេងស្រី និងនៅពេលដែលក្មេងស្រីទទួលបានកិត្តិយស និងភាពល្បីល្បាញសម្រាប់ប្រទេសកម្ពុជា និងខ្លួនរបស់ពួកគេផ្ទាល់។ បុរសដែលធ្លាប់ចម្អកឱ្យពួកគេក៏ផ្លាស់ប្តូរចិត្តរបស់ពួកគេផងដែរ នៅពេលបានឃើញពីរបៀបដែលក្មេងស្រីលេង។

### ការអានអំពីការបំបែកផ្នត់គំនិត

● គោលបំណងនៃសកម្មភាពនេះគឺដើម្បីបង្ហាញសិស្សថា មានឧទាហរណ៍អំពីមនុស្សជាច្រើនដែលបានបំបែកផ្នត់គំនិតយេនឌ័រ។ អ្វីដែល ចាន់តុន និងគ្រូទាំងពីរមកពីប្រទេសវៀតណាមមានដូចគ្នានោះ គឺពួកគេមានតួនាទីដែលប្រពៃណីត្រូវបានគេគិតថា ជាការងាររបស់ "ភេទផ្ទុយពីនោះ"។

- ចំណុចសំខាន់ខ្លះដែលអ្នកអាចបញ្ចូលក្នុងការពិភាក្សាចុងក្រោយៈ
  - ផ្នត់គំនិតអាចបំបែកបាន ព្រោះពួកវាត្រូវបានបង្កើតឡើងដោយសង្គម។ ក្នុងន័យមួយ ទៀត ពួកវាមិនមែនផ្អែកលើវិធីដែលយើងបានធ្វើឬផ្អែកលើភេទរបស់យើង។ ផ្នត់គំនិតគឺពឹងផ្អែកលើអ្វីដែលមនុស្សជឿចំពោះគំនិតវប្បធម៌ និងប្រពៃណី។
  - ពេលខ្លះ ជំនឿវប្បធម៌ទាំងនោះបញ្ឈប់យើងពីអ្វីដែលយើងចង់ធ្វើ ឬត្រូវធ្វើ។ឧទាហរណ៍៖ ចាន់ថនត្រូវការផ្គត់ផ្គង់គ្រួសារ។ មធ្យោបាយល្អបំផុតដែលនាងអាចធ្វើគឺការធ្វើការជា អ្នករត់ម៉ូតូឌុប។ ប្រសិនបើស្តាប់ជំនឿប្រពៃណីដែលនិយាយថា ការងារប្រភេទនេះគឺ សម្រាប់តែបុរស នាងនឹងពិបាកក្នុងការស្វែងរកវិធីមកផ្គត់ផ្គង់គ្រួសាររបស់នាង បន្ទាប់ពី នាងបានលែងលះគ្នា។
  - ក្នុងករណីរបស់គ្រូបង្រៀនមកពីវៀតណាមទាំងពីរនាក់ ពួកគេទាំងពីរមានបេះដូងនិងចំណាប់អារម្មណ៍ក្នុងការបង្រៀន និងធ្វើការជាមួយក្មេងៗ។ ប្រសិនបើគេ ធ្វើតាមគំនិតវប្បធម៌ ពួកគេប្រហែលជាមិនមាន ឱកាសធ្វើការក្នុងជំនាញវិជ្ជាជីវៈដែល ពួកគេស្រលាញ់ និងដែលអនុញ្ញាតឱ្យពួកគេរីកលូតលាស់ និងអភិវឌ្ឍក្នុង ភាពជាមនុស្សទេ។
  - ការបំបែកផ្នត់គំនិតគឺមិនងាយស្រួលទេ - អ្នកត្រូវតែជាមនុស្សរឹងមាំជាមួយបំណងប្រាថ្នាខ្លាំងក្លា ដើម្បីធ្វើអ្វីដែលអ្នកជឿជាក់។ ប៉ុន្តែរឿងទាំងនេះបានប្រាប់យើងថា វាអាចធ្វើបាន!

<u>**សំណួរ: ការសម្ភាសទីមួយជាមួយ ស្មី**</u>

1.តើនាងនិយាយអ្វីខ្លះអំពីការលេងបាល់ទាត់? តើនាងចូលចិត្តវាឬទេ? តើវាល្អសម្រាប់នាងទេ? តើវាមានផលប្រយោជន៍យ៉ាងដូចម្តេចចំពោះនាង?

2.តើបងប្អូនរបស់នាងគិតអ្វីខ្លះ នៅពេលពួកគេបានឮជាលើកដំបូង អំពីការលេងបាល់ទាត់របស់អ្នក?

3.តើពេលក្រោយមកពួកគេបានផ្លាស់ប្តូរគំនិតរបស់ពួកគេដែរឬទេ? ហេតុអ្វី?

4.តើមនុស្សមួយចំនួននិយាយអ្វីខ្លះអំពីស្រីពៅ និងសមត្ថភាពរបស់នាងក្នុងការមានកូន ប្រសិនបើនាងលេងបាល់ទាត់?

5.តើអ្នកគិតយ៉ាងដូចម្តេចអំពីគំនិតនេះ? តើវាអាចត្រឹមត្រូវដែរឬទេ?

<u>**ការសម្ភាសទីពីរជាមួយ មករា គ្រូបង្វឹក**</u>

1.តើមករានិយាយអ្វីខ្លះអំពីបទពិសោធន៍របស់នាងក្នុងការលេងបាល់ទាត់ក្នុងនាមជាគ្រូបង្វឹក?

2.តើបងប្អូននិងអ្នកជិតខាងគិតយ៉ាងដូចម្តេចអំពីការលេងបាល់ទាត់និងជាគ្រូបង្វឹកក្រុមក្មេងស្រី នៅពេលដែលនាងចាប់ផ្តើមដំបូង?

3.តើពួកគេមានការផ្លាស់ប្តូរគំនិតរបស់ពួកគេដែរឬទេ?

4.តើមូលហេតុអ្វីដែលអ្នកគិតថាពួកគេផ្លាស់ប្តូរគំនិត?

<u>**ការសម្ភាសទីបីជាមួយ សោម គ្រូបង្វឹកក្រុមជម្រើសជាតិ**</u>

1.តើសំនិយាយអ្វីខ្លះអំពីអារម្មណ៍របស់ក្មេងស្រី ពេលពួកគេចាប់ផ្តើមលេងបាល់ទាត់ដំបូង?

2.តើអារម្មណ៍របស់ពួកគេផ្លាស់ប្តូរដោយរបៀបណា?

3.តើសំបានធ្វើអ្វីខ្លះដើម្បីជួយគាំទ្រមករា និងក្មេងស្រីដទៃទៀត?

4.តើគំនិតទាំងនោះផ្លាស់ប្តូរដោយរបៀបណា? ហេតុអ្វី?

5.តើសំនិយាយអ្វីខ្លះអំពីតួនាទីរបស់ក្មេងស្រី និងស្ត្រីនៅក្នុងប្រទេសកម្ពុជា? តើអ្នកយល់ស្របដែរឬទេ?

## រឿងរបស់ អ៊ុំ ចាន់ថន (ដកស្រង់ពី http://english.ntdtv.com/ntdtv_en/ns_life/2009-09-02/046316997332.html)

ប្រទេសកម្ពុជាមានភាពល្បីឈ្មោះខាងរថយន្តល្អូល និងរ៉ឺម៉កកង់បី ប៉ុន្តែវាគឺជាម៉ូតូឌុបតូចមួយដែល អ៊ុំ ចាន់ថន បើកបរ។ នាងគឺជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីតែពីរឬបីនាក់ប៉ុណ្ណោះនៅលើពិភពលោកនៃអ្នករត់ម៉ូតូឌុប ដែលជាមុខរបរជាប្រពៃណីអនុវត្តដោយបុរស។ អ៊ុំ ចាន់ថន ក្លាយជាអ្នករត់ម៉ូតូឌុបតាំងពី៩ឆ្នាំមុនមកម្ល៉េះ បន្ទាប់ពីនាងលែងលះជាមួយស្វាមី។ នាងចាប់ផ្តើមធ្វើការដើម្បីផ្គត់ផ្គង់គ្រួសាររបស់នាងដែលរួមមាន ម្តាយ កូនប្រុសពីរនាក់ និងក្មួយប្រុសម្នាក់។ អ៊ុំ ចាន់ថន ដែលជាអ្នករត់ម៉ូតូឌុបនិយាយថា "រៀងរាល់ព្រឹក ខ្ញុំក្រោកតាំងពីព្រលឹមដើម្បីសម្អាតម៉ូតូរបស់ខ្ញុំ និងរៀបចំសម្ភារៈសម្រាប់ការងារប្រចាំថ្ងៃរបស់ខ្ញុំ"។ វាមិនធ្វើឱ្យខ្ញុំរាថយទៀយ បើទោះបីជាខ្ញុំជាស្ត្រីតែម្នាក់គត់ដែលធ្វើការរបៀបនេះ។ សូម្បីមិត្តរួមការងារប្រុសរបស់ខ្ញុំក៏បានសរសើរចំពោះការធ្វើការងារនេះដែរ។ ចាន់ទី អ្នករត់ម៉ូតូឌុបនិយាយថា "នាងមានភាពក្លាហានជាងពួកយើង ដែលនាងអាចធ្វើការងាររបស់យើង។ ខ្ញុំសរសើរចិត្តរបស់នាងដែលនាងអាចធ្វើការងារនេះដើម្បីផ្គត់ផ្គង់គ្រួសាររបស់នាងក្រោយពេលបែកបាក់ពីប្តីរបស់នាង"។

វន ស្រីនាង ដែលជាអតិថិជននិយាយថា: ចាន់ថន ទទួលបានអតិថិជនស្ត្រីច្រើនជាងមិត្តរួមការងារបុរសរបស់នាង ដោយអតិថិជនទាំងនោះទុកចិត្តលើជំនាញក្នុងការបើកបររបស់នាង និងចង់ជួយនាង។

នាងទទួលបានអតិថិជនប្រមាណជា៦នាក់ក្នុងមួយថ្ងៃដែលធ្វើឱ្យនាងអាចរកប្រាក់ចំណូលជាមធ្យមចំនួន ១០ដុល្លារក្នុងមួយថ្ងៃ។



**សំណួរ:**

1.តើហេតុអ្វីបានជា ចាន់ថន សម្រេចចិត្តក្លាយជាអ្នករត់ម៉ូតូឌុប?

2.តើនាងយល់ឃើញថាវាមានឧបសគ្គដែរឬទេ?

3.តើមិត្តរួមការងារបុរសរបស់នាងគិតយ៉ាងដូចម្តេចចំពោះនាង?

4.តើអតិថិជនរបស់នាងគិតយ៉ាងដូចម្តេចចំពោះនាង?

5.តើអ្នកគិតយ៉ាងដូចម្តេចអំពីស្ត្រីដែលជាអ្នករត់ម៉ូតូឌុប?

6.តើនាងបានជួយបំបែកផ្នត់គំនិតយេនឌ័រនៅក្នុងប្រទេសកម្ពុជាដោយរបៀបណា?

នៅពេលដែលអ្នកបានឆ្លើយសំណួរទាំងនេះរួច ចូរចែករំលែកចម្លើយរបស់អ្នកជាមួយដៃគូរបស់អ្នក។ ពិភាក្សាជាមួយគ្នាអំពីសំណួរខាងក្រោម:

តើមនុស្សក្នុងរឿងនេះមានអ្វីដូចគ្នា?

# មេរៀនទី ៨: ការចែករំលែកចំណេះដឹង

🕑 រយៈពេលបង្រៀន: ១ ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ:

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ក្ដារខៀន ដីស
- ផ្ទាំងក្រដាសធំ
- ហ្វឺតចំរុះពណ៌ ឬគូល័រទៀន
- ការស្គិត កន្ត្រៃ (សម្រាប់សិស្ស៦ក្រុម)
- ទស្សនាវដ្ដី/កាសែតចាស់ៗ
- ឯកសារសម្រាប់សិស្ស ៨.១

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាចៈ

- កំណត់និងស្គាល់គំនិតសំខាន់ៗដែលទាក់ទងនឹងផ្នត់គំនិតយេនឌ័រ និងការធ្វើការសម្រេចចិត្តក្នុងការចិញ្ចឹមជីវិត។

**សេចក្ដីផ្ដើម: តើខ្ញុំអាចជឿអ្នកបានទេ?** 🕑 ១៥ នាទី

គ្រូរំលឹកសិស្សអំពីកិច្ចការដែលគ្រូឱ្យពួកគេធ្វើការពីចុងមេរៀនមុន។ ប្រាប់ពួកគេថា ពួកគេនឹងប្រើប្រាស់គំនិតរបស់ពួកគេដើម្បីបង្កើតជាផ្ទាំងរូបភាពធំមួយដែលនឹងប្រើប្រាស់សម្រាប់លើកកម្ពស់ការយល់ដឹង។

បិទផ្ទាំងក្រដាសធំអំពីប្រយោគនៅក្នុងមេរៀនមុនដើម្បីរំលឹកពួកគេ *(មើលមេរៀនមុន)*។

គ្រូសួរសិស្សអំពីអ្វីដែលគួរបញ្ចូលទៅក្នុងផ្ទាំងរូបភាពដើម្បីជួយមនុស្សឱ្យយល់ដឹងពីផ្នត់គំនិតយេនឌ័រ និងឥទ្ធិពលរបស់វាមកលើការសម្រេចចិត្តជុំវិញការចិញ្ចឹមជីវិតក្នុងពេលអនាគត។

សរសេរគំនិតរបស់ពួកគេនៅលើក្ដារខៀន ហើយជៀសវាងការសរសេរគំនិតដូចគ្នា។ ប្រាប់ សិស្សឱ្យផ្ដល់គំនិតដែលមិនទាន់មាននៅលើក្ដារខៀន។

នៅពេលដែលសិស្សបានផ្ដល់គំនិតរួចរាល់ហើយ ធ្វើការជាមួយសិស្សដើម្បីចាត់គំនិតទាំងនោះ ជាក្រុមទៅតាមផ្នែកខាងក្រោម៖

១. វប្បធម៌
២. ភេទ និងយេនឌ័រ
៣. ការរើសអើងនៅកន្លែងធ្វើការ
៤. ការយល់ដឹងរបស់សហគមន៍ចំពោះតួនាទីយេនឌ័រ
៥. ការយល់ដឹងរបស់ពិភពលោកចំពោះតួនាទីយេនឌ័រ
៦. ការបែងចែកផ្ទត់គំនិត - រឿងរបស់មនុស្សពិតប្រាកដ

គ្រូពន្យល់ថា អ្វីទាំងនោះគឺជាអ្វីដែលយើងបានរៀននៅក្នុងកម្មវិធីបំណិនជីវិត។ ពួកគេនឹងប្រើប្រាស់គំនិតទាំងនោះដើម្បីបង្កើតជាផ្ទាំងរូបភាព ដែលនឹងប្រើជាឧបករណ៍លើកកម្ពស់ការ យល់ដឹងអំពីផលប៉ះពាល់របស់ផ្នត់គំនិតយេនឌ័រមកលើការសម្រេចចិត្តដែលយើងធ្វើសម្រាប់ការចិញ្ចឹមជីវិតនាពេលអនាគត។

ប្រសិនបើមានតែគំនិតពីរឬបី ឬមិនមានគំនិតទាល់តែសោះនៅក្នុងផ្នែកណាមួយ វាមិនមាន បញ្ហាអ្វីទេ។ វាប្រហែលជាគំនិតខ្លះអាចនៅក្រោមផ្នែកច្រើនជាងមួយ ព្រោះគំនិតអាចទាក់ទងគ្នាច្រើនជាងគំនិតតែមួយ *(មើលសេចក្ដីណែនាំសម្រាប់គ្រូ)*។

## សកម្មភាពសំខាន់។

៦៥ នាទី

គ្រូចាត់ចែងឱ្យសិស្សធ្វើការជាមួយគោលគំនិតទាំងនោះ *(មើលសេចក្ដីណែនាំសម្រាប់គ្រូ)*។

នៅពេលដែលសិស្សចូលក្នុងក្រុមរបស់ពួកគេ និងដឹងពីផ្នែកផ្ទាំងដែលពួកគេត្រូវធ្វើ គ្រូប្រាប់សិស្សថា ពួកគេនឹងធ្វើការមួយ ជាមួយគ្នាដើម្បីរៀបគម្រោងផ្ទាំងរូបភាពធំមួយ។

គ្រូចែកក្រុមនីមួយៗនូវឯកសារសម្រាប់សិស្សអំពីការរៀបគម្រោង *(មើលឯកសារសម្រាប់សិស្ស ឬ សរសេរនៅលើក្ដារខៀន)*។

- ក្រុមរៀបចំសំណួរដោយខ្លួនឯង ដើម្បីប្រើប្រាស់សំណួរទាំងនោះ ដូច្នេះសមាជិកក្រុមនីមួយៗ មានកិច្ចការដែលត្រូវធ្វើ។ មានសិស្សច្រើននាក់ដែលនឹងត្រូវធ្វើកិច្ចការ ជាក់លាក់ណាមួយ។
- នៅពេលដែលក្រុមបានសម្រេចថានរណាត្រូវធ្វើកិច្ចការណា ក្រុមចាប់ផ្ដើមធ្វើកិច្ចការ រៀងៗខ្លួន។
- គ្រូគួរដើរពិនិត្យមើល និងជួយសិស្សដោយផ្ដល់ដំបូន្មាននិងធ្វើឱ្យប្រាកដថា អ្នករាល់គ្នាគឺកំពុងធ្វើកិច្ចការ។

**បញ្ចប់មេរៀន** ១០ នាទី

ឱ្យសិស្សក្រោកឈរ ហើយគ្រូនិយាយថា ពួកគេធ្វើការយ៉ាងសកម្ម ហើយគួរទទួលបាន នូវការសរសើរ។ ឱ្យសិស្សពាក់កណ្តាលថ្នាក់ទះដៃសម្រាប់សិស្សដទៃទៀត ហើយបន្ទាប់មក ឱ្យសិស្សពាក់កណ្តាក់ទៀតទះដៃវិញ។ ចុងក្រោយឱ្យសិស្សទាំងអស់ទះដៃជាមួយគ្នា។ តមកទៀត អ្នកសរសើរពួកគេចំពោះអ្វីដែលពួកគេបានធ្វើតាំងពីដើមរហូតមក និងប្រាប់ថា នៅមេរៀនបន្ទាប់ ពួកគេនឹងចងក្រងការងាររបស់ពួកគេជាផ្ទាំងរូបភាពធំមួយ ហើយប្រសិនបើពួកគេត្រូវការបន្តធ្វើការរៀបគម្រោង និងរៀបចំផ្ទាំងរូបភាពតាមក្រុម លើកទឹកចិត្តពួកគេ ឱ្យធ្វើកិច្ចការនេះមុនពេលមេរៀនបន្ទាប់។

## សេចក្តីណែនាំសម្រាប់គ្រូ

សេចក្តីផ្តើម

- ទោះបីជាផ្ទាំងរូបភាពត្រូវបានជ្រើសរើសជាឧបករណ៍លើកកម្ពស់ការយល់ដឹងសម្រាប់មេរៀននេះក៏ដោយ អ្នកអាចជ្រើសរើសទម្រង់នៃសកម្មភាពចូលរួមជាមួយសហគមន៍ផ្សេងទៀត ដែលសមស្របជាមួយអ្នក និងសិស្សរបស់អ្នក។ មធ្យោបាយផ្សេងៗនៃការផ្សាយព័ត៌មានរួម មានការសម្តែង យុទ្ធនាការឃោសនា ការពិភាក្សាវែកញែក និងការនិទានរឿង។
- វាមានសារៈសំខាន់ដែលគ្រូត្រូវធ្វើឱ្យសិស្សយល់ច្បាស់ថា មាតិកានៃផ្ទាំងរូបភាពគួរឆ្លុះបញ្ចាំងពីអ្វីដែលពួកគេបានរៀននៅក្នុងវគ្គនេះ។
- ខាងក្រោមនេះគឺគំនិតស្នើឡើងមួយចំនួន ដែលសិស្សអាចប្រើដើម្បីបង្កើតជាផ្ទាំងរូបភាព របស់ពួកគេ។ នេះគ្រាន់តែជាឧទាហរណ៍តែប៉ុណ្ណោះ ហើយគ្រូគួរតែប្រើប្រាស់គំនិតរបស់សិស្ស។ ប្រសិនបើគ្រូមានអារម្មណ៍ថា គំនិតរបស់សិស្សមិនឆ្លុះបញ្ចាំងពីអ្វីដែលបានរៀន ឬត្រូវការបន្ថែម គាត់/នាងអាចប្រើគំនិតខាងក្រោម។ វាមិនចាំបាច់ប្រើឧទាហរណ៍ ឬផ្នែកទាំងអស់នោះទេ។ ធ្វើអ្វីដែលល្អបំផុតសម្រាប់អ្នក និងសិស្សរបស់អ្នក។

១. វប្បធម៌

ក. ប្រើប្រាស់សុភាសិតដើម្បីយល់ពីរបៀបដែលវប្បធម៌អាចមានឥទ្ធិពលដល់របៀបដែលយើងប្រព្រឹត្ត

ខ. បង្ហាញរបៀបដែលវប្បធម៌បានផ្លាស់ប្តូរក្នុងរយៈពេលជាច្រើនឆ្នាំមកនេះនិងមូលហេតុ (ម៉ូដសំលៀកបំពាក់ ឱកាសការងារ តន្ត្រី...)

២. យេនឌ័រ និងភេទ

ក. ការកំណត់និយមន័យ ភេទ និងយេនឌ័រ

ខ. តួនាទីយេនឌ័រ និងតួនាទីជីវសាស្ត្រ

៣. ការរើសអើងនៅកន្លែងធ្វើការ

ក. ប្រភេទនៃការរើសអើង

ខ. ផលប៉ះពាល់នៃការរើសអើង

៤. ការយល់ដឹងរបស់សហគមន៍ចំពោះតួនាទីយេនឌ័រ

ក. លទ្ធផលនៃការស្រាវជ្រាវ និងមូលហេតុនៅពីក្រោយលទ្ធផលរបស់យើង( ការវិភាគរបស់យើង )

ខ. ការកំណត់និយមន័យតួនាទីផលិតភាព តួនាទីបន្តពូជ តួនាទីសហគមន៍

៥. ការយល់ដឹងរបស់ពិភពលោកចំពោះតួនាទីយេនឌ័រ

ក. ការពិត និងតួលេខពីជុំវិញពិភពលោក - ផែនទីយេនឌ័រ

ខ. ការប្រៀបធៀបប្រទេសពីរ - ប្រទេសកម្ពុជា ជាមួយ.....?

៦. ការបំបែកផ្ទត់គំនិត - រឿងរបស់មនុស្សពិតប្រាកដ

ក. ឧទាហរណ៍ពិភពលោក

ខ. ឧទាហរណ៍ក្នុងតំបន់ និងក្នុងប្រទេស

ការរៀបគម្រោងសម្រាប់ផ្ទាំងរូបភាពរបស់យើង

● ចំនួនក្រុមនិងចំនួនរបស់គោលគំនិត របស់ផ្ទាំងរូបភាពនីមួយៗនឹងខុសគ្នាពីថ្នាក់មួយទៅថ្នាក់មួយ។ ឧទាហរណ៍ អ្នកប្រហែលជាចង់ឱ្យសិស្សធ្វើការជា ៦ក្រុម ហើយក្រុមនីមួយៗធ្វើការលើផ្នែកម្នាក់ៗ។ ឬក៏ អ្នកចង់ឱ្យសិស្សផ្តោតតែលើមួយឬពីរផ្នែក។ វាអាស្រ័យលើទំហំថ្នាក់ របស់អ្នក និងគំនិតរបស់អ្នកផ្ទាល់អំពីរបៀបដែលអ្នកចង់រៀបចំថ្នាក់ និងផ្ទាំងរូបភាព។ គ្រូ គួរតែអាននៅក្នុងផ្នែកទី៤ នៃសៀវភៅគ្រូ/អ្នកបណ្តុះបណ្តាល LSS LLSP ព្រមទាំងផ្នែកដែលពាក់ព័ន្ធនឹងការរៀបចំក្រុម។

● ចូរចងចាំថា គ្រូអាចជួយ និងធ្វើការជាមួយសិស្ស ទោះបីជាពួកគេធ្វើការជាក្រុមក៏ដោយ។ ដូច្នេះ ជ្រើសរើសការរៀបចំណាមួយដែលអ្នកមានទំនុកចិត្ត និងមានភាពងាយស្រួល ក៏ដូចជាអ្វីមួយដែលជួយក្នុងការរៀនសូត្ររបស់សិស្ស។

● នៅពេលដែលសិស្សបានជ្រើសរើសកិច្ចការរៀងខ្លួននៅក្នុងក្រុមរួច ពួកគេចាប់ផ្តើមធ្វើការជាមួយវា។ គំនិតនៅពីក្រោយនៃការបង្កើតផ្ទាំងរូបភាពនេះ គឺសិស្សនៅក្នុងក្រុមមួយធ្វើការនៅលើផ្នែកមួយនៃផ្ទាំងរូបភាព។ នៅពេលពួកគេបញ្ចប់កិច្ចការនេះ ក្រុមទាំងអស់ត្រូវរួមបញ្ចូលគ្នា ហើយធ្វើការសម្រេចចិត្ត អំពីរបៀបដែលពួកគេរៀបចំផ្នែកនៃកិច្ចការរបស់ពួកគេទាំងអស់ឱ្យទៅជាផ្ទាំងរូបភាពក្រុមមួយ។ កិច្ចការនេះនឹងកើតឡើងនៅមេរៀនបន្ទាប់។

<u>សំណួរការរៀបចំគម្រោងការងារក្រុម</u>

អ្នកនឹងបង្កើតជាផ្ទាំងរូបភាពធំមួយនៅក្នុងក្រុមរបស់អ្នក។ ដើម្បីធ្វើវា អ្នករាល់គ្នាត្រូវធ្វើការនៅលើផ្នែកមួយនៃផ្ទាំងរូបភាពធំនេះ។ ការណែនាំ និងសំណួរខាងក្រោមគឺនឹងជួយអ្នក។ ប្រសិនបើអ្នកគិតថា អ្នកចង់ធ្វើកិច្ចការនេះក្នុងវិធីផ្សេងពីនេះ និងប្រសិនបើក្រុមរបស់អ្នកមានគំនិតខុសពីនេះដើម្បីបង្កើតជាផ្ទាំងរូបភាពធំនោះ ចូរពិភាក្សាគំនិតទាំងនោះជាមួយគ្រូ។

1.តើផ្នែកណាមួយ ឬផ្នែកណាខ្លះដែលអ្នកកំពុងយកចិត្តទុកដាក់ធ្វើនៅក្នុងក្រុមរបស់អ្នក?

.......................................................................................................................................................

.......................................................................................................................................................

2.តើគំនិត/គោលសំខាន់អ្វីខ្លះដែលអ្នកនឹងដោះស្រាយនៅក្នុងក្រុមរបស់អ្នក?

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

3.តើនរណានៅក្នុងក្រុមរបស់អ្នកនឹងធ្វើការលើគំនិត/គោលសំខាន់ណា?

| <u>គំនិត/គោលសំខាន់</u> | <u>ឈ្មោះ</u> |
| --- | --- |
| ក. | |
| ខ. | |
| គ. | |
| ឃ. | |

4.តើអ្នកនឹងធ្វើបទបង្ហាញពីគំនិត/គោលសំខាន់ទាំងនោះដោយរបៀបណា?

នេះគឺជាគំនិតខ្លះដើម្បីជួយអ្នក..........

ក) ការប្រើប្រាស់រូបភាពពិទស្សនាវដ្តីដើម្បីបង្ហាញពីគំនិតរបស់អ្នក

ខ) ការគូររូបភាព ឬក្រាបដើម្បីពន្យល់ពីគំនិត/គោលសំខាន់របស់អ្នក

គ) ការប្រើប្រាស់រឿងពិតរបស់មនុស្សនៅក្នុងភូមិ ឃុំ ប្រទេសរបស់អ្នក ឬពីប្រទេសដទៃ

ឃ) ការប្រើប្រាស់ការពិតពីប្រទេសកម្ពុជា ឬប្រទេសដទៃ

ង) ការសរសេរគំនិតយល់ឃើញផ្ទាល់របស់អ្នកអំពីប្រធានបទ និងរបៀបដែលវាប៉ះពាល់ដល់ការចិញ្ចឹមជីវិតនាពេលអនាគតរបស់អ្នកផ្ទាល់។

# មេរៀនទី ៩: ការចែករំលែកចំណេះដឹង(ត)

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ក្ដារខៀន ដីស
- ហ្វឺតចំរុះពណ៌ ឬគូល័រទៀន
- ការស្កុត កន្ត្រៃ ផ្ទាំងក្រដាសធំ (សម្រាប់សិស្ស៦ក្រុម)
- ទស្សនាវដ្ដី/កាសែតចាស់ៗ
- ឯកសារសម្រាប់សិស្ស ៩.១

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាចៈ

- ប្រើប្រាស់ជំនាញនិងចំណេះដឹងដែលពួកគេបានបង្កើតឡើង ដើម្បីបង្កើតជាផ្ទាំងរូបភាពមួយអំពីផ្នត់គំនិតយេនឌ័រ និងផលប៉ះពាល់របស់វាមកលើការធ្វើការសម្រេចចិត្តក្នុងការចិញ្ចឹមជីវិត។

## សេចក្ដីផ្ដើម

🕑 ១០ នាទី

គ្រូប្រាប់សិស្សថា ពួកគេនឹងបង្រួបបង្រួមនូវអ្វីដែលពួកគេបានរៀនក្នុងអំឡុងពេលកម្មវិធី។ ដំបូងពួកគេនឹងធ្វើការលើការរៀបចំអ្វីគ្រប់យ៉ាងដែលពួកគេបានត្រៀមឱ្យទៅជាទម្រង់ផ្ទាំងរូបភាពមួយ។ ហើយនៅពេលសកម្មភាពនេះបញ្ចប់នឹងមានសកម្មភាពផ្ទះបញ្ចាំងមួយ។

## សកម្មភាពសំខាន់ៗ

🕑 ៧០ នាទី

ការរៀបគម្រោងសម្រាប់ផ្ទាំងរូបភាពរបស់យើង

ឱ្យសិស្សចូលធ្វើការជាមួយក្រុមចាស់របស់ពួកគេ ហើយបន្តធ្វើការលើផ្ទាំងរូបភាពរបស់ពួកគេ *(មើលសេចក្ដីណែនាំសម្រាប់គ្រូ)*។ប្រសិនបើក្រុមខ្លះធ្វើរួចមុនក្រុមដទៃ ឱ្យពួកគេធ្វើសកម្មភាពផ្ទះបញ្ចាំង ឬឱ្យពួកគេជួយសិស្សដទៃ។

ការផ្ទះបញ្ចាំង

គ្រូរៀបចំសកម្មភាពផ្ទះបញ្ចាំងរបស់សិស្ស *(មើលសេចក្ដីណែនាំសម្រាប់គ្រូ)*។

- ចែកទម្រង់ផ្ទះបញ្ចាំងរបស់សិស្សទៅឱ្យសិស្សគ្រប់ៗគ្នា *(មើលឯកសារសម្រាប់សិស្ស)*។
- ពេលដែលសិស្សធ្វើរួច ប្រមូលយកមកវិញ ហើយអានវាពេលបញ្ចប់ម៉ោងបង្រៀន។

**បញ្ចប់មេរៀន** ១០ នាទី

ប្រាប់សិស្សថា នៅមេរៀនក្រោយពួកគេនឹងធ្វើការធ្វើតេស្តក្រោយវគ្គសិក្សាមួយ។ តេស្តនេះ គឺដូចនឹងអ្វីដែលពួកគេបានធ្វើកាលពីពេលចាប់ផ្តើមវគ្គ។ គោលបំណងនៃតេស្តនេះគឺដើម្បី បង្ហាញគ្រូនិងសិស្សថាតើពួកគេរៀនបានប៉ុន្មាននៅក្នុងកម្មវិធីបំណិនជីវិតនេះ។ ទាំងអស់នេះនឹងជួយគ្រូធ្វើការអភិវឌ្ឍមេរៀនរបស់គាត់/នាងនៅពេលក្រោយ ហើយនិងបង្ហាញសិស្សនូវចំណុចដែលពួកគេបានរីកចម្រើន។

សួរពួកគេថា តើពួកគេមានសំណួរអ្វីចង់សួរមកគ្រូដែរឬទេ។

*អរគុណសិស្សសម្រាប់ការខិតខំធ្វើការរបស់ពួកគេ។*

## សេចក្តីណែនាំសម្រាប់គ្រូ

**ការរៀបគម្រោងសម្រាប់ផ្ទាំងរូបភាពរបស់យើង**

● នៅក្នុងសៀវភៅនេះ ដំណាក់កាលចុះប្រតិបត្តិនៃកម្មវិធីបំណិនជីវិតមិនត្រូវបានបញ្ចូលទេ - ក្នុងន័យម្យ៉ាងទៀត វាមិនបានគ្របដណ្តប់ទៅលើរបៀប និងពេលណាដែលសិស្សគួរបង្ហាញផ្ទាំងរូបភាពរបស់ពួកគេឡើយ គឺអាស្រ័យលើគ្រូ និងសាលាក្នុងការស្វែងរកវិធីក្នុងការបង្ហាញការងាររបស់សាលា។ ទោះបីជាយ៉ាងណាក៏ដោយ គួរផ្តល់ជាអនុសាសន៍ថាផ្ទាំងរូបភាពគួរប្រើបានតែក្នុងវិធីមួយចំនួន សូម្បីតែវាសាមញ្ញដូចជាការធ្វើបទបង្ហាញពីផ្ទាំងរូបភាព របស់ពួកគេទៅកាន់គ្នាទៅវិញទៅមកនៅក្នុងថ្នាក់រៀន។

● គ្រូគួរតែអានសៀវភៅគ្រូ/អ្នកបណ្តុះបណ្តាលLSS LLSP និងធ្វើការរំលឹកពីដំណើរការសម្រាប់ការរៀបគម្រោង និងការចុះប្រតិបត្តិសកម្មភាពចូលរួមជាមួយសហគមន៍នៅត្រង់ជំហានទី៤ និងជំហានទី៥ ដើម្បីទទួលបានការណែនាំបន្ថែមពីបណ្តាចំណុចខាងក្រោម។

- តើហេតុអ្វីត្រូវធ្វើសកម្មភាពចូលរួមជាមួយសហគមន៍ ?
- តើគួរបញ្ចូលព័ត៌មានអ្វីខ្លះទៅក្នុងសកម្មភាពចូលរួមជាមួយសហគមន៍ ?
- តើសកម្មភាពគួរធ្វើឡើងនៅពេលណា ?
- តើសកម្មភាពគួរធ្វើឡើងនៅកន្លែងណា ?
- តើសកម្មភាពគួរធ្វើឡើងដោយរបៀបណា ?
- តើនរណាជាក្រុមគោលដៅ ?
- តើនរណាគួរចូលរួមជាមួយ ?

**ការឆ្លុះបញ្ចាំង**

● មានវិធីដែលខុសៗគ្នាជាច្រើនក្នុងការអនុវត្តការឆ្លុះបញ្ចាំងរបស់សិស្ស គឺជាការសំខាន់ដែល ត្រូវចងចាំថាវាជាអ្វីដែលអ្នកចង់រៀនពីសិស្សអំពីកម្មវិធីបំណិនជីវិត និងព័ត៌មានដែលអ្នកទទួល បាននឹងជួយអ្នកឱ្យអភិវឌ្ឍកម្មវិធីក្នុងពេលអនាគតដោយរបៀបណា។

● គ្រូគួរតែអានសៀវភៅគ្រូ/អ្នកបណ្តុះបណ្តាល LSS LLSP និង/ឬដំណើរការវាយតម្លៃ

● ការប៉ាន់ប្រមាណរបស់បំណិនជីវិតដើម្បីជាការណែនាំពួកគេ។ ឧទាហរណ៍ដែលបានផ្តល់នៅក្នុងសៀវភៅនេះនៅក្នុងឯកសារសម្រាប់សិស្សអាចកែប្រែ និង/ឬអភិវឌ្ឍបន្ថែមទៀត។ វាគ្រាន់តែជាការណែនាំប៉ុណ្ណោះ។

●សូមចងចាំថា ដំណើរការឆ្លុះបញ្ចាំងដែលមានគុណភាពគឺទាមទារពេលវេលា។ ប្រសិនបើគ្រូ គិតថាមិនមានពេលវេលានៅសល់គ្រប់គ្រាន់នៅក្នុងមេរៀន អ្នកអាចឱ្យសិស្សបំពេញវានៅផ្ទះ ហើយឱ្យសិស្សប្រគល់វិញនៅម៉ោងបន្ទាប់។



ចូរអានប្រយោគនីមួយៗនីមួយៗក្នុងតារាងខាងក្រោម ហើយគូស(✓)ការឆ្លើយតបដែលសមស្របសម្រាប់អ្នក

| ល.រ. | **ការអភិវឌ្ឍជំនាញ/ឥរិយាបថ** | មិនយល់ស្រប | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|
| 0 | **ការធ្វើបទបង្ហាញ:** ខ្ញុំបានបង្កើនទំនុកចិត្ត និងរៀនដើម្បីអោយនិយាយច្បាស់ៗ។ | | | |
| 1 | **ទំនាក់ទំនង:** ខ្ញុំបានរៀនការធ្វើការពិភាក្សាយ៉ាងសកម្មជាមួយសមាជិកទាំងអស់នៅក្នុងក្រុមរបស់ខ្ញុំ។ | | | |
| 2 | **ការគិតពិចារណាបានស៊ីជម្រៅ/ការវិភាគ:** ខ្ញុំបានរៀនក្នុងការផ្តល់ការឆ្លើយតបដោយប្រើភស្តុតាងដើម្បីគាំទ្រគំនិតរបស់ខ្ញុំ។ | | | |
| 3 | **ការដោះស្រាយបញ្ហា:** ខ្ញុំបានរៀនគិតអំពីដំណោះស្រាយដែលអាចដោះស្រាយបញ្ហាដែលយើងបានពិភាក្សា។ | | | |
| 4 | **ការសហការគ្នា:** ខ្ញុំបានរៀនក្នុងការធ្វើការអោយបានល្អជាមួយក្រុមរបស់ខ្ញុំ។ | | | |
| 5 | **ការធ្វើការសម្រេចចិត្ត:** ខ្ញុំបានរៀនធ្វើការសម្រេចចិត្តនិងមិនខ្លាចក្នុងការនិយាយវាចេញមក។ | | | |
| 6 | **ការដាក់គោលបំណង:** ខ្ញុំបានរៀនក្នុងការបង្កើតគោលបំណងដែលច្បាស់លាស់ និងអាចសម្រេចបាន។ | | | |
| 7 | **ទំនុកចិត្តលើខ្លួនឯង:** ខ្ញុំមានទំនុកចិត្តថា ខ្ញុំដឹងពីអ្វីដែលខ្ញុំកំពុងនិយាយនៅពេលដែលខ្ញុំពិភាក្សាអំពីបញ្ហាយេនឌ័រ។ | | | |
| 8 | **ការលើកទឹកចិត្ត:** ខ្ញុំចង់បន្តការសិក្សាបន្ថែមទៀតអំពីបញ្ហាយេនឌ័រ។ | | | |
| 9 | **ឥរិយាបថវិជ្ជមាន:** ខ្ញុំគិតថា ខ្ញុំរៀនបានរបស់ជាច្រើនពីថ្នាក់បំណិនជីវិត។ | | | |
| 10 | **ការយល់ចិត្ត:** ខ្ញុំយល់បានកាន់តែប្រសើរពីអារម្មណ៍ដែលត្រូវបានគេរើសអើងយ៉ាងណា។ | | | |
| 11 | **ការច្នៃប្រឌិត:** ខ្ញុំបានរៀនបង្កើតការច្នៃប្រឌិតរបស់ខ្ញុំ និងរកមើលគំនិតដើម។ | | | |
| 12 | **អារម្មណ៍:** ខ្ញុំបានបង្កើនភាពអត់ធ្មត់ និងការយល់យោគនៅពេលធ្វើការជាមួយអ្នកដទៃ។ | | | |
| មតិយោបល់ផ្សេងៗ: | | | | |

# មេរៀនទី ១០: គោលបំណងសម្រាប់អនាគត

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ក្ដារខៀន ដីស
- ផ្ទាំងក្រដាសធំ
- ហ្វឺតចំរុះពណ៌ ឬគូលរ័ទៀន
- ឯកសារដូចបានរៀបរាប់ខាងលើ

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាចៈ

- ប្រាប់ហេតុផលសមស្របអំពីអ្វីដែលពួកគេចង់ធ្វើ ឬក្លាយទៅជា... ពេលពួកគេបញ្ចប់ការសិក្សា
- បណ្ដុះអារម្មណ៍ល្អអំពីអ្វីដែលពួកគេបានរៀន និងបន្សល់ទុកនៅកំណត់ត្រាវិជ្ជមាន

## សេចក្ដីផ្ដើមៈ តេស្តបញ្ចប់វគ្គ

🕑 ២០ នាទី

គ្រូប្រាប់សិស្សថា មេរៀនចុងក្រោយនេះនឹងប្រើប្រាស់ដើម្បីធ្វើតេស្តបញ្ចប់វគ្គ ហើយសកម្មភាពសប្បាយៗ។

សួរសិស្សតើថាពួកគេមានសំណួរចុងក្រោយដែរឬទេ មុនពេលចាប់ផ្ដើមធ្វើតេស្ត។

ចូរប្រាកដថា សិស្សទាំងអស់ត្រៀមរួចរាល់ ហើយបន្ទាប់មកចែកក្រដាសតេស្តឱ្យទៅសិស្ស គ្រប់គ្នា។ ទុកពេល២៥នាទី ឱ្យសិស្សធ្វើកិច្ចការនេះ។

- រំលឹកសិស្សថា នេះគឺគ្រាន់តែជាដំណើរការសិក្សាតែប៉ុណ្ណោះ *(មើលសេចក្ដីណែនាំ សម្រាប់គ្រូ)*។
- ក្រោយពេល២៥នាទី ប្រមូលតេស្តមកវិញ

ប្រាប់សិស្សថា អ្នកទន្ទឹងរង់ចាំអានគំនិតរបស់ពួកគេ និងធ្វើការប្រៀបធៀបជាមួយអ្វីដែលគេបានសរសេរពីលើកមុន។ បន្ទាប់មកអ្នកនឹងប្រគល់ឱ្យពួកគេវិញទាំងតេស្តសាកល្បងមុនវគ្គ និង តេស្តបញ្ចប់វគ្គ ដូច្នេះពួកគេអាចនឹងឃើញពីដំណើរការអភិវឌ្ឍជំនាញ ចំណេះដឹង និងឥរិយាបថ ដែលពួកគេបានឆ្លងកាត់។ សម្រាប់មេរៀនដែលនៅសល់ ពួកគេនឹងបង្កើតជាបទចម្រៀងមួយ!

## សកម្មភាពសំខាន់ៗ

🕑 ៦០ នាទី

✋ ឱ្យសិស្សធ្វើការជាក្រុមតូចៗ (ចំនួនក្រុមគឺអាស្រ័យលើចំនួនរបស់សិស្សនៅក្នុងថ្នាក់ ប៉ុន្តែប្រសិនបើអាច មិនគួរឱ្យច្រើនជាង ៨ នាក់ ក្នុងមួយក្រុមឡើង)។

✎ សរសេរនៅលើក្តារខៀននូវឃ្លាៈ "ពេលខ្ញុំធំឡើង ខ្ញុំចង់ក្លាយទៅជា..."

ពន្យល់ប្រាប់សិស្សថា នេះគឺជាចំណាងជើងរបស់បទចម្រៀង។ ពួកគេត្រូវសរសេរវគ្គមួយរបស់បទចម្រៀងនេះ ដែលពាក់ព័ន្ធនឹងចំណងជើងបទចម្រៀង ដោយប្រើប្រាស់បទភ្លេងមួយ *(បទភ្លេងរបស់បទចម្រៀងគួរតែយកចេញពីបទដ៏ល្បីណាមួយ ដែលសិស្សទាំងអស់គ្នាស្គាល់)*។ ពួកគេមានរយៈពេល៤៥នាទីដើម្បីបង្កើតវគ្គមួយនៃបទចម្រៀងនេះ ហើយសមាជិកម្នាក់ៗ នៅក្នុងក្រុមត្រូវចូលរួមគំនិតក្នុងការបង្កើតវគ្គនេះ។

- លើកទឹកចិត្តពួកគេឱ្យមានភាពច្នៃប្រឌិត និងប្រើប្រាស់អ្វីដែលពួកគេបានរៀនក្នុងអំឡុងពេលនៃកម្មវិធីបំណិនជីវិត។
- ក្រោយពេល៤៥នាទីបញ្ឈប់ ឱ្យពួកគេត្រៀមក្នុងការចែករំលែកវគ្គនៃបទ ចម្រៀងរបស់គេ។
- ឱ្យក្រុមនីមួយៗក្រោកឈរ និងច្រៀងនូវវគ្គរបស់ពួកគេ (ចូរប្រាកដថា សិស្សទះដៃ ក្រោយពេលក្រុមនីមួយៗបានច្រៀងចប់)។
- បន្ទាប់ពីក្រុមទាំងអស់បានបញ្ចប់ ឱ្យសិស្សធ្វើការសម្រេចចិត្តតើវគ្គណាគួរនៅទីមួយ ទីពីរ ទីបី ។ល។
- នៅពេលដែលសិស្សបានសម្រេចចិត្តពីលំដាប់នៃបទចម្រៀងរួចមក ឱ្យសិស្សកត់ត្រា បទចម្រៀងទាំងមូលនៅក្នុងសៀវភៅរបស់ពួកគេ។
- ពេលដែលសិស្សកត់រួច ឱ្យសិស្សក្រោកឈរទាំងអស់គ្នា ហើយច្រៀងបទចម្រៀង ទាំងមូល។

## បញ្ចប់មេរៀន

🕑 ១០ នាទី

គ្រូអរគុណសិស្សគ្រប់គ្នាសម្រាប់រយៈពេល ១០សប្តាហ៍ ដែលពោរពេញទៅដោយផលិតភាព និងភាពអស្ចារ្យ ហើយប្រាប់សិស្សថា លោកគ្រូ/អ្នកគ្រូសង្ឃឹមថា ពួកគេបានរៀននូវមេរៀនជាច្រើនដូចអ្វី ដែលអ្នកបានរៀនក្នុងរយៈពេល ១០ សប្តាហ៍កន្លងមកនេះ។

អរគុណពួកគេសម្រាប់ការខិតខំព្យាយាមរបស់ពួកគេ ហើយនិងបញ្ចប់មេរៀនដោយការទះដៃ។

**ការវាយតម្លៃ ៖ សំណួរសរសេរ . ការយល់ដឹងពីយេនឌ័រ**

ឈ្មោះ....................................ភេទ...........ថ្នាក់ទី............សាលា.................................

ស្រុក.....................................ខេត្ត..............................................

១. តើវប្បធម៌ជាអ្វី? តើមនុស្សវ័យក្មេងទទួលជំនឿ និងទម្លាប់ពីវប្បធម៌ដោយរបៀបណា?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

២. តើអ្វីជាភាពខុសប្លែកគ្នារវាងភេទ និងយេនឌ័រ?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៣. តើមានចរិតលក្ខណៈអ្វីខ្លះ ដែលសង្គមគ្រួសារ និងមិត្តភក្តិបង្រៀនដល់ក្មេងស្រី/ស្ត្រី?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៤. តើមានចរិតលក្ខណៈអ្វីខ្លះ ដែលសង្គមគ្រួសារ និងមិត្តភក្តិបង្រៀនដល់ក្មេងប្រុស/បុរស?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៥. តើអ្នកគិតថាអ្នកណាដែលគួរធ្វើកិច្ចការ"សំអាតផ្ទះ"? ផ្តល់ហេតុផលចំពោះចម្លើយដែលបានជ្រើសរើស

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៦. តើអ្នកអាចឧទាហរណ៍មួយអំពីផ្នត់គំនិតយេនឌ័រ និងឧទាហរណ៍មួយទៀតអំពីការរើសអើងយេនឌ័រនៅកន្លែងធ្វើការ?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៧. តើអ្នកគិតថាផ្នត់គំនិតយេនឌ័រ និងការរើសអើងមានកើតឡើងនៅប្រទេសដទៃទៀតដែរឬទេ?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

# សេចក្តីណែនាំសម្រាប់គ្រូ

តេស្តបញ្ចប់វគ្គ

● តេស្តបញ្ចប់វគ្គអាចរកឃើញនៅក្នុងឯកសារសម្រាប់សិស្ស។ តេស្តនេះត្រូវបង្កើតឡើងដោយផ្អែកលើខ្លឹមសារដែលបានគ្រប់ដណ្តប់ក្នុងមេរៀនបំណិនជីវិត។ គោលបំណងរបស់តេស្តនេះគឺដើម្បីវាស់ស្ទង់ពីគំនិត និងចំណេះដឹងដែលសិស្សទទួលបានពីវគ្គសិក្សា។ ដូច្នេះ គ្រូគួរតែរក្សាទុកនូវការឆ្លើយតបរបស់សិស្សក្នុងតេស្តសាកល្បងមុនវគ្គនេះ ឱ្យបានល្អដើម្បីធ្វើការ ប្រៀបធៀប ចម្លើយជាមួយនឹងតេស្តបញ្ចប់វគ្គ។

● តេស្តមេរៀននេះគឺមានចម្លើយដែលផ្អែកលើចំណុចសំខាន់ៗ ដែលសិស្សគួរដាក់បញ្ចូលក្នុងចម្លើយរបស់ពួកគេ។ ចំណុចទាំងអស់នោះគួរត្រូវបានបង្រៀនក្នុងមេរៀនបំណិនជីវិត។ គ្រូអាចប្រើឯកសារតេស្តសាកល្បងមុនវគ្គ ពីមេរៀនទីមួយចែកឱ្យសិស្ស។

● អ្នកអាចឱ្យសិស្សកត់ត្រាសំណួរទៅក្នុងសៀវភៅរបស់ពួកគេ ឬក៏ឱ្យសរសេរវានៅលើក្រដាស ដែលអ្នកអាចប្រមូល និងថែរក្សាបាន *(ដោយហេតុថា តេស្តមានរយៈពេល២៥នាទីពេញ ដូច្នេះអ្នកត្រូវទុកពេលឱ្យពួកគេបន្ថែមទៀតប្រសិនបើអ្នកធ្វើដូចនេះ)*។ ប្រសិនបើអ្នកអាច ថតចម្លងបាន អ្នកអាចថតចម្លង ហើយចែកឱ្យសិស្សគ្រប់គ្នា និងទុកពេលតែ២៥នាទី ឱ្យពួកគេ។

● វាមានសារៈសំខាន់ដែលអ្នកត្រូវរំលឹកពួកគេថា នេះគ្រាន់តែជាដំណើរការសិក្សា ដូច្នេះពួកគេ មិនគួរមានអារម្មណ៍តប់ប្រមល់ក្នុងការធ្វើតេស្តនេះឡើយ!

● ប្រាប់ពួកគេថា អ្នកនឹងឱ្យពួកគេត្រឡប់មកវិញធ្វើនូវតេស្តសាកល្បងមុនវគ្គ និងតេស្តបញ្ចប់វគ្គ ដូច្នេះពួកគេ អាចឃើញថាតើពួកគេបានអភិវឌ្ឍយ៉ាងណាក្នុងរយៈពេល១០សប្តាហ៍ កន្លងមកនេះ។

## តេស្តបញ្ចប់វគ្គ

១. តើវប្បធម៌ជាអ្វី? តើមនុស្សវ័យក្មេងទទួលជំនឿ និងទម្លាប់ពីវប្បធម៌ដោយរបៀបណា?

- វប្បធម៌ដុសខាត់ជំនឿ គុណតម្លៃ និងអាកប្បកិរិយា ហើយគំនិត និងជំនឿទាំងនេះត្រូវបានផ្ទេរពីមួយជំនាន់ទៅមួយជំនាន់ ពីសង្គមមួយទៅសង្គមមួយ។
- សង្គមបានបង្រៀនមនុស្សវ័យក្មេង ពីជំនឿ គំនិត និងទស្សនៈទាំងនេះតាំងពីនាទីដែលពួកគេកើតមកម្ល៉េះ។ មនុស្សវ័យក្មេង ចាប់រៀនពីវប្បធម៌របស់ពួកគេតាំងពីតូចរហូតដល់ធំ។ សង្គមផ្លាស់ប្តូរ វប្បធម៌ប្រែប្រួល។
- វាមានភាពចាំបាច់ដែលត្រូវចងចាំថា វប្បធម៌របស់យើងឆ្លុះបញ្ចាំងពីគុណតម្លៃ និងជំនឿរបស់យើង។ មនុស្សក្នុងសង្គមខុសៗគ្នាអាចមានគុណតម្លៃ និងជំនឿដូចគ្នា ប៉ុន្តែក៏មានភាពខុសគ្នាផងដែរអាស្រ័យលើការជះឥទ្ធិពលពីគ្រួសារ និងស្ថាប័នអប់រំក្នុងសង្គមដែលពួកគេធំដឹងក្តីជាមួយ។

២. តើអ្វីជាភាពខុសប្លែកគ្នារវាងភេទ និងយេនឌ័រ?

- "ភេទ" សំដៅទៅលើភាពខុសគ្នាតាមធម្មជាតិខាងលក្ខណៈជីវសាស្ត្រ ដែលកំណត់មនុស្សមួយថាជាមនុស្សប្រុស និងមនុស្សស្រី ។ ពាក្យនេះពិពណ៌នាអំពីភាពខុសគ្នាផ្នែកផ្លូវកាយ និងកត្តាជីវសាស្ត្រមនុស្សប្រុស និងមនុស្សស្រី ដែលជាការសម្រាប់បន្តពូជ។

- "យេនឌ័រ" សំដៅយកតួនាទី ឥរិយាបថ និងគុណតម្លៃនានាដែលវប្បធម៌ និងសង្គមដាក់កំណត់ឱ្យមនុស្សស្រី និងមនុស្សប្រុសដោយឡែកពីគ្នា។ តួនាទី ឥរិយាបថ និងគុណតម្លៃទាំងនេះកំណត់នូវអាកប្បកិរិយា និងទំនាក់ទំនងរវាងមនុស្សស្រី និងមនុស្សប្រុស។

៣. តើមានចរិតលក្ខណៈអ្វីខ្លះ ដែលសង្គម គ្រួសារ និងមិត្តភក្តិបង្រៀនដល់ក្មេងស្រី/ស្ត្រី?
- កុំលេងបាល់ដូចក្មេងប្រុស
- កូនស្រីត្រូវចេះកិច្ចការផ្ទះ ដូចជាធ្វើម្ហូប
- ត្រូវមានចរឹតសុភាពរម្យទម
- មិនត្រូវតមាត់ជាមួយប្តី...

៤. តើមានចរិតលក្ខណៈអ្វីខ្លះ ដែលសង្គម គ្រួសារ និងមិត្តភក្តិបង្រៀនដល់ក្មេងប្រុស/បុរស?
- កុំលេងតុក្កតា លេងបាយឡុកបាយឡ វាដូចក្មេងស្រីឮ(គ្រួសារ)
- កុំយំ គេថាជាបុរសទន់ខ្សោយ (សង្គម/គ្រួសារ)
- បើមិនផឹក គេមិនថាមនុស្សប្រុសទេ(មិត្តភក្តិ)
- បុរសគឺជាមេគ្រួសារ បុរសត្រូវតែខ្លាំង...

៥. តើអ្នកគិតថាអ្នកណាដែលគួរធ្វើកិច្ចការ "សំអាតផ្ទះ"។ ផ្តល់ហេតុផលចំពោះចម្លើយដែលអ្នកបានជ្រើសរើស។
ក. ភាគច្រើនបុរស
ខ. ភាគច្រើនស្ត្រី
គ. ទាំងពីរ

- ចម្លើយនេះអាចខុសគ្នាពីសិស្សម្នាក់ទៅសិស្សម្នាក់។ ចម្លើយនៃសំណួរនេះ គឺការចែករំលែកការងារគ្នារវាងបុរសនិងស្ត្រី (គ. ទាំងពីរ)។ ចំណុចសំខាន់នៃការផ្តល់ហេតុផលជុំវិញចម្លើយរបស់ក្មេងគឺការមិនរើសអើងការងារថាជាការងារ ឬប្រកាន់តួនាទីថាជាកិច្ចការរបស់ស្ត្រី ទាំងក្មេងប្រុសនិងក្មេងស្រី និងការផ្តល់តម្លៃការងារស្មើគ្នារវាងបុរស និងស្ត្រី។

៦. តើអ្នកអាចឧទាហរណ៍មួយអំពីផ្នត់គំនិតយេនឌ័រ និងឧទាហរណ៍មួយទៀតអំពីការរើសអើងយេនឌ័រនៅកន្លែងធ្វើការ?
- ចម្លើយនេះអាចខុសគ្នាពីសិស្សម្នាក់ទៅសិស្សម្នាក់ ប៉ុន្តែគួរបង្ហាញការយល់ដឹងដែលផ្នត់គំនិតកំណត់ការងារមួយចំនួនដែលសមរម្យសម្រាប់បុរសនិងស្ត្រី និងការរើសអើងយេនឌ័ររារាំងមនុស្សពីការទទួលបានការងារពីព្រោះតែភេទរបស់ពួកគេ។

៧. តើអ្នកគិតថាផ្នត់គំនិតយេនឌ័រ និងការរើសអើងកើតឡើងនៅប្រទេសដទៃទៀតដែរ?
- ចម្លើយនេះអាចខុសគ្នាពីសិស្សម្នាក់ទៅសិស្សម្នាក់ ប៉ុន្តែពួកគេត្រូវតែទទួលស្គាល់ថា ផ្នត់គំនិតយេនឌ័រនិងការរើសអើងតែជាក្តីកង្វល់របស់ពិភពលោកទាំងមូល។

## ឧបសម្ព័ន្ធ ១.១ : គំរូប័ណ្ណវាយតម្លៃ (សម្រាប់គ្រូ)

# ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ........................ សាលា...................... . ខេត្ត.............. ស្រុក................. ថ្នាក់ទី ........ ប្រធានបទ................

| ចំណុចត្រូវដាក់ពិន្ទុ | | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| **កិច្ចការទី ១: តេស្តចំណេះដឹង (សំណួរសរសេរ)** | | | |
| សំណួរសរសេរមានពិន្ទុសរុប ១៥ ពិន្ទុ បើពិន្ទុ 0 ដល់ ៧=ខ្សោយ/ បើ ៨ ដល់ ១០=មធ្យម / បើ ១១ ដល់ ១៥=ល្អ) | | | |
| **សង្កេតឥរិយាបថសិស្ស** | | ពិន្ទុ (១-៥) | និទ្ទេស |
| ១ | **ការប្រាស្រ័យទាក់ទង និងការសហការ :** សកម្មភាពពិភាក្សាជាមួយសមាជិកទាំងអស់ក្នុងក្រុម និងធ្វើការបានប្រសើរ ជាមួយក្រុម ។ សិស្សស្តាប់គ្នាទៅវិញទៅមក និងផ្តល់យោបល់គ្នាទៅវិញទៅមក ។ | | |
| ២ | **ការវិភាគល្អិតល្អន់ និងការដោះស្រាយបញ្ហា :** ផ្តល់ចម្លើយដោយមានហេតុផល និងអំណះអំណាងច្បាស់លាស់ និងអាចកំណត់ដំណោះស្រាយចំពោះបញ្ហាងាយៗដែលជួបប្រទះ ។ | | |
| ៣ | **ការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង :** មិនមានការបារម្ភច្រើន ក្នុងការធ្វើសេចក្តីសំរេចចិត្ត និងដឹងច្បាស់ថាខ្លួនគេកំពុងនិយាយឬធ្វើអ្វីមួយ ។ | | |
| ៤ | **ទំនុកចិត្តលើខ្លួនឯង :** កំឡុងពេលធ្វើបទបង្ហាញនិងពិភាក្សាក្រុម សិស្សមានទំនុកចិត្តក្នុងការនិយាយ និងចូលរួមក្នុងក្រុម | | |
| ៥ | **ការលើកទឹកចិត្ត និងការយល់ចិត្ត:** សិស្សចង់បន្តរៀនសូត្របន្ថែមពីប្រធានបទនេះ ហើយយល់ច្បាស់ខ្លឹមសារក្នុង ប្រធានបទ និងការអនុវត្តផ្ទាល់ ។ | | |
| ៦ | **ចរិត : សិស្ស**មានចិត្តអំណត់និងអារម្មណ៍ល្អនៅក្នុងការសិក្សា ។ | | |
| ៧ | **ការបង្កើតថ្មី :** សិស្សបង្ហាញនូវភាពច្នៃប្រឌិតក្នុងការរៀបចំការធ្វើបទបង្ហាញផលិតផល នៅកំឡុងពេលសិក្សា ដោយបង្ហាញចេញនូវគំនិតជាច្រើន ។ | | |
| | **សរុបសង្កេតឥរិយាបថសិស្ស** | | |
| សង្កេតឥរិយាបថសិស្សមានពិន្ទុសរុប ៣៥ ពិន្ទុ ( បើពិន្ទុ 0 ដល់ ១៧ =ខ្សោយ/ បើ ១៨ ដល់ ២៣=មធ្យម / បើ ២៤ ដល់ ៣៥=ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស ( បើពិន្ទុ 0 ដល់ ២៤=ខ្សោយ/ បើ ២៥ ដល់ ៣៣=មធ្យម / បើ ៣៤ ដល់ ៥០=ល្អ) | | | |

ថ្ងៃទី .......... ខែ ........... ឆ្នាំ ..........

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបរបាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត .......................... ស្រុក ........................សាលា .............................. ថ្នាក់ទី .......... ប្រធានបទ ....................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | ឥរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព ថ្ងៃទី .......... ខែ ............ ឆ្នាំ ..........

នាយកសាលា ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

| ការអង្កេតថ្នាក់រៀន | | | | | ការវាយតម្លៃគ្រូបំណិនជីវិត |
|---|---|---|---|---|---|
| សាលារៀន | | | | គ្រូ | អ្នកសង្កេត |
| | | | | | |
| កាលបរិច្ឆេទ | ការចាប់ផ្តើមមេរៀន | ការបញ្ចប់មេរៀន | ថ្នាក់ | ចំនួនសិស្សដែលបានចុះឈ្មោះ/មានវត្តមាន | ប្រធានបទបំណិនជីវិត: |
| | | | | | |
| តើមេរៀនបង្ហាញពីអ្វី? | | | | | |
| | | | | | |

| លក្ខណៈវិនិច្ឆ័យ – ការរៀបចំ – តើបន្ទប់រៀន.. | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
|---|---|---|
| មានសណ្តាប់ធ្នាប់ ហើយ ត្រៀមសម្ភារៈរួចជាស្រេចសម្រាប់ប្រើប្រាស់ក្នុងមេរៀននេះ? | 1-2-3-4-5 | |
| បង្ហាញសិស្សនូវសម្ភារៈដែលបានធ្វើកាលពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស...** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| មានចំណាប់អារម្មណ៍ និងចូលរួមក្នុងការងាររបស់ពួកគេដែរឬទេ? | 1-2-3-4-5 | |
| ធ្វើការក្នុងក្រុមខុសៗគ្នាក្នុងកំឡុងពេលបង្រៀនដោយមានតួនាទីក្រុមច្បាស់លាស់ | 1-2-3-4-5 | |
| រីករាយជាមួយមេរៀនដែលគ្រូបង្រៀន | 1-2-3-4-5 | |
| បង្ហាញចំណេះដឹង ឬបំណិនពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ – ការបង្រៀន – តើគ្រូ..** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| អនុវត្តតាមកិច្ចតែងការបង្រៀនដែលមានឬទេ? | 1-2-3-4-5 | *សូមបញ្ជាក់ធាតុណាមួយដែលត្រូវបានប្រើ* |
| ប្រើប្រាស់ធនធានសហគមន៍ក្នុងការបង្រៀនមេរៀននេះ ឬប្រើប្រាស់សហគមន៍ទាំងស្រុង? | 1-2-3-4-5 | |

| | | |
|---|---|---|
| ប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម/សកម្ម ឧ.ផែនទីគំនិត, ករណីសិក្សា, ការសម្តែងតួ, ល្បែងកំសាន្ត... | 1-2-3-4-5 | |
| ប្រើប្រាស់ប្រភេទសំណួរផ្សេងៗ | 1-2-3-4-5 | |
| ប្រើប្រាស់ធនធានបង្កើតឡើងដោយខ្លួនឯង ឬឯកសារបន្ថែមដើម្បីពន្យល់មេរៀន | 1-2-3-4-5 | |
| ចាប់ផ្តើមតាមពេលកំណត់ និងប្រើប្រាស់ពេលវេលាយ៉ាងមានប្រសិទ្ធភាព | 1-2-3-4-5 | |
| ផ្តល់មតិយោបល់វិជ្ជមានដើម្បីជំរុញការសិក្សា និងបង្កើនទំនុកចិត្តដល់សិស្ស | 1-2-3-4-5 | |
| ជួយសិស្សជាលក្ខណៈបុគ្គលចំពោះសិស្សណាដែលមានការលំបាក | 1-2-3-4-5 | |
| កត់ត្រាការវិវត្តនៃអត្តចរិតសិស្សក្នុងតារាងវាយតម្លៃការសិក្សារបស់សិស្ស? | 1-2-3-4-5 | |

បន្ទាប់ពីផ្នែកនេះ ចូរប្រើប្រាស់កំណត់ត្រារបស់អ្នកដើម្បីពិភាក្សាជាមួយគ្រូ។ **សុំឱ្យគ្រូកំណត់ចំណុចល្អរបស់មេរៀន** ហើយស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អ។ ធ្វើការជាមួយគ្រូដើម្បីកំណត់ភាពខ្លាំង។ ធ្វើការផ្តល់គំនិតចំពោះការកែលម្អ។ ការសង្កេតត្រូវបានបញ្ចប់ ដោយធ្វើការសម្ភាសន៍។

| ចំណុចខ្លាំង | គំនិតសម្រាប់កែលម្អ |
|---|---|
| | |

ហត្ថលេខា និងឈ្មោះរបស់អ្នកវាយតម្លៃ .......................

ហត្ថលេខា និងឈ្មោះរបស់គ្រូ .....................................

# ដប់ដងត្រូវ ? ឬដប់ដងខុស ?



បុរសគួរចេះជួលជុល
វត្ថុផ្សេងៗ



មានតែក្មេងស្រី/ស្ត្រីទេ
គួររៀនពីរបៀបធ្វើម្ហូប



នេះជាកិច្ចការរបស់ឪពុក
ក្នុងការបង្រៀនកូនប្រុសពី
ក្បាច់ប្រដាល់។



វាមិនល្អទេដែលឪពុកម្តាយ
បង្ហាញក្តីស្រលាញ់ខ្លាំងចំពោះ
កូន ព្រោះវាអាចធ្វើឲ្យក្មេងខូច
និងបានចិត្ត។



បុរសគួរតែរៀនបោកសម្លៀក
បំពាក់ដោយខ្លួនឯង



ប្រសិនបើអ្នកប្រៀបធៀប
ជីវិតបុរស និងស្ត្រី, ជីវិត
របស់បុរសមានលក្ខណៈ
ងាយស្រួលជាង



បុរសបើកម៉ូតូ
ប្រសើរជាង
ស្ត្រី

បុរសមាន
សិទ្ធិមានដៃ
គូរស្នេហា
ច្រើនជាង
មួយ ក្នុង
ពេលតែមួយ



ក្មេងៗត្រូវតែ
បង្ហាញការ
គោរពចំពោះ
ឪពុកម្តាយ





ឪពុកគួរតែជិតស្និទ្ធជាមួយកូនប្រុស ឯ
ម្តាយគួរជិតស្និទ្ធជាមួយកូនស្រី

DEUTSCHE ZUSAMMENARBEIT

Implemented by giz

aecid